# ការវាយតម្លៃអំពើពុករលួយ ក្នុងវិស័យឯកជននៅកម្ពុជា




ស្អាតស្អំ

រួមគ្នាប្រឆាំងអំពើពុករលួយ

# ការវាយតម្លៃអំពើពុករលួយ
# ក្នុងវិស័យឯកជននៅកម្ពុជា

ខែ កក្កដា ឆ្នាំ ២០០៦

គម្រោងការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជន (CAPS) នេះ បានទទួលការឧបត្ថម្ភពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីកិច្ចអភិវឌ្ឍន៍អន្តរជាតិ (USAID) អង្គការ Pact និង អង្គការ PADCO|AECOM និងត្រូវបានអនុវត្តដោយវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (វ.ស.ក.) ។

នាយកស្រាវជ្រាវ : សុក ហាច

ប្រធានគម្រោង : នុត មុនីរតន៍ និង ចាន់ វុទ្ធី

នាយកគ្រប់គ្រង : នៅ សីហា

# មាតិកា


បញ្ជីតារាង ប្រអប់ និងរូបភាព iii

បញ្ជីពាក្យកាត់ v

អារម្ភកថា vii

សេចក្តីសង្ខេប ix

ហេតុអ្វីបានជាមានការសិក្សានេះ? ១

**១. លក្ខណៈនៃអំពើពុករលួយក្នុងវិស័យឯកជន ៣**

១.១. ចំនួននៃការត្រួតពិនិត្យលើសហគ្រាស ៤

១.២. ការដឹងជាមុននៃការចំណាយក្រៅផ្លូវការ ៧

១.៣. ប្រសិទ្ធភាពនៃសេវាសាធារណៈ និងការចំណាយក្រៅផ្លូវការ ៨

១.៤. តើការបង់ចំណាយក្រៅផ្លូវការកើតមានយ៉ាងដូចម្តេច? ៨

**២. មូលហេតុនៃអំពើពុករលួយក្នុងវិស័យឯកជន ១៣**

២.១. មូលហេតុក្នុងការបង់ចំណាយក្រៅផ្លូវការ ១៣

២.២. មូលហេតុនៃការទារចំណាយក្រៅផ្លូវការ ១៥

**៣. វិសាលភាពនៃអំពើពុករលួយ និងផលប៉ះពាល់ ១៩**

៣.១. ភាពធ្ងន់ធ្ងរនៃការបង់ចំណាយក្រៅផ្លូវការ ១៩

៣.២. តើមានអំពើពុករលួយកម្រិតណាក្នុងវិស័យឯកជន? ២១

៣.៣. ផលប៉ះពាល់នៃអំពើពុករលួយលើថវិការដ្ឋ ២៤

៣.៤. ផលប៉ះពាល់នៃអំពើពុករលួយមកលើសេដ្ឋកិច្ច ២៦

## ៤. យុទ្ធសាស្ត្រទប់ស្កាត់អំពើពុករលួយក្នុងវិស័យឯកជន ២៩

៤.១. ការបង្កើតយន្តការប្រឆាំងនឹងអំពើពុករលួយប្រកបដោយប្រសិទ្ធភាព ៣០

៤.២. ការតំឡើងប្រាក់ខែរបស់មន្ត្រីរាជការ ៣៤

៤.៣. ការជំរុញអោយមានអភិបាលកិច្ចល្អ និងសីលធម៌ ៣៧

៤.៤. ការចូលរួមរបស់វិស័យឯកជន ៤១

**សេចក្តីសន្និដ្ឋាន** **៤៣**

**ឯកសារយោង** **៤៥**

**សេចក្តីបន្ថែម ១: ប្រមើលមើលទស្សនវិស័យនៃបរិយាកាសអំពើពុករលួយ** **A១**

**សេចក្តីបន្ថែម ២: វិធីសាស្ត្រក្នុងការសិក្សា** **A៩**

**សេចក្តីបន្ថែម ៣: កម្រងសំណួរស្ទង់មតិ** **A២១**

# បញ្ជីតារាង ប្រអប់ និងរូបភាព

## បញ្ជីតារាង

តារាង ១.១: ភាគរយនៃសហគ្រាសដែលត្រូវបានត្រួតពិនិត្យដោយអាជ្ញាធរផ្សេងៗ
តារាង ៣.១: ភាពធ្ងន់ធ្ងរនៃចំណាយក្រៅផ្លូវការ
តារាង ៣.២: ចំណាយរបស់សហគ្រាសទៅមន្ត្រីសាធារណៈ (គិតជាភាគរយនៃប្រាក់ចំណូលពីការលក់)
តារាង ៣.៣: ចំណាយរបស់សហគ្រាសទៅមន្ត្រីសាធារណៈ (លាន ដុល្លារអាមេរិក)
តារាង ៣.៤: អត្រាពន្ធដែលប្រមូលបាន អត្រាពន្ធផ្លូវការ និងការខាតបង់របស់រដ្ឋាភិបាល

## បញ្ជីប្រអប់

ប្រអប់ ៣.១: តើចំណាយក្រៅផ្លូវការដែលបង់ដោយវិស័យឯកជនត្រូវបានកំណត់របៀបណា?
ប្រអប់ ៣.២: ការយកពន្ធតាមរបបពិត និងរបបម៉ៅការ
ប្រអប់ ៤.១: តើមន្ត្រីសាធារណៈចាយលុយពុករលួយរបៀបណា?
ប្រអប់ ៤.២: គោលនយោបាយរដ្ឋអំពីបៀវត្សរ៍ និងការលើកទឹកចិត្តមន្ត្រីរាជការ
ប្រអប់ ៤.៣: ការិយាល័យបង្អួចមួយនៅស្រុក បាត់ដំបង និងសៀមរាប
ប្រអប់ ៤.៤: តម្លាភាពក្នុងប្រព័ន្ធពន្ធដារ: ធ្វើឱ្យប្រព័ន្ធគណនេយ្យមានភាពសាមញ្ញ

## បញ្ជីរូបភាព

រូបភាព ១.១: ភាពស្មោះត្រង់ និងសុចរិតភាព របស់មន្ត្រីភ្នាក់ងារ ឬសេវាសាធារណៈ
រូបភាព ១.២: ការដឹងជាមុននៃការចំណាយក្រៅផ្លូវការ
រូបភាព ១.៣: ប្រសិទ្ធភាពនៃសេវាសាធារណៈ និងការបង់ចំណាយក្រៅផ្លូវការ
រូបភាព ១.៤: បែបបទនៃចំណាយក្រៅផ្លូវការរបស់មីក្រូសហគ្រាស
រូបភាព ១.៥: បែបបទនៃចំណាយក្រៅផ្លូវការរបស់សហគ្រាសធុនតូច និងមធ្យម
រូបភាព ១.៦: បែបបទនៃចំណាយក្រៅផ្លូវការរបស់សហគ្រាសធុនធំ
រូបភាព ២.១: មូលហេតុនៃការបង់ចំណាយក្រៅផ្លូវការរបស់មីក្រូសហគ្រាស
រូបភាព ២.២: មូលហេតុនៃការបង់ចំណាយក្រៅផ្លូវការរបស់ហគ្រាសធុនតូច និងមធ្យម
រូបភាព ២.៣: មូលហេតុនៃការបង់ចំណាយក្រៅផ្លូវការរបស់សហគ្រាសធុនធំ
រូបភាព ២.៤: ការយល់ឃើញពីមូលហេតុនៃការទារចំណាយក្រៅផ្លូវការរបស់មីក្រូសហគ្រាស

រូបភាព ២.៥: ការយល់ឃើញពីមូលហេតុនៃការទារចំណាយក្រៅផ្លូវការរបស់សហគ្រាសធុនតូច និងមធ្យម
រូបភាព ២.៦: ការយល់ឃើញពីមូលហេតុនៃការទារចំណាយក្រៅផ្លូវការរបស់សហគ្រាសធុនធំ
រូបភាព ៤.១: សកម្មភាពរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ
រូបភាព ៤.២: ការយល់ដឹងរបស់សហគ្រិនអំពីពង្រាងច្បាប់ប្រឆាំងនឹងអំពើពុករលួយ
រូបភាព ៤.៣: ជោគជ័យនៃការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ

# បញ្ជីពាក្យកាត់

| | |
|---|---|
| AAC | សមាគមសិប្បកម្មកម្ពុជា |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AT | ក្រុមកំនត់គោលដៅ |
| CAPS | ការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជន |
| CGE | ម៉ូដែល CGE |
| CPI | សន្ទស្សន៍នៃការយល់ឃើញអំពើពុករលួយ |
| CR | ប្រាក់រៀលកម្ពុជា |
| CSD | មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម |
| DFIO | នាយកដ្ឋានសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| EIC | វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា |
| FGD | ការពិភាក្សាជាក្រុម |
| GDP | ផលិតផលជាតិសរុប |
| GMAC | សមាគមវិស័យកាត់ដេរនៃប្រទេសកម្ពុជា |
| ILO | អង្គការពលកម្មអន្តរជាតិ |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| MIME | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| MoC | ក្រសួងពាណិជ្ជកម្ម |
| MPDF | កម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ |
| MSME | មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| PICS | ការស្ទង់មតិពីបរិយាកាសវិនិយោគ និងផលិតកម្ម |
| SME | សហគ្រាសធុនតូច និងមធ្យម |
| TAF | អង្គការមូលនិធិអាស៊ី |
| TI | តម្លាភាពអន្តរជាតិ |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| UNIFEM | មូលនិធិអភិវឌ្ឍន៍សម្រាប់ស្ត្រីនៃអង្គការសហប្រជាជាតិ |
| USAID | ភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់កិច្ចអភិវឌ្ឍន៍អន្តរជាតិ |
| WB | ធនាគារពិភពលោក |
| WEF | អង្គការវេទិកាសេដ្ឋកិច្ចពិភពលោក |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក |

# អារម្ភកថា

**វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា** (វ.ស.ក.) គឺជាស្ថាប័នស្រាវជ្រាវឯករាជ្យមួយដែលផ្ដោតទៅលើបញ្ហាចំបងនានា ដែលកម្ពុជាកំពុងជួបប្រទះ។ វ.ស.ក. មានបេសកម្មផ្សព្វផ្សាយព័ត៌មានដែលអាចជឿទុកចិត្តបាន ដល់អ្នកពាក់ព័ន្ធទាំងអស់ និងបង្កើនការយល់ដឹងលើគោលនយោបាយសម្រាប់ការអភិវឌ្ឍ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ប្រកបដោយនិរន្តភាព និងអភិបាលកិច្ចល្អ។

របាយការណ៍ *"ការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា"* គឺជាជំហានដំបូងរបស់ វ.ស.ក. ក្នុងការសិក្សាអំពីបញ្ហាអំពើពុករលួយដែលជាផ្នែកមួយនៃកម្មវិធី *"វិមជ្ឈការ និងអភិបាលកិច្ច"* របស់ខ្លួន។

របាយការណ៍នេះ អាចធ្វើទៅបានអាស្រ័យដោយមានការឧបត្ថម្ភ និងគាំទ្រពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីកិច្ចអភិវឌ្ឍន៍អន្តរជាតិ **(USAID)** អង្គការ **Pact** និងអង្គការ **PADCO|AECOM**។

វ.ស.ក. សូមថ្លែងអំណរគុណចំពោះវិស័យឯកជនដែលរួមមាន មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម និងសហគ្រាសធុនធំ ដែលបានចំណាយពេលវេលាដ៏មមាញឹករបស់ខ្លួន ក្នុងការផ្ដល់ព័ត៌មានដ៏មានតម្លៃ និងកិច្ចសហការល្អ សម្រាប់ការសិក្សាស្រាវជ្រាវនេះ។ បើគ្មានការចូលរួមពីវិស័យឯកជនទេ ការសិក្សាស្រាវជ្រាវនេះមិនអាចសម្រេចបាននូវលទ្ធផលប្រកបដោយផ្លែផ្កាបានឡើយ។ វ.ស.ក. ក៏សូមអរគុណផងដែរ ដល់ក្រុមប្រឹក្សាពិគ្រោះយោបល់រួមមាន ទាំងអ្នកជំនាញការឯកជនដែលនាំមុខគេ និងទាំងអ្នកជំនាញការ ខាងអភិបាលកិច្ចនៅក្នុងប្រទេស ដែលផ្ដល់នូវគំនិត និងបទពិសោធន៍ល្អៗសម្រាប់ការសិក្សានេះ។

វ.ស.ក. សូមថ្លែងអំណរគុណជាពិសេសចំពោះ **ឯកឧត្តម ជាម យៀប** ប្រធាន គណៈកម្មការ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃរដ្ឋសភា ដែលបានរៀបចំកិច្ចប្រជុំ ដ៏មានសារៈសំខាន់មួយជាមួយ សមាជិកព្រឹទ្ធសភា និងរដ្ឋសភា ដើម្បីពិភាក្សាអំពីលទ្ធផលជំហានដំបូងនៃការសិក្សាស្រាវជ្រាវនេះ។ វ.ស.ក. ក៏សូមថ្លែងអំណរគុណជាពិសេសផងដែរចំពោះ **ឯកឧត្តម គាត ឈន់** ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំង **លោក ស៊ឹម អៀង** ប្រធាន នាយកដ្ឋានពន្ធដារ ដែលបានផ្ដល់អនុសាសន៍ល្អៗ ដល់លទ្ធផលនៃការស្រាវជ្រាវ និងរបាយការណ៍នេះ។ វ.ស.ក. ក៏សូមថ្លែងអំណរគុណផងដែរចំពោះមន្ត្រីនៃរាជរដ្ឋាភិបាល មួយចំនួនទៀតដែលមិនអាចរៀបរាប់អស់ ក្នុងការសម្រួលដល់ការសិក្សាស្រាវជ្រាវ និងការផ្ដល់អនុសាសន៍ល្អៗដល់របកគំឃើញនូវរបាយការណ៍នេះ។

ជាទីបញ្ចប់ វ.ស.ក. សូមអរគុណយ៉ាងជ្រាលជ្រៅ ចំពោះបុគ្គលិកវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជាទាំងអស់ចំពោះកិច្ចខិតខំប្រឹងប្រែង និងគាំទ្រទាំងកំលាំងកាយចិត្ត ដើម្បីសម្រេចបាននូវរបាយការណ៍នេះប្រកបដោយជោគជ័យ។

**សុក ហាច**

នាយកវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា

# សេចក្ដីសង្ខេប

វិស័យឯកជន ជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច និងដើរតួនាទីសំខាន់មួយក្នុងការបង្កើតការងារសម្រាប់កំលាំងពលកម្មថ្មី។ ដើម្បីលើកកម្ពស់វិស័យឯកជន គេត្រូវការបរិយាកាសអំណោយផលមួយ។ បច្ចុប្បន្ននេះ វិស័យឯកជនកម្ពុជាជួបប្រទះឧបសគ្គនានាមួយចំនួនក្នុងការអភិវឌ្ឍដែលក្នុងនោះអំពើពុករលួយគឺជាឧបសគ្គដ៏ធំបងមួយ។

ដើម្បីលើកកម្ពស់វិស័យឯកជន ចាំបាច់ត្រូវដោះស្រាយអំពើពុករលួយឱ្យបានជោគជ័យ។ ដើម្បីចូលរួមទប់ស្កាត់អំពើពុករលួយក្នុងវិស័យឯកជន វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ដោយបានការគាំទ្រពី USAID Pact និង PADCO|AECOM បានធ្វើការសិក្សាមួយអំពីការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា។

ការសិក្សានេះ ប្រើប្រាស់វិធីសាស្ត្រធំទូលាយមួយដែលរួមមានៈ ការរំលឹកទ្រឹស្តី ការស្ទង់មតិបែបបរិមាណ និងគុណភាព ប្រព័ន្ធម៉ូដែលជាក់លាក់មួយសម្រាប់វាយតម្លៃឥទ្ធិពលនៃអំពើពុករលួយ ក្នុងវិស័យឯកជន រួមទាំងមានក្រុមប្រឹក្សាយោបល់មួយក្រុមផងដែរ។ កាលពីខែ មេសា ២០០៦ ការសិក្សា នេះត្រូវបានអនុវត្តជាមួយទំហំគំរូប្រហែល ១ ២០០ សហគ្រាស ក្នុងខេត្តក្រុងសំខាន់ៗ ៩ ក្នុងប្រទេសកម្ពុជា។ ជាងនេះទៀត ការសិក្សានេះ បានរៀបចំក្រុមពិភាក្សា ២០ ក្រុម ដែលរួមមានមីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម (MSME) រួមទាំងការសម្ភាសផ្ទាល់ជាមួយមន្ត្រីសាធារណៈផងដែរ។

ដើម្បីលើកកម្ពស់ការយល់ដឹងរបស់វិស័យឯកជនអំពីអំពើពុករលួយ របាយការណ៍នេះ ផ្តល់ពន្លឺអំពីលក្ខណៈ មូលហេតុ និងវិសាលភាពនៃអំពើពុករលួយរួមទាំងអនុសាសន៍ជាក់ស្តែងមួយចំនួនក្នុងការទប់ស្កាត់អំពើពុករលួយប្រកបដោយប្រសិទ្ធភាពក្នុងវិស័យឯកជននៅកម្ពុជានេះ។

## លក្ខណៈនៃអំពើពុករលួយ

អំពើពុករលួយអាចកើតឡើងនៅគ្រប់កន្លែង និងគ្រប់វេលា។ ប៉ុន្តែ ក្នុងវិស័យឯកជន អំពើពុករលួយភាគច្រើន កើតមាននៅពេលដែលមានអធិការកិច្ចពីមន្ត្រីសាធារណៈ។ កម្ពុជាមិនមានគោលនយោបាយនៃការធ្វើអធិការកិច្ចឱ្យបានច្បាស់លាស់នៅឡើយទេ ដូចជាចំនួនដងនៃពេលវេលា និងគោលបំណងនៃការធ្វើអធិការកិច្ចនេះជាដើម។ ជាទូទៅ ការធ្វើអធិការកិច្ច គ្រាន់តែជាលេសដើម្បីសុំលុយដោយភ្នាក់ងារមន្ត្រីសាធារណៈនានាប៉ុណ្ណោះ។ MSME ទទួលការធ្វើអធិការកិច្ចច្រើនប្រភេទនៅក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ខ្លួន អាស្រ័យលើលក្ខណៈ ទីតាំង និងប្រភេទរបស់អាជីវកម្មនីមួយៗ។

ស្ថាប័នសាធារណៈដែលធ្វើអធិការកិច្ចលើសហគ្រាសញឹកញាប់ជាងគេរួមមាន មន្ត្រី ពន្ធដារ ប៉ូលីស អាជ្ញាធរមូលដ្ឋាន អាជ្ញាធរសុវត្ថិភាពអគ្គិភ័យ និងអាគារ មន្ត្រីបរិស្ថាន ការធ្វើអធិការកិច្ចលើបទដ្ឋានការងារ

និងសន្តិសុខសង្គម។ល។ ការធ្វើអធិការកិច្ចពន្ធដារ កើតឡើងញឹកញាប់ជាងគេដោយសារតែជាកាតព្វកិច្ចរបស់ពួកគាត់ក្នុងការធានាថា សហគ្រាសទាំងនោះប្រកាសពីកាតព្វកិច្ចពន្ធរបស់ខ្លួនបានត្រឹមត្រូវឬទេ។ ចំនួននៃការធ្វើអធិការកិច្ចលើសហគ្រាសកើនឡើងទៅតាមទំហំនៃសហគ្រាសនោះ។

ការធ្វើអធិការកិច្ចពីមន្ត្រីសាធារណៈ បង្កឱ្យមានបញ្ហាយែនឌ័រផងដែរ។ គ្រួសារដែលដឹកនាំដោយស្ត្រីការប្រកបរបរអាជីវកម្មជួបបន្ទុកច្រើនពីអធិការកិច្ចរបស់មន្ត្រីសាធារណៈ។ ស្ត្រីត្រូវបង់ចំណាយក្រៅផ្លូវការច្រើនជាងធម្មតាដើម្បីរក្សាទំនាក់ទំនងល្អជាមួយមន្ត្រីទាំងនោះ។ ស្ត្រីភាគច្រើនខ្វះការអប់រំ និងព័ត៌មានពីបទបញ្ញត្តិ និងច្បាប់អាជីវកម្មនានាដែលធ្វើឱ្យពួកគាត់ត្រូវបង់ចំណាយក្រៅផ្លូវការកាន់តែច្រើន។ ជាងនេះទៀត ស្ត្រីអាចប្រឈមនឹងការមាក់ងាយ ខាងពាក្យសំដី និងការបំពារបំពានខាងផ្លូវភេទ ពីសំណាក់មន្ត្រីសាធារណៈមួយចំនួនក្នុងពេលធ្វើអធិការកិច្ចទៀតផង។

ការធ្វើអធិការកិច្ច និងចំណាយក្រៅផ្លូវការជាបន្ទុកមួយសម្រាប់វិស័យឯកជន។ ប៉ុន្តែ មីក្រូសហគ្រាសហាក់ដូចជាមិនសូវអើពើនឹងបញ្ហានេះប៉ុន្មានទេ ដោយសារពួកគេជារឿយៗ ដឹងពីបរិមាណដែលត្រូវចំណាយក្រៅផ្លូវការនេះជាមុន។ នេះដោយសារតែ ការចំណាយក្រៅផ្លូវការ ជាផ្នែកមួយនៃជីវភាពប្រចាំថ្ងៃរបស់មីក្រូសហគ្រាស។ ប៉ុន្តែ សហគ្រាសធុនតូច មធ្យម និងធំ មិនសូវដឹងមុនពីបរិមាណដែលត្រូវបង់នោះទេ។ នេះដោយសារ ភាពស្មុគស្មាញនៃសហគ្រាសធុនតូច មធ្យម និងធុនធំ ទាំងនោះដែលបង្កឱ្យមានភាពខុសគ្នាក្នុងការបង់ចំណាយក្រៅផ្លូវការលើករណីនីមួយៗដោយឡែកៗពីគ្នា។

ជាទូទៅ មន្ត្រីសាធារណៈមកសហគ្រាសដោយផ្ទាល់ដើម្បីទារសំណូក។ ប៉ុន្តែ សហគ្រាសខ្លះទាក់ទងមន្ត្រីសាធារណៈដោយខ្លួនឯងផ្ទាល់ ឬតាមរយៈអ្នករត់ការ ដើម្បីផ្តល់សំណូកផងដែរ ដែលភាគច្រើនជាសហគ្រាសផ្លូវការ ជាពិសេសជាសហគ្រាសធុនតូច មធ្យម និងធុនធំ។ សហគ្រាសណាដែលមានលក្ខណៈផ្លូវការខ្លាំង ត្រូវប្រឈមមុខនឹងការិយាធិបតេយ្យកាន់តែច្រើន។ ដូចនេះ ដើម្បីទទួលបានសេវាសាធារណៈរហ័ស និងប្រសិទ្ធភាព ការប្រើប្រាស់អ្នករត់ការ និងទំនាក់ទំនងផ្ទាល់នឹងមន្ត្រីសាធារណៈជាការសំខាន់។ នៅពេលដែលសហគ្រាសមួយបង់ចំណាយក្រៅផ្លូវការរួចហើយ សហគ្រាសនោះនឹងទទួលបានសេវាកម្មពីមន្ត្រីសាធារណៈប្រកបដោយប្រសិទ្ធភាព។

## មូលហេតុនៃអំពើពុករលួយ

វិស័យឯកជន និងមន្ត្រីសាធារណៈ ព្យាយាមពន្យល់អំពីមូលហេតុនានាដែលនាំឱ្យមានអំពើពុករលួយនេះ។ សហគ្រិនផ្តល់មូលហេតុផ្សេងៗគ្នានៃការបង់ក្រៅផ្លូវការឱ្យមន្ត្រីសាធារណៈ។ ជាទូទៅ មីក្រូសហគ្រិនបង់ចំណាយក្រៅផ្លូវការដើម្បីរក្សាទំនាក់ទំនងល្អជាមួយមន្ត្រីរាជការ។ មូលហេតុចំបងសម្រាប់សហគ្រិនរបស់

សហគ្រាសធុនតូច មធ្យម និងធំ ក្នុងការចំណាយក្រៅផ្លូវការ ភាគច្រើនគឺដើម្បីទទួលបានសេវាសាធារណៈ។ ការរក្សាទំនាក់ទំនងល្អជាមួយមន្ត្រីទាំងនោះជារឿងបន្ទាប់បន្សំ។

សហគ្រិនយល់ថា មូលហេតុចំបងនៃអំពើពុករលួយគឺៈ "ប្រាក់ខែទាបរបស់មន្ត្រីរាជការ" កង្វះយន្តការប្រឆាំងនឹងអំពើពុករលួយ" "វប្បធម៌នៃអំពើពុករលួយ" "កង្វះឯករាជ្យភាពតុលាការ និងប្រសិទ្ធភាព" និង "ការអនុវត្តច្បាប់ខ្សោយ"។

ដូចគ្នាដែរ មន្ត្រីសាធារណៈបានយល់ស្របជាមួយគំនិតទាំងឡាយដែលបានលើកឡើងដោយវិស័យឯកជន។ ប៉ុន្តែ មន្ត្រីសាធារណៈបានសង្កត់ធ្ងន់លើរបៀបវារៈរបស់ ខ្លួនថាជាមូលហេតុដ៏ចំបងដែលបណ្តាលឱ្យមានអំពើពុករលួយ។

## វិសាលភាពនៃអំពើពុករលួយ

ចំណាយក្រៅផ្លូវការរបស់វិស័យឯកជននៅកម្ពុជាមានកម្រិតខ្ពស់។ កម្រិតនេះប្រែប្រួលទៅតាមបណ្តាខេត្តនានា អាស្រ័យលើរដ្ឋបាលសាធារណៈមូលដ្ឋាន ដែលពាក់ព័ន្ធវិស័យឯកជន និងសកម្មភាពសេដ្ឋកិច្ចនៅតាមតំបន់នីមួយៗ។

ទោះបីយ៉ាងណា MSME យល់ឃើញថា ការបង់ចំណាយក្រៅផ្លូវការ មិនមានកម្រិតធ្ងន់ធ្ងរទេ ដោយសារសហគ្រាសទាំងនោះ អាចរ៉ាប់រងនូវការចំណាយទាំងនោះបាន។ សហគ្រាសកាន់តែធំ ការបង់ចំណាយក្រៅផ្លូវការកាន់តែច្រើន។ សហគ្រាសផលិតកម្ម បង់ចំណាយក្រៅផ្លូវការច្រើនផងដែរ ដោយសារសហគ្រាសទាំងនោះ ចាំបាច់ត្រូវធ្វើការទាក់ទងជាមួយនឹងមន្ត្រីសាធារណៈផ្សេងៗ ទៅតាមដំណាក់កាលនៃផលិតកម្មរបស់ខ្លួន។

ជាមធ្យម វិស័យឯកជនបង់ចំណាយក្រៅផ្លូវការប្រមាណ ២,៨ ភាគរយ នៃចំណូលពីការលក់ប្រចាំឆ្នាំសរុបរបស់ខ្លួន គឺស្មើនឹង ៣៣០ លានដុល្លារអាមេរិក ឆ្នាំ ២០០៥។ ចំនួននេះមិនរាប់បញ្ចូលនូវចំណាយក្រៅផ្លូវការដែលត្រូវបានបង់ឡើងដោយសហគ្រាសនាំចេញនាំចូលទៅឱ្យមន្ត្រីគយ កំពង់ផែ និងមន្ត្រីរាជការផ្សេងទៀត ឬដោយសហគ្រាសដែលទទួលកិច្ចសន្យាការងារពីរដ្ឋាភិបាល។

ជារួម មីក្រូសហគ្រាសបង់ប្រមាណ ១,៨ ភាគរយ សហគ្រាសធុនតូច និងមធ្យម ប្រមាណ ២,៥ ភាគរយ និងសហគ្រាសធុនធំ ប្រមាណ ៤,១ ភាគរយ នៃចំណូលប្រចាំឆ្នាំសរុប។

តួលេខខាងលើបញ្ជាក់ថា អំពើពុករលួយក្នុងវិស័យឯកជនត្រូវបានកាត់បន្ថយបើធៀបនឹងការអង្កេត ដែលធ្វើឡើងដោយធនាគារពិភពលោកឆ្នាំ ២០០៤ ដែលបានរកឃើញថា ប្រាក់ចំណាយក្រៅផ្លូវការប្រមាណ ៥-៧ ភាគរយ នៃចំណូលពីការលក់សរុប។

*ឥទ្ធិពលលើថវិការដ្ឋ*

ទោះបីជាអំពើពុករលួយនៅក្នុងវិស័យឯកជនហាក់ដូចជាកាត់បន្ថយក៏ដោយ ក៏បរិមាណសរុបនៃប្រាក់ដែលបានបាត់បង់ដោយសារអំពើពុករលួយនេះ នៅតែមានកម្រិតខ្ពស់នៅឡើយ។ ចំណាយក្រៅផ្លូវការរបស់វិស័យឯកជនក្នុងមួយឆ្នាំៗ មានប្រមាណ ៣៣០ លានដុល្លារ។ បរិមាណនេះ តំណាងឱ្យប្រមាណ ៥០ ភាគរយ នៃចំណូលថវិការដ្ឋឆ្នាំ ២០០៥ ឬ ៦ ភាគរយ នៃផលិតផលក្នុងស្រុកសរុប។

កម្រិតចំណាយក្រៅផ្លូវការនេះ មានឥទ្ធិពលលើប្រសិទ្ធភាពនៃការប្រមូលពន្ធ។ អត្រាពន្ធផ្លូវការលើវិស័យឯកជនមានកម្រិតខ្ពស់ច្រើនជាងអត្រាពន្ធដែលប្រមូលបាន។ បើទោះបីជា ចំណូលពន្ធក្នុងស្រុក ដែលប្រមូលដោយនាយកដ្ឋានពន្ធដារមានកំណើនខ្លាំងក្តី ក៏ចំណូលពន្ធនេះមានត្រឹមតែប្រមាណ ២៥ ភាគរយ នៃពន្ធសក្តានុពលប៉ុណ្ណោះ។ ដូចនេះ រដ្ឋអាចបាត់ចំណូលពន្ធដល់ទៅ ៤០០ លានដុល្លារ ក្នុងឆ្នាំ ២០០៥។ នេះគឺជាលទ្ធផលនៃប្រព័ន្ធពន្ធដែលសាំញ៉ាំ និងគ្មានតម្លាភាព។

## ការទប់ស្កាត់អំពើពុករលួយ

ការទប់ស្កាត់អំពើពុករលួយមានការលំបាក ប៉ុន្តែអាចធ្វើទៅបាន។ គ្មានវិធីជាក់លាក់ណាមួយ ដើម្បីលុបបំបាត់អំពើពុករលួយបានទាំងស្រុងទេ។ យុទ្ធសាស្ត្រ និងអនុសាសន៍ផ្សេងៗ គួរត្រូវបានអនុវត្តន៍ដើម្បីទប់ស្កាត់អំពើពុករលួយ ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ របាយការណ៍នេះ មានគោលបំណងផ្តល់ជូននូវអនុសាសន៍មួយចំនួនដែលទទួលបាន ពីវិស័យឯកជន និងមន្ត្រីសាធារណៈ។

*ការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយដែលត្រឹមត្រូវ*

ការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ គឺត្រូវការជាចាំបាច់។ មកដល់បច្ចុប្បន្ន កម្ពុជានៅមិនទាន់មានច្បាប់ប្រឆាំងអំពើពុករលួយនៅឡើយទេ។ រាជរដ្ឋាភិបាលបានបរាជ័យ ក្នុងការប្តេជ្ញាចិត្តរបស់ខ្លួនដើម្បីអនុម័តច្បាប់ប្រឆាំងអំពើពុករលួយឱ្យបានត្រឹមចុងខែ មិថុនា ២០០៦ ដូចដែលបានសន្យាក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់រវាងម្ចាស់ផ្តល់ជំនួយ និងរាជរដ្ឋាភិបាលក្នុងខែមីនា ២០០៦ កន្លងទៅនេះ។

ពង្រាងច្បាប់នេះ នៅមានភាពចម្រូងចម្រាសនៅឡើយ បើអនុលោមតាមស្តង់ដាអន្តរជាតិ។ ភាពចម្រូងចម្រាសនេះ ទាក់ទងជាពិសេសទៅនឹងឯករាជ្យភាពនៃការប្រតិបត្តិ និងថវិកាស្វយ័តរបស់លេខាធិការដ្ឋាន និងភាពឯករាជ្យរបស់អាជ្ញាធរស៊ើបអង្កេត។ ពង្រាងច្បាប់នេះ ក៏មិនបានអនុញ្ញាតឱ្យអគ្គលេខាធិការក្រុមប្រឹក្សាប្រឆាំងអំពើពុករលួយទទួលបានព័ត៌មានពីការប្រកាសទ្រព្យសម្បត្តិ ដែលរាប់បញ្ចូលទាំងភរិយា និង កូនរបស់មន្ត្រីផងក្នុងកំឡុងពេលធ្វើការស៊ើបអង្កេត។ ពង្រាងច្បាប់នេះ ខ្វះនូវខចែងដែលពាក់ព័ន្ធនឹងការណ៍សម្ងាត់ដើម្បីការពារជនរងគ្រោះ និងសាក្សី និងទោស ពិសេសចំពោះការបែកធ្លាយការណ៍សម្ងាត់។

ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយក្នុងវិស័យឯកជន ក៏ដូចជាក្នុងប្រទេសទាំងមូល ជំហានដំបូងបំផុតគឺ ការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយដ៏ត្រឹមត្រូវមួយ។ រដ្ឋាភិបាលបានបង្ហាញនូវឆន្ទៈដ៏មុះមុត ក្នុងការប្រឆាំងអំពើពុករលួយតាមរយៈគោលនយោបាយផ្សេងៗរបស់ខ្លួន។ ដើម្បីសម្រេចនូវឆន្ទៈនេះ ចាំបាច់ត្រូវធ្វើការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយស្តង់ដារខ្ពស់ ដើម្បីឱ្យកម្ពុជាមានមូលដ្ឋានច្បាប់ដ៏រឹងមាំ និងអាចជឿទុកចិត្តបាន។

### *ការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយប្រកបដោយប្រសិទ្ធភាព*

ការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយប្រកបដោយប្រសិទ្ធភាព មានទំនាក់ទំនងនឹងបញ្ហាប្រាក់ខែរបស់មន្ត្រីរាជការ។ ប្រសិនបើគ្មានប្រាក់ខែគ្រប់គ្រាន់សម្រាប់មន្ត្រីរាជការអាចរស់បានទេ ពួកគាត់ត្រូវប្រព្រឹត្តអំពើពុករលួយដោយទទួលសំណូកពីវិស័យឯកជន។ ប្រសិនបើប្រាក់ខែសម្រាប់ទ្រទ្រង់ជីវភាពរបស់មន្ត្រីរាជការដែលជាប់ពាក់ព័ន្ធក្នុងអំពើពុករលួយមានកម្រិតខ្ពស់គ្រប់គ្រាន់នឹងតម្រូវការនោះ ចរិកលក្ខណៈពុករលួយរបស់គេនឹងទប់ស្កាត់បានយ៉ាងច្រើន។ ដូច្នេះ ការតម្លើងប្រាក់ខែមន្ត្រីរាជការនឹងជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយដើម្បីកាត់បន្ថយអំពើពុករលួយ។

បញ្ហាគឺថា តើប្រាក់ខែប៉ុន្មានទៅដែលគ្រប់គ្រាន់សម្រាប់មន្ត្រីរាជការ។ មន្ត្រីរាជការធម្មតាជឿថាប្រាក់ខែពី ១០០ ទៅ ១៥០ ដុល្លារ ក្នុងមួយខែ គឺគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ជីវភាពរបស់គាត់ និងអាចផ្គត់ផ្គង់តម្រូវការមូលដ្ឋានរបស់គ្រួសារគាត់។ ក្នុងយុទ្ធសាស្ត្រចតុកោណ រដ្ឋាភិបាលបានសន្យាតម្លើងប្រាក់ខែមន្ត្រីរាជការពី ១០ ទៅ ១៥ ភាគរយ ដើម្បីពង្រឹងកម្រិតជីវភាព របស់ពួកគាត់អោយបានសមរម្យតាមឋានៈ។ ការតម្លើងប្រាក់ខែរបស់មន្ត្រីរាជការជាបន្តបន្ទាប់ ត្រូវបានដាក់អនុវត្ត ប៉ុន្តែពួកគាត់នៅត្អូញត្អែរពីការតម្លើងនេះមិនគ្រប់គ្រាន់សម្រាប់គេ។

### *ការជំរុញអោយមានអភិបាលកិច្ចល្អ និង សីលធម៌*

អភិបាលកិច្ចល្អមានតួនាទីសំខាន់ក្នុងការទប់ស្កាត់អំពើពុករលួយ។ ការបង្កើតអោយមាន "សេវាច្រកចេញចូលតែមួយ" អាចកាត់បន្ថយអំពើពុករលួយ ដោយជួយបង្កើនល្បឿនដំណើរការរដ្ឋបាលសាធារណៈ។

សំខាន់ជាងនេះទៀត បទបញ្ញត្តិ ច្បាប់ នីតិវិធី និងព័ត៌មានអំពីអាជីវកម្មគួរតែមានភាពសាមញ្ញ ងាយស្រួលសម្រាប់វិស័យឯកជន និង មានចំណាយតិច។ ប្រាក់ចំណាយអាជីវកម្មផ្លូវការទាំងអស់ គួរតែបោះពុម្ពផ្សាយ និងផ្សព្វផ្សាយដល់វិស័យឯកជន។

វិធានការណ៍មួយទៀតដើម្បីពង្រឹងអភិបាលកិច្ចល្អដែលលើកឡើងដោយមន្ត្រីសាធារណៈ គឺការផ្លាស់ប្តូរមន្ត្រីរាជការពីកន្លែងមួយទៅកន្លែងមួយទៀត។ ការធ្វើរបៀបនេះ នឹងទប់ស្កាត់មិនអោយមានការពង្រឹងបណ្តាញ និងការបង្កើតឱកាសសម្រាប់ពុករលួយ។

លើសពីនេះទៀតការគ្រប់គ្រង និងត្រួតពិនិត្យពីមន្ត្រីថ្នាក់លើ លើមន្ត្រីថ្នាក់ក្រោមអោយបានតឹងរឹង វាមានសារៈសំខាន់ណាស់។ មន្ត្រីថ្នាក់ខ្ពស់គួរមានគោលនយោបាយច្បាស់លាស់ ដូចជាការណែនាំ និងការត្រួតពិនិត្យតឹងតែងលើអ្នកក្រោមបង្គាប់ និងគួរទទួលខុសត្រូវចំពោះអំពើពុករលួយរបស់មន្ត្រីក្រោមឱវាទ។

ជាងនេះទៅទៀត វាមានសារៈសំខាន់ណាស់ក្នុងការជំរុញប្រសិទ្ធភាពនៃរដ្ឋបាលសាធារណៈតាមរយៈការធានាការជ្រើសរើសមន្ត្រីរាជការត្រឹមត្រូវ ការវាយតម្លៃ និង ការតម្លើងឋានៈមន្ត្រីរាជការ។ មន្ត្រីរាជការគួរត្រូវបានពង្រឹងសមត្ថភាព ដើម្បីអាចអនុវត្តតួនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ ការអនុវត្តចំណុចនេះ មានសារៈសំខាន់ណាស់ក្នុងការលុបបំបាត់អំពើបក្សពួកនិយម និង ប្រព័ន្ធពុករលួយដែលមានភាពជាចៅហ្វាយ។

រដ្ឋបាលសាធារណៈ គួរបង្កើតនូវប្រព័ន្ធមួយដែលអនុញ្ញាតអោយប្រជាជនអាចធ្វើការរាយការណ៍ពីអំពើពុករលួយ។ ការរាយការណ៍នេះ គួរតែធ្វើឡើងដោយសំងាត់ ហើយអ្នករាយការណ៍គួរតែត្រូវបានការពារ។ របាយការណ៍ដែលធ្វើឡើងដោយពលរដ្ឋ គួរតែត្រូវចាត់វិធានការណ៍អោយបានមុតមាំដើម្បីឱ្យពួកគាត់មានទឹកចិត្តរាយការណ៍នៅពេលក្រោយ។

ជាចុងក្រោយ ក្រមសីលធម៌មានសារៈសំខាន់ណាស់សម្រាប់បង្រៀនឱ្យមនុស្សគ្រប់រូបឱ្យស្អាតស្អំ។ ក្រមសីលធម៌ណាដែលជាវិធីដ៏សំខាន់មួយសម្រាប់ទប់ស្កាត់អំពើពុករលួយ គួរតែត្រូវបានជំរុញ និងពង្រឹងឡើងតាមរយៈការអប់រំ។ មនុស្សគ្រប់រូបជាពិសេស វិស័យឯកជន និងមន្ត្រីរាជការគួរតែត្រូវបានបង្រៀនអោយមានភាពស្មោះត្រង់ គំនិតស្នេហាជាតិ ស្មារតីជាតិនិយម និងមនសិការជាតិ។

### *ការចូលរួមប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយដោយវិស័យឯកជន*

វិស័យឯកជន អាចចូលរួមប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយតាមវិធី ២ យ៉ាង។ ទី ១ វិស័យឯកជនខ្លួនឯងចាំបាច់ត្រូវមានភាពស្មោះត្រង់។ ប្រសិនបើមនុស្សគ្រប់រូបមិនពុករលួយទេនោះ អំពើពុករលួយនឹងមិនកើតឡើងឡើយ។ វិស័យឯកជនទាំងអស់គួរដកខ្លួនពីការផ្តល់សំណូកឱ្យមន្ត្រីសាធារណៈ។

ទី ២ វិស័យឯកជនអាចបង្កើត ឬចូលរួមក្នុងសហគមន៍ ឬសមាគមប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ សហគ្រាសមួយមិនមានសំឡេងគ្រប់គ្រាន់ដើម្បីឱ្យមានឥទ្ធិពលលើអាជ្ញាធរសាធារណៈ ឱ្យពិចារណាអំពីបញ្ហា ឬប្រយោជន៍នានារបស់គាត់ឡើយ។ សមាគមមានប្រសិទ្ធភាពច្រើនជាង ក្នុងការសម្តែងកង្វល់របស់ពួកគាត់ ឱ្យបានដល់អ្នកធ្វើគោលនយោបាយ។

សមាគមវិស័យឯកជនទាំងនេះ អាចជោគជ័យបាន ដរាបណាមានការគាំទ្រពេញទំហឹងពីរដ្ឋាភិបាល និងបរិយាកាសអំណោយផលមួយ ដែលពួកគាត់អាចប្រើសិទ្ធិរបស់ខ្លួន និងចូលសមាគមដោយគ្មានការភ័យខ្លាច។

## សេចក្តីសន្និដ្ឋាន

អំពើពុករលួយក្នុងវិស័យឯកជនមានលក្ខណៈស្មុគស្មាញ។ ទាំងម្ចាស់សហគ្រាស និងទាំងមន្ត្រីសាធារណៈ សុទ្ធតែបានពាក់ព័ន្ធនឹងអំពើពុករលួយដែលមានពាសពេញផ្ទៃប្រទេស ដោយសារតែប្រព័ន្ធនៃភាពជាចៅហ្វាយ និងខ្សែបណ្តាញ។

ទោះបីជាទំហំនៃអំពើពុករលួយក្នុងវិស័យឯកជនហាក់បីដូចជាធ្លាក់ចុះបើធៀបនឹងការវាយតម្លៃរបស់ធនាគារពិភពលោកក្នុងឆ្នាំ ២០០៤ ក៏ដោយ ក៏ទំហំនៅតែខ្ពស់នៅឡើយ។ ដើម្បីទប់ស្កាត់អំពើពុករលួយ បញ្ហាឫសគល់ដែលនាំឱ្យមានអំពើពុករលួយទាំងនេះគួរត្រូវតែដោះស្រាយ។

ប្រសិនជាអំពើពុករលួយក្នុងវិស័យឯកជនត្រូវបានលុបបំបាត់ ចំនួនប្រាក់ដែលបាត់ដោយសារអំពើពុករលួយនេះអាចយកមកប្រើឱ្យកាន់តែមានប្រសិទ្ធភាពជាងនេះទៅទៀតក្នុងការអភិវឌ្ឍ។ បរិមាណនៃការបាត់បង់នេះ (៣៣០ លានដុល្លារ ក្នុងឆ្នាំ ២០០៥) មានចំនួនលើសពីសេចក្តីត្រូវការចាំបាច់សម្រាប់យកទៅតម្លើងបៀវត្សរ៍មន្ត្រីរាជការដល់កម្រិតជាមធ្យម ១០០ ទៅ ១៥០ ដុល្លារអាមេរិក ក្នុងមួយខែ។ អំពើពុករលួយត្រូវកាត់បន្ថយ ឯសេវាសាធារណៈ ក៏កាន់តែមានប្រសិទ្ធភាព។

ជាងនេះទៅទៀត ដោយសារប្រព័ន្ធអំពើពុករលួយ រដ្ឋាភិបាលអាចប្រមូលពន្ធបានតែប្រហែល ២៥ ភាគរយ នៃចំណូលពន្ធសក្តានុពលសរុប។ ការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការប្រមូលចំណូលរដ្ឋឱ្យបានកាន់តែច្រើនគួរផ្តោតលើការធ្វើឱ្យប្រព័ន្ធពន្ធដារមានលក្ខណៈសាមញ្ញ និងប្រកបដោយតម្លាភាពក្នុងការប្រមូលពន្ធ។

## ហេតុអ្វីបានជាមានការសិក្សានេះ?

វិស័យឯកជន គឺជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច និងមានតួនាទីសំខាន់មួយក្នុងការបង្កើតការងារសំរាប់កំលាំងពលកម្មថ្មីៗ។ ការលើកស្ទួយវិស័យឯកជនតម្រូវឱ្យមានបរិយាកាសល្អ និងអំណោយផលក្នុងការធ្វើអាជីវកម្ម។ ដោយឡែក នៅកម្ពុជាវិស័យឯកជនជួបប្រទេះឧបសគ្គជាច្រើនក្នុងការអភិវឌ្ឍ។

របាយការណ៍របស់ធនាគារពិភពលោកស្តីពីការវាយតម្លៃបរិយាកាសវិនិយោគ និងយុទ្ធសាស្ត្រកំណែទម្រង់របស់កម្ពុជាបានបង្ហាញថា ឧបសគ្គដ៏ចំបងសម្រាប់វិស័យឯកជននៅកម្ពុជាគឺ"អំពើពុករលួយ"។ ទំហំនៃការបង់ចំណាយទៅអោយមន្ត្រីសាធារណៈមានចំនួន ៥ ភាគរយ នៃចំណូលពីការលក់ប្រចាំឆ្នាំ។ ការសិក្សាថ្មីមួយ ដែលធ្វើឡើងដោយវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា និងវេទិកាសេដ្ឋកិច្ចពិភពលោក ក៏បានគូសបញ្ជាក់ផងដែរថា បញ្ហាធំបំផុតក្នុងការធ្វើពាណិជ្ជកម្ម គឺអំពើពុករលួយ។

ដើម្បីបង្កើនឱកាសប្រកួតប្រជែងរបស់វិស័យឯកជនកម្ពុជាជាមួយប្រទេសនាំចេញដទៃទៀត ក្នុងទីផ្សារពិភពលោក បញ្ហាអំពើពុករលួយចាំបាច់ត្រូវដោះស្រាយ និងបំបាត់ឱ្យបានជោគជ័យ។

ទោះបីជាមានសិក្សាជាច្រើន ដែលធ្វើឡើងដោយស្ថាប័ននានាស្តីពីអំពើពុករលួយក៏ដោយ ក៏គេពុំទាន់ឃើញមានទិន្នន័យជាក់លាក់ណាមួយស្តីពីអំពើពុករលួយក្នុងវិស័យឯកជននៅឡើយទេ។ ដូច្នេះហើយ ទើបវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា បានផ្តួចផ្តើមនូវការសិក្សាមួយ ស្តីពីការវាយតំលៃអំពើពុករលួយក្នុងវិស័យឯកជន ដែលទទួលបានការឧបត្ថម្ភពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីកិច្ចអភិវឌ្ឍន៍អន្តរជាតិ (USAID) អង្គការ Pact និងអង្គការ PADCO|AECOM។

ការសិក្សានេះមានគោលបំណងធំៗពីរ: ទីមួយ ការសិក្សានេះមានគោលបំណងផ្តល់ការយល់ដឹងដល់វិស័យឯកជន ជាពិសេស មីក្រូសហគ្រាស និងសហគ្រាសតូចនិងមធ្យម អំពីមូលហេតុ លក្ខណៈ និងទំហំនៃអំពើពុករលួយក្នុងប្រទេសកម្ពុជាតាមរយៈការបោះពុម្ពផ្សាយ និងការផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវក្នុងសិក្ខាសាលា ឬសន្និសីទនានា។ ទីពីរ ការសិក្សានេះមានគោលបំណងពង្រឹងសមត្ថភាពរបស់វិស័យឯកជន តាមរយៈការផ្តល់នូវអនុសាសន៍ជាក់ស្តែងមួយចំនួនអំពីការចូលរួមរបស់វិស័យឯកជន ក៏ដូចជារដ្ឋបាលសាធារណៈ និងអ្នកពាក់ព័ន្ធដទៃទៀត អាចចូលរួមក្នុងការប្រឆាំងអំពើពុករលួយបាន។

ដើម្បីធ្វើអោយលទ្ធផលនៃការសិក្សានេះទទួលបាននូវទំនុកចិត្តនិងភាពជឿជាក់ ការសិក្សានេះបានប្រើនូវវិធីសាស្ត្រស្រាវជ្រាវជាច្រើនបែប ដែលក្នុងនោះរួមមាន: ការសិក្សាអត្ថបទដែលពាក់ព័ន្ធ ការស្ទង់មតិបែបបរិមាណ និងការស្ទង់មតិបែបគុណភាព ប្រព័ន្ធម៉ូដែលសម្រាប់វាយតំលៃផលប៉ះពាល់នៃអំពើពុករលួយលើវិស័យឯកជន និងសេដ្ឋកិច្ចព្រមទាំងក្រុមប្រឹក្សាផ្តល់យោបល់សម្រាប់ការសិក្សាមួយក្រុមផង

ដែរ។ ការសិក្សានេះត្រូវបានធ្វើឡើងនៅ ខែមេសា ឆ្នាំ ២០០៦ ជាមួយនឹងសហគ្រាសចំនួន ១ ១០៧ (មីក្រូសហគ្រាសចំនួន ៨១៨ សហគ្រាសធុនតូច និងមធ្យម (SME) ចំនួន ២៤៤ និងសហគ្រាសធុនធំ ចំនួន ៤៥)[១] នៅក្នុងខេត្តក្រុងសំខាន់ៗទាំង ៩ នៃព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះទៀត ការសិក្សានេះបានរៀបចំ ក្រុមពិភាក្សា (FGD) ចំនួន ២០ ជាមួយមីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម និងបានធ្វើការ សម្ភាសជាមួយនឹងមន្ត្រីរាជការ នៅក្នុងខេត្តក្រុងទាំង ៩ នោះផងដែរ (សម្រាប់ព័ត៌មានពិស្តាពីវិធីសាស្ត្រ នៃការសិក្សានេះសូមអានឧបសម្ព័ន្ធ)។

ដើម្បីយល់អោយកាន់តែច្បាស់អំពីអំពើពុករលួយក្នុងវិស័យឯកជន ការដឹងជាសារវ័ន្តអំពីមូល-ហេតុ លក្ខណៈ និងវិសាលភាពនៃអំពើពុករលួយ ព្រមទាំងវិធីសាស្ត្រនៃការលុបបំបាត់អំពើពុករលួយ[២] ជាការចាំបាច់ណាស់។ របាយការណ៍នេះ នឹងផ្តល់នូវលទ្ធផលនៃការស្រាវជ្រាវអំពី - លក្ខណៈ និងមូលហេតុនៃអំពើពុករលួយក្នុងវិស័យឯកជន នៅក្នុងជំពូកទី ១ និង ទី ២ - វិសាលភាពនៃអំពើពុករលួយនៅក្នុងវិស័យឯកជន និងឥទ្ធិពលរបស់វាលើសេដ្ឋកិច្ចជាតិ នៅជំពូកទី ៣ - ព្រមទាំងអនុសាសន៍ និងយុទ្ធសាស្ត្រនានា ដើម្បីធ្វើការកាត់បន្ថយអំពើពុករលួយក្នុងវិស័យឯកជន ព្រមទាំងជំរុញការចូលរួមពីវិស័យឯកជនក្នុងការប្រឆាំងអំពើពុករលួយនេះ នៅជំពូកចុងក្រោយ។

---

[១] មីក្រូសហគ្រាសមាននិយោជិតតិចជាង ១០ នាក់ - សហគ្រាសធុនតូច និងមធ្យមមាននិយោជិតតិចពី ១០ - ១០០ នាក់ - សហគ្រាសធុនធំ មាននិយោជិតច្រើនជាង ១០០ នាក់

[២] ការិយាល័យថ្នាំញៀន និងឧក្រិដ្ឋកម្មរបស់សហប្រជាជាតិ - ការិយាល័យតំបន់សម្រាប់អាហ្វ្រិកខាងត្បូង: របាយការណ៍វាយតម្លៃអំពើពុករលួយរបស់ប្រទេសអាហ្វ្រិកខាងត្បូង ឆ្នាំ ២០០៣ ទំព័រ ៩៣

# ជំពូកទី ១

# លក្ខណៈនៃអំពើពុករលួយក្នុងវិស័យឯកជន

មុននឹងពិនិត្យមើលយ៉ាងពិស្តារទៅលើលក្ខណៈ និងមូលហេតុនៃអំពើពុករលួយក្នុងវិស័យឯកជន ជាចាំបាច់ យើងត្រូវយល់អំពីស្ថានភាពទូទៅនៃអំពើពុករលួយក្នុងប្រទេសកម្ពុជាជាមុនសិន។

ជាទូទៅ អំពើពុករលួយក្នុងប្រទេសកម្ពុជា ត្រូវបានគេមើលឃើញថាមានស្ទើរគ្រប់ទីកន្លែង និងមានលក្ខណៈរីកដុះដាលជាលំដាប់។ ស្ថាប័នរដ្ឋជាច្រើនត្រូវបានសំគាល់ថា ពុំមានភាពស្មោះត្រង់ និងមានការពាក់ព័ន្ធជាមួយនឹងអំពើពុករលួយ។ របាយការណ៍អង្កេត ដែលធ្វើដោយធនាគារពិភពលោក និងមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមមានភាពដូចគ្នាទៅនឹងអំណះអំណាងនេះ។ របាយការណ៍ធនាគារពិភពលោកស្តីពី *អភិបាលកិច្ច និងការវិភាគរកមូលហេតុនៃអំពើពុករលួយរបស់កម្ពុជា* បានបង្ហាញថា ស្ថាប័នសាធារណៈ ដែលត្រូវបានប្រជាពលរដ្ឋ សហគ្រិន និងមន្ត្រីសាធារណៈស្គាល់ថា គ្មានភាពស្មោះត្រង់ទាល់តែសោះនោះ គឺតុលាការ អាជ្ញាធរដែលប្រមូលប្រាក់ចំណូលសម្រាប់រដ្ឋ និងភ្នាក់ងារជាប់ពាក់ព័ន្ធក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ[៣]។ របាយការណ៍របស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមស្តីពី *អំពើពុករលួយ និងគ្រួសារកម្ពុជា* ក៏បានបង្ហាញដែរថា តុលាការ មន្ត្រីគយ និងរដ្ឋាករ ត្រូវបានគេស្គាល់ថា គឺជាស្ថាប័ន ដែលគ្មានភាពស្មោះត្រង់ទាល់តែសោះ[៤] ដែលវាយតម្លៃដោយមេគ្រួសារ។

មានលក្ខណៈប្រហាក់ប្រហែលនឹងស្ថាប័នទាំងពីរខាងលើដែរ ការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជន ដែលធ្វើឡើងដោយវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ក៏បានបង្ហាញលទ្ធផលដូចគ្នាដែរថា ស្ថាប័នរដ្ឋស្ទើរតែទាំងអស់មិនមានភាពស្មោះត្រង់។ ការណ៍ដែលថា ស្ថាប័នរដ្ឋស្ទើរតែទាំងអស់ពុំមានសុចរិតភាព ត្រូវបានស្តែងឡើងតាមរយៈការយល់ឃើញរបស់សហគ្រិន អំពីភាពស្មោះត្រង់ និងសុចរិតភាពរបស់ស្ថាប័នរដ្ឋចំនួន ១០ ។ ក្នុងចំណោមស្ថាប័នទាំង ១០ នេះ ស្ថាប័នស្ទើរតែទាំងអស់ លើកលែងតែស្ថាប័នដែលផ្តល់សេវាទឹក/លូទឹកចេញ គឺសុទ្ធតែត្រូវបានយល់ឃើញថាពុំមានភាពស្មោះត្រង់ និងខ្វះសុចរិតភាព និងត្រូវបានសហគ្រិនដាក់ពិន្ទុទាបជាងមធ្យម (រូប ១.១)។

---

[៣] សូមមើលធនាគារពិភពលោក រដ្ឋាភិបាលកម្ពុជា និងការវិភាគរកមូលហេតុនៃអំពើពុករលួយ: ភស្តុតាងបានពីប្រជាពលរដ្ឋ សហគ្រាស និងការស្ទង់មតិមន្ត្រីសាធារណៈ ឆ្នាំ ២០០០ ទំព័រ ១៣

[៤] មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម អំពើពុករលួយ និងគ្រួសារកម្ពុជា ឆ្នាំ ២០០៥ ទំព័រ ៤៥

**រូបភាព ១.១: ភាពស្មោះត្រង់ និងសុចរិតភាព របស់មន្ត្រីភ្នាក់ងារ ឬសេវាសាធារណៈ**

**(១ = មិនស្មោះត្រង់ទាល់តែសោះ ៧ = ស្មោះត្រង់បំផុត)**




**ប្រភព:** *វ.ស.ក. ការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា - មេសា ២០០៦*

សហគ្រិនជឿជាក់ថា ស្ថាប័នស្មោះត្រង់បំផុត គឺសេវាទឹក/លូទឹក ចំណែកឯស្ថាប័នដែលពុករលួយបំផុតនោះត្រូវបានគេស្គាល់ថាមាន ស្ថាប័នតុលាការ បន្ទាប់មកពន្ធដារ និងពន្ធគយ សេវាសុខភាពសាធារណៈ និងប៉ូលិស។

បន្ទាប់មកទៀត ជំពូកនេះនឹងផ្តល់ពីលទ្ធផលនៃការស្រាវជ្រាវអំពីការចុះត្រួតពិនិត្យសហគ្រាសដែលធ្វើឡើងដោយមន្ត្រីសាធារណៈ។ ផងដែរ ជំពូកនេះក៏ផ្តល់អោយឃើញពីការយល់ឃើញរបស់វិស័យឯកជន អំពីចំណាយក្រៅផ្លូវការ ជាពិសេសថា តើសហគ្រិនទាំងអស់បានដឹងជាមុន អំពីចំនួនទឹកប្រាក់ក្រៅផ្លូវការ ដែលពួកគាត់ត្រូវបង់ឬទេ? លើសពីនេះទៀត ជំពូកនេះក៏មានការពិភាក្សាពីបែបបទនៃចំណាយក្រៅផ្លូវការបានកើតមានឡើង និងប្រសិទ្ធភាពសេវាសាធារណៈបន្ទាប់ពីមានការបង់ប្រាក់ក្រៅផ្លូវការផងដែរ។

## ១.១. ចំនួននៃការត្រួតពិនិត្យលើសហគ្រាស

ការចុះត្រួតពិនិត្យសហគ្រាសពីសំណាក់មន្ត្រីរាជការ នៅតែជាបន្ទុកសម្រាប់សហគមន៍អាជីវកម្ម។ គោលនយោបាយចុះត្រួតពិនិត្យមានភាពមិនច្បាស់លាស់គ្រាន់គ្រាន់ ដើម្បីផ្តល់ឱ្យសហគ្រិនដឹងថា តើនឹងមានការចុះត្រួតពិនិត្យសហគ្រាសរបស់ខ្លួនពីសំណាក់គ្រប់ភ្នាក់ងារទាំងអស់ចំនួនប៉ុន្មានដង ក្នុងមួយឆ្នាំនោះទេ។ មីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យមនីមួយៗ ត្រូវបានត្រួតពិនិត្យជាច្រើនលើប្រតិបត្តិការអាជីវកម្មរបស់ពួកគេ ពីមួយថ្ងៃទៅមួយថ្ងៃ អាស្រ័យទៅតាមលក្ខណៈ ទីតាំង និងប្រភេទនៃអាជីវកម្ម។ ការត្រួតពិនិត្យមាន សារៈសំខាន់ណាស់ ក្នុងការលើកកម្ពស់ផលប្រយោជន៍សាធារណៈ និង

បទបញ្ញត្តិសង្គម ប៉ុន្តែពេលអនុវត្ត វាជាការលំបាកមួយក្នុងការធានាបានថា ការត្រួតពិនិត្យនោះ មិនមែនជាលេសទារប្រាក់ពីសំណាក់ភ្នាក់ងារសាធារណៈផ្សេងៗនោះទេ។ សហគ្រិនជាច្រើនបានអះអាងថា ពួកគាត់ត្រូវចំណាយឱ្យមន្ត្រីសាធារណៈ ដើម្បីសម្រួលដល់ដំណើរការការងារផ្សេងៗ។

### តារាង ១.១: ភាគរយនៃសហគ្រាសដែលត្រូវបានត្រួតពិនិត្យដោយអាជ្ញាធរផ្សេងៗ

| | មីក្រូសហគ្រាស | សហគ្រាសធុនតូច និងមធ្យម | សហគ្រាសធុនធំ |
|---|---|---|---|
| អាជ្ញាធរពន្ធដារ | ៩៣% | ៩៥% | ១០០% |
| ប៉ូលីស | ៣៧% | ៥០% | ៦០% |
| អាជ្ញាធរមូលដ្ឋាន | ២៩% | ៥៥% | ៦២% |
| មន្ត្រីអគ្គីភ័យ | ២៨% | ៥៨% | ៨៤% |
| បរិស្ថាន | ១៥% | ៥២% | ៥៨% |
| ការត្រួតពិនិត្យស្តង់ដា | ៣% | ២០% | ១៦% |
| សន្តិសុខសង្គម និងការងារ | ២% | ៣១% | ៨២% |

ប្រភព: *វ.ស.ក. ការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា - មេសា ២០០៦*

*ចំនួនអ្នកឆ្លើយតប: (សហគ្រាសធុនតូច = ៨១៨ សហគ្រាសធុនតូច និងមធ្យម = ២៤៤ សហគ្រាសធុនធំ = ៤៥)*

អធិការកិច្ចផ្នែកពន្ធដារមានភាពញឹកញាប់ជាងគេនៅគ្រប់ប្រភេទសហគ្រាសទាំងអស់។ ជាង ៩០ ភាគរយ នៃសហគ្រាសទាំងអស់ត្រូវបានចុះត្រួតពិនិត្យដោយអាជ្ញាធរពន្ធដារ ទាំងជាលក្ខណៈផ្លូវការ និងក្រៅផ្លូវការ។ ការដែលភ្នាក់ងារពន្ធដារបានចុះទៅពិនិត្យសហគ្រាសញឹកញាប់ជាងគេ ពីព្រោះថា មន្ត្រីពន្ធដារមានកាតព្វកិច្ចមួយត្រូវចុះទៅពិនិត្យសហគ្រាស ដើម្បីបញ្ជាក់ថា កាតព្វកិច្ចពន្ធដារដែលសហគ្រាសបានប្រកាសនៅនាយកដ្ឋានពន្ធដារពិតជាមានលក្ខណៈត្រឹមត្រូវ[៥]។

ជាទូទៅ សមាមាត្រនៃសហគ្រាសដែលត្រូវបានត្រួតពិនិត្យដោយភ្នាក់ងារផ្សេងៗ មានការកើនឡើងទៅតាមទំហំនៃសហគ្រាស។ នេះមានន័យថា នៅពេលដែលសហគ្រាសកាន់តែមានលក្ខណៈផ្លូវការ ពួកគាត់ត្រូវបំពេញកាតព្វកិច្ចអនុលោមកាន់តែច្រើន។ ម៉្យាងទៀត ការមានទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយភ្នាក់ងារពាក់ព័ន្ធគឺសំខាន់ណាស់សម្រាប់សហគ្រាសធំៗ ដើម្បីធានាដល់អាជីវកម្មរបស់ខ្លួន។

គួរកត់សំគាល់ថា មានត្រឹមតែ ២ ភាគរយនៃមីក្រូសហគ្រាសប៉ុណ្ណោះត្រូវបានត្រួតពិនិត្យលើផ្នែកការងារ និងសន្តិសុខសង្គម ប៉ុន្តែសហគ្រាសធុនតូច និងមធ្យម មាន ៣១ ភាគរយ និងសហគ្រាសធុនធំ

[៥] ផ្តល់ព័ត៌មានដោយប្រធាននាយកដ្ឋានពន្ធដារ ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០០៦

មានដល់ទៅ ៨២ ភាគរយ។ ភាពខុសគ្នាដែលមានទំហំធំនេះបង្ហាញថា មីក្រូសហគ្រាសតែងតែធ្វើសកម្មភាពក្រៅប្រព័ន្ធ។ នេះមានន័យថា មិនមានការយកចិត្តទុកដាក់ច្រើនទៅលើមីក្រូសហគ្រាសអំពីសន្តិសុខការងារ និងសង្គមទេ។ ចំណែកឯការត្រួតពិនិត្យស្តង់ដាវិញ សមាមាត្រនៃសហគ្រាសដែលត្រូវបានត្រួតពិនិត្យ មានការប្រែប្រួលពី ៣ ភាគរយ នៃមីក្រូសហគ្រាស ទៅ ២០ ភាគរយ នៃសហគ្រាសធុនតូច និងមធ្យម និង ១៦ ភាគរយ នៃសហគ្រាសធុនធំ។ ភ្នាក់ងារពាក់ព័ន្ធដទៃទៀត ដូចជានាយកដ្ឋាន ទេសចរណ៍ នាយកដ្ឋានពាណិជ្ជកម្ម នាយកដ្ឋានកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរអនាម័យ ... ក៏ជាប់ពាក់ព័ន្ធនឹងការត្រួតពិនិត្យសហគ្រាសផងដែរ។

ប៉ុន្តែប្រសិនបើមាននរណាម្នាក់តវ៉ាប្រឆាំងខ្លាំងជាមួយមន្ត្រី ដែលមកទារប្រាក់ទាំងនោះ មន្ត្រីទាំងនោះនឹងមិនមកទារលុយម្តងទៀតទេ។ ឧទាហរណ៍ អ្នកលក់ដូរម្នាក់នៅ ក្នុងទីក្រុងភ្នំពេញនិយាយថា *"ប្រសិនបើយើងនៅតែបន្តបង់ឱ្យពួកគេ ពួកគេនឹងមកទារប្រាក់ពីពួកយើងជាបន្តទៀត។ នរណាបង់ឱ្យពួកគេនឹងនៅតែបង់ឱ្យពួកគេបន្តទៀត។ សម្រាប់ខ្ញុំវិញ ខ្ញុំមិនបង់ឱ្យពួកគេទេ ខ្ញុំមិនបានធ្វើអ្វីខុសទេ។ អាជីវកម្មរបស់ខ្ញុំស្របច្បាប់។ ខ្ញុំមានអាជ្ញាប័ណ្ណពីអាជ្ញាធរមូលដ្ឋាន និងសាលាក្រុង ហើយខ្ញុំបង់ពន្ធជាប្រចាំ។ នៅពេលយើងនិយាយខ្លាំងជាមួយពួកគេ ពួកគេមិនហ៊ានមកទៀតទេ ហើយជាធម្មតា ខ្ញុំមិនជួបប្រទះនឹងបញ្ហានេះទេ"*។

ដូចគ្នាដែរ សហគ្រិនម្នាក់នៅក្នុងខេត្តបន្ទាយមានជ័យក៏បានបង្ហាញទស្សនៈមួយចំនួន អំពីការអនុវត្តដោយមិនយុត្តិធម៌នេះផងដែរ ដោយបាននិយាយថា *"ប្រសិនបើយើងនៅស្ងៀមស្ងាត់ហើយធ្វើជាអ្នកទន់ខ្សោយ ពួកគេនឹងមកយកប្រាក់ពីយើងជាបន្តទៀត។ ប៉ុន្តែ ប្រសិនបើយើងហ៊ានតវ៉ាប្រឆាំង និងនិយាយខ្លាំងតាមលក្ខណៈច្បាប់ ពួកគេមិនហ៊ានមកទៀតទេ"*។

ការត្រួតពិនិត្យ និងចំណាយក្រៅផ្លូវការដែលសុំដោយមន្ត្រីសាធារណៈ បង្កើតឱ្យមានបញ្ហាផ្នែកយេនឌ័រមួយចំនួនផងដែរ។ គ្រួសារដែលមានស្ត្រីសហគ្រិនដែលជាមេគ្រួសារ នោះជួបប្រទះនឹងការត្រួតពិនិត្យដ៏ច្រើនដោយមន្ត្រីសាធារណៈ ដែលពួកគេចាំបាច់ត្រូវបង់ចំណាយក្រៅផ្លូវការបន្ថែមទៀត ដើម្បីរក្សាទំនាក់ទំនងល្អជាមួយអាជ្ញាធរ។ មូលហេតុសាមញ្ញដែលនាំអោយមានការបង់ប្រាក់ច្រើនជាងគឺថា ស្ត្រីជាសហគ្រិន និងជាមេគ្រួសារ ជាទូទៅ មានកំរិតសិក្សានិងការយល់ដឹងទាប ព្រមទាំងពុំសូវទទួលបាននូវព័ត៌មានទាក់ទងនឹងច្បាប់ និងបទបញ្ញាផ្សេងៗស្តីពីអាជីវកម្មឡើយ។ សហគ្រិនជាស្ត្រីម្នាក់នៅក្នុងខេត្តកណ្តាល បានលើកឡើងថា *"នៅពេលខ្ញុំរស់នៅម្នាក់ឯងជាស្ត្រីមេម៉ាយនោះ មន្ត្រីសាធារណៈផ្សេងៗជាច្រើនតែងតែចូលមកកន្លែងខ្ញុំជាប្រចាំដើម្បីសុំប្រាក់ពីខ្ញុំ ប៉ុន្តែបន្ទាប់ពីខ្ញុំបានរៀបការរួចមកពួកគេមិនហ៊ានចូលមកទារលុយទៀតទេ"*។ រឿងរ៉ាវនេះបានកើតមានឡើងពីព្រោះថា បន្ទាប់ពីគាត់បានរៀបការមក គឺប្តីរបស់គាត់ជាអ្នកទទួលខុសត្រូវក្នុងអាជីវកម្ម ក៏ដូចជាការដោះស្រាយបញ្ហាផ្សេងៗជាមួយនឹងមន្ត្រី ដែលចុះមកទារប្រាក់ផងដែរ។

នៅក្នុងបរិបទនេះ ដោយសារស្ត្រី ជាពិសេសគ្រួសារដែលមានស្ត្រីជាមេគ្រួសារ ដែលខ្វះការអប់រំ ជំនាញសហគ្រិន ការតវ៉ា និងការចរចារ បើធៀបនឹងបុរសនោះ ស្ត្រីប្រឈមមុខនឹងការត្រួតពិនិត្យ និង ការបង់ចំណាយក្រៅផ្លូវការកាន់តែច្រើនជាង។

បញ្ហាយេនឌ័រដ៏សំខាន់មួយទៀត ដែលទាក់ទងនឹងការត្រួតពិនិត្យដោយមន្ត្រីសាធារណៈនោះផង ដែរគឺថា ក្រុមស្ត្រីអាចរងគ្រោះនឹងការប្រមាថជាពាក្យសំដី និងផ្លូវភេទដោយមន្ត្រីសាធារណៈទាំងនោះ ដែលភាគច្រើនជាបុរស (យោងតាមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល (CAR) បង្ហាញថា មានតែ ៣១ ភាគរយ នៃមន្ត្រី ប៉ុណ្ណោះ ជាស្ត្រី[៦])។ ទស្សនៈនេះត្រូវបានយល់ព្រមពីសំណាក់អ្នកចូលរួមពិភាក្សានៅក្នុង កិច្ចពិភាក្សាក្នុងខេត្តកំពត ដោយបានសម្តែងឡើងថា *"ជួនកាលនៅពេលដែលជួបដោះស្រាយជាមួយមន្ត្រី សាធារណៈ ពួកគេតែងតែនិយាយចែចង់កំប្លែងលេងជាមួយម្ចាស់សហគ្រាសស្ត្រី និងពេលខ្លះ មន្ត្រីទាំង នោះថែមទាំងបានប៉ះខ្លួនស្ត្រីទាំងនោះទៀតផង"*។

## ១.២. ការដឹងជាមុននៃការចំណាយក្រៅផ្លូវការ

មីក្រូសហគ្រាសភាគច្រើនយល់ដឹងបានជាមុននូវបរិមាណនៃការបង់ចំណាយក្រៅផ្លូវការ បើធៀប នឹងសហគ្រាសធុនតូច និងមធ្យម និងសហគ្រាសធំៗ។ នេះគឺដោយសារតែ ការបង់ចំណាយក្រៅផ្លូវការទៅ មន្ត្រីសាធារណៈ គឺជាផ្នែកមួយជីវភាពប្រចាំថ្ងៃរបស់សហគ្រិនតូចតាច។ កំរិតនេះមិនមានភាពខុសគ្នាច្រើន ទេ រវាងទីក្រុងភ្នំពេញ និងខេត្តផ្សេងៗ (រូបភាព ១.២)។

**រូបភាព ១.២: ការដឹងជាមុននៃការចំណាយក្រៅផ្លូវការ**

**(១= មិនធ្លាប់ដឹង ៧= ជានិច្ចកាលដឹងមុន)**




**ប្រភព:** *វ.ស.ក. ការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា - មេសា ២០០៦*

---

៦ UNIFEM, WB, ADB, UNDP និង DFID/UK: ចំណែកស្មើភាពសម្រាប់ស្ត្រី : ការវាយតម្លៃយេនឌ័រនៅកម្ពុជា ២០០៤ ទំព័រ ១៣០

## ១.៣. ប្រសិទ្ធភាពនៃសេវាកម្មសាធារណៈ និងការចំណាយក្រៅផ្លូវការ

គ្រប់សហគ្រិនទាំងអស់ត្រូវបានសាកសួរអំពីកំរិតនៃការពេញចិត្ត និងការបំរើសេវារបស់មន្ត្រីសា-ធារណៈ បន្ទាប់ពីបានការបង់ចំណាយក្រៅផ្លូវការ ។ សហគ្រិនភាគច្រើនបានយល់ព្រមថា ពួកគាត់ទទួលបានសេវាប្រកបដោយប្រសិទ្ធភាពពីមន្ត្រីសាធារណៈ នៅពេលដែលបង់ប្រាក់ក្រៅផ្លូវការរួចហើយ ។ (សូមមើលរូបភាព ១.៣) ។

លទ្ធផលនេះ ហាក់ដូចជាស្របតាមទស្សនៈដែលបានអះអាងដោយសហគ្រិនតូចតាចថា *"នៅកម្ពុជា ប្រសិនបើអ្នកមានលុយ អ្នកអាចធ្វើ ឬទទួលបានអ្វីៗក៏បាន"*។ ការឆ្លើយតបរបស់មីក្រូសហគ្រាសមានភាពវិជ្ជមានជាងសហគ្រាសធុនតូច និងមធ្យម និងសហគ្រាសធុនធំ ។ នេះគឺដោយសារតែ មីក្រូសហ-គ្រាស ជាធម្មតា មិនសូវត្រូវការសេវាពីមន្ត្រីសាធារណៈ ដូចបង្ហាញនៅក្នុងរូបភាព ២.១ ដែលបានបង្ហាញពីក្រុមមន្ត្រីសាធារណៈ ដែលចូលមកសុំប្រាក់ក្រៅផ្លូវការពីពួកគេ ។

**រូបភាព ១.៣: ប្រសិទ្ធភាពនៃសេវាសាធារណៈ និងការបង់ចំណាយក្រៅផ្លូវការ**

**(១=មិនធ្លាប់ដឹង ៧=ជានិច្ចកាលដឹង)**




ប្រភព: *វ.ស.ក. ការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា - មេសា ២០០៦*

## ១.៤. តើការបង់ចំណាយក្រៅផ្លូវការកើតមានយ៉ាងដូចម្តេច?

សហគ្រិនក៏ត្រូវបានសាកសួរផងដែរ ថាតើការបង់ចំណាយក្រៅផ្លូវការកើតមានដោយរបៀបណា? ជាទូទៅ មន្ត្រីសាធារណៈចូលមកសហគ្រាសរបស់ពួកគាត់ ហើយទាររកប្រាក់ជាសំណូក។ ប្រហែល ៩0 ភាគរយ នៃមីក្រូសហគ្រាសបានឆ្លើយថា មន្ត្រីសាធារណៈចូលមកសហគ្រាសរបស់ពួកគាត់ដោយ ផ្ទាល់ដើម្បីទារប្រាក់ក្រៅផ្លូវការ ។ ការបង់ជាសំណូករបស់មីក្រូសហគ្រាសឱ្យទៅមន្ត្រីសាធារណៈ មិនសូវជា

ញឹកញាប់ទេ ហើយក៏មិនប្រើអ្នករត់ការ[៧] ឱ្យជួយសម្រួលដល់ដំណើរការកិច្ចការផ្សេងៗញឹកញាប់នោះដែរ (រូបភាព ១.៤) ។

### រូបភាព ១.៤: បែបបទនៃចំណាយក្រៅផ្លូវការរបស់មីក្រូសហគ្រាស




**ប្រភព:** *វ.ស.ក. ការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា - មេសា ២០០៦*

ស្រដៀងគ្នានឹងមីក្រូសហគ្រាសដែរ សហគ្រាសធុនតូច និងមធ្យម ជាញឹកញាប់ បង់ចំណាយក្រៅផ្លូវការឱ្យទៅមន្ត្រីសាធារណៈនៅពេលដែលពួកគាត់ចូលមកសហគ្រាស។ ៧៣ ភាគរយ នៃសហគ្រាសធុនតូច និងមធ្យមឆ្លើយថា មន្ត្រីសាធារណៈចូលមកដល់សហគ្រាសរបស់ពួកគាត់ផ្ទាល់ ដើម្បីទារប្រាក់ក្រៅផ្លូវការ។ ទោះបីជាយ៉ាងណា សហគ្រាសធុនតូច និងមធ្យម ក៏ត្រូវការប្រើអ្នករត់ការច្រើនដែរ (៤១ ភាគរយ) ដើម្បីធ្វើការជាមួយមន្ត្រីសាធារណៈទាំងនោះជំនួសខ្លួន។ ម្យ៉ាងទៀតមានកិច្ចការខ្លះ (២៩ ភាគរយ) សហគ្រាសធុនតូច និងមធ្យមត្រូវទាក់ទងជាមួយមន្ត្រីដោយផ្ទាល់ផងដែរ ដើម្បីអោយមន្ត្រីធ្វើការងារឱ្យខ្លួន (រូបភាព ១.៥) ។

---

[៧] ពាក្យ "អ្នករត់ការ" ដែលប្រើនៅក្នុងអត្ថបទនេះ សំដៅលើភ្នាក់ងារដែលត្រូវបានជួលឱ្យបំពេញការងារសហគ្រាសក្នុងការរត់ការផ្សេងៗ។ អ្នករត់ការអាចជាមេធាវី អង្គភាពឯកជន ឬមន្ត្រីសាធារណៈ ។ល។ ដែលអាចធានាថា នឹងអាចទទួលបានការអនុញ្ញាតិដ៏ត្រឹមត្រូវ ឬ សេចក្តីសម្រេចផ្សេងៗ សម្រាប់ដំណើរការផ្សេងៗ ឬ ផ្តល់នូវសេវាកម្មវិជ្ជាជីវៈផ្សេងៗ ។

## រូបភាព ១.៥: បែបបទនៃចំណាយក្រៅផ្លូវការរបស់សហគ្រាសធុនតូច និងមធ្យម




**ប្រភព:** *វ.ស.ក. ការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា - មេសា ២០០៦*

ដូចមីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យមដែរ ៧៣ ភាគរយ នៃសហគ្រាសធំៗ បាន ឆ្លើយថា មន្ត្រីសាធារណៈជាច្រើនបានចូលទៅសហគ្រាស ដើម្បីទារប្រាក់ក្រៅផ្លូវការ។ គួរកត់សំគាល់ថា សហគ្រាសធំៗចាំបាច់ត្រូវប្រើអ្នករត់ការ (៦៤ ភាគរយ) ដើម្បីទទួលបានសេវាសាធារណៈ។ សហគ្រាស ធំៗ ប្រហែល ៦៩ ភាគរយ ក៏បានទាក់ទងជាមួយមន្ត្រីសាធារណៈផងដែរ ដើម្បីឱ្យសេវាសាធារណៈរបស់ ខ្លួនដំណើរការល្អ។ (សូមមើលរូប ១.៦)

## រូបភាព ១.៦: បែបបទនៃចំណាយក្រៅផ្លូវការរបស់សហគ្រាសធុនធំ




**ប្រភព:** *វ.ស.ក. ការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា - មេសា ២០០៦*

ដោយសារតែការិយាធិបតេយ្យច្រើនជាមួយនឹងអាជីវកម្មនៃសហគ្រាសធុនតូច មធ្យម និង ធុនធំ ធៀបនឹងមីក្រូសហគ្រាស ការប្រើអ្នករត់ការ និងការទាក់ទងដោយផ្ទាល់ជាមួយមន្ត្រីសាធារណៈ ដោយ សហគ្រាសទាំងបីប្រភេទនេះ កើតមានញឹកញាប់ជាង។ សហគ្រាសធំៗចាំបាច់ ត្រូវប្រើអ្នករត់ការច្រើន ជាងគេ ដើម្បីឱ្យជួយសម្រួលដល់ការងាររបស់ពួកគាត់ ដោយសារតែការិយាធិបតេយ្យមានភាពស៊ាំញាំ ដែលពួកគាត់ត្រូវតែបំពេញក្នុងនាមជាសហគ្រាសផ្លូវការ។

ជារួមមក សហគ្រាសដែលមានលក្ខណៈកាន់តែផ្លូវការ ការប្រើអ្នករត់ការកាន់តែញឹកញាប់ ដោយ សារតែសហគ្រាសផ្លូវការទាំងនោះជួបប្រទះនឹងការិយាធិបតេយ្យជាច្រើន។ សហគ្រាសដែលមានលក្ខណៈ ផ្លូវការ ចាំបាច់ត្រូវប្រើអ្នករត់ការ ដែលដឹងពីរបៀបរបបនៃការរត់ឯកសារជាមួយរដ្ឋបាលសាធារណៈដោយ សារសហគ្រាស ចាំបាច់ត្រូវធ្វើការងារច្រើនក្នុងការបំពេញតាមបែបបទផ្សេងៗ ហើយសហគ្រាសភាគ ច្រើន មិនដឹងពីនីតិវិធីដែលតម្រូវដោយផ្នែករដ្ឋបាសាធារណៈឡើយ។ សហគ្រាសផ្លូវការជាច្រើនទំនងជាទាក់ ទងដោយផ្ទាល់ជាមួយមន្ត្រីសាធារណៈដើម្បីឱ្យធ្វើការងារឱ្យខ្លួន។

# ជំពូកទី ២

# មូលហេតុនៃអំពើពុករលួយក្នុងវិស័យឯកជន

ដើម្បីអោយដឹងច្បាស់ពីមូលហេតុនៃអំពើពុករលួយក្នុងវិស័យឯកជន ការសិក្សាស្ទង់មតិនេះបានផ្អែកលើការយល់ឃើញរបស់តួអង្គពីសំខាន់ៗគឺ អ្នកទទួលសំណូក និងអ្នកផ្តល់សំណូកៈ ពោលគឺ ការយល់ឃើញរបស់វិស័យឯកជនដែលជាអ្នកផ្តល់ប្រាក់ក្រៅផ្លូវការ និងការយល់ឃើញរបស់មន្ត្រីសាធារណៈដែលអ្នកទទួលប្រាក់ក្រៅផ្លូវការ អំពីមូលហេតុនៃអំពើពុករលួយនេះមកធ្វើការឆ្លុះបញ្ចាំង។

## ២.១. មូលហេតុក្នុងការបង់ចំណាយក្រៅផ្លូវការ

ការឆ្លើយនឹងសំណួរ ថាតើហេតុអ្វីបានជាពួកគេចាំបាច់ត្រូវបង់ចំណាយក្រៅផ្លូវការទៅឱ្យមន្ត្រីសាធារណៈ? មីក្រូសហគ្រាសភាគច្រើន (៧៧ ភាគរយ) បានឆ្លើយថា ពួកគាត់បង់ចំណាយក្រៅផ្លូវការ ដើម្បីរក្សាទំនាក់ទំនងល្អសម្រាប់អាជីវកម្មរបស់ពួកគាត់ ប៉ុន្តែ មានតែ ៥៤ ភាគរយ នៃសហគ្រាសធុនតូច និងមធ្យម និង ៤៧ ភាគរយ នៃសហគ្រាសធុនធំប៉ុណ្ណោះឆ្លើយថា ពួកគាត់បង់ចំណាយក្រៅផ្លូវការ ដោយសារហេតុផលនេះ (សូមមើលរូបភាព ២.១)។ នៅពេលធ្វើការសម្ភាសន៍ជាមួយមីក្រូសហគ្រាស សហគ្រិនភាគច្រើនបានលើកឡើងថា *"ប្រសិនបើយើងមិនបង់ឱ្យគេទេ នៅពេលដែលយើងសុំឱ្យពួកគេជួយធ្វើការងារអ្វីមួយនោះ ពួកគេនឹងមិនជួយយើងទេ។ វាជាការយល់គ្នាទៅវិញទៅមក"*។

### រូបភាព ២.១: មូលហេតុនៃការបង់ចំណាយក្រៅផ្លូវការរបស់មីក្រូសហគ្រាស




**ប្រភព:** *វ.ស.ក. ការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា - មេសា ២០០៦*

ផ្ទុយពីមីក្រូសហគ្រាស មូលហេតុ ភាគច្រើន ដែលសហគ្រាសធុនតូច និងមធ្យមដែលបង់ចំណាយក្រៅផ្លូវការទៅឱ្យមន្ត្រីសាធារណៈគឺដើម្បីទទួលបានសេវាសាធារណៈ[៨] (៥៦ ភាគរយ) និងដើម្បីរក្សាទំនាក់ទំនងល្អជាមួយមន្ត្រីទាំងនោះ (៥៤ ភាគរយ) (សូមមើលរូបភាព ២.២) ។

**រូបភាព ២.២: មូលហេតុនៃការបង់ចំណាយក្រៅផ្លូវការរបស់ហគ្រាសធុនតូច និងមធ្យម**




**ប្រភព:** *វ.ស.ក. ការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា - មេសា ២០០៦*

សហគ្រាសធុនធំមានការព្រួយបារម្ភអំពីលទ្ធផល ដែលទទួលបានពីមន្ត្រីសាធារណៈជាងការបង្ហាញពីអំណរគុណ ឬទំនាក់ទំនងល្អ ឬគំរាមកំហែងដោយមន្ត្រីសាធារណៈ ដោយសារតែពួកគាត់ត្រូវការសេវាកម្មពីមន្ត្រីសាធារណៈទាំងនោះជាចាំបាច់ ។ លទ្ធផលនៃការស្ទង់មតិបង្ហាញថា សហគ្រាសធុនធំ ភាគច្រើន (៨៧ ភាគរយ) បង់ចំណាយក្រៅផ្លូវការទៅឱ្យមន្ត្រីសាធារណៈ ដើម្បីឱ្យការងាររបស់ខ្លួនបានសម្រេច ។ ទោះជាយ៉ាងណា "ការរក្សានូវទំនាក់ទំនងល្អសម្រាប់អាជីវកម្ម" ក៏ជាហេតុផលទីពីរនៃការបង់ចំណាយក្រៅផ្លូវការរបស់ហគ្រាសធុនធំផងដែរ (សូមមើលរូបភាព ២.៣) ។

[៨] សេវាកម្មសាធារណៈនេះរាប់បញ្ចូលទាំងសេវានៃការផ្តល់អាជ្ញាប័ណ្ណ ការត្រួតពិនិត្យ និងការចុះបញ្ជី ដែលផ្តល់ដោយមន្ត្រីសាធារណៈ

រូបភាព ២.៣: មូលហេតុនៃការបង់ចំណាយក្រៅផ្លូវការរបស់សហគ្រាសធុនធំ




**ប្រភព:** *វ.ស.ក. ការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា - មេសា ២០០៦*

យើងអាចសន្និដ្ឋានបានថា ចំពោះការបង់ចំណាយក្រៅផ្លូវការទៅឱ្យមន្ត្រីសាធារណៈ សហគ្រាសក្នុងប្រព័ន្ធផ្តោតសំខាន់ទៅលើសមិទ្ធផលនៃការផ្តល់សេវាសាធារណៈនោះ។ ប៉ុន្តែ ការរក្សាទំនាក់ទំនងល្អជាមួយមន្ត្រីសាធារណៈក៏មានសារៈសំខាន់ណាស់ដែរ សម្រាប់រាល់សហគ្រាសទាំងអស់ដែលធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជា។ ជាពិសេស មីក្រូសហគ្រាសដែលជាញឹកញាប់មានបញ្ហាត្រូវដោះស្រាយជាមួយមន្ត្រីនោះ ចាំបាច់ត្រូវតែរក្សាទំនាក់ទំនងល្អជាមួយមន្ត្រីទាំងនោះ តាមរយៈការបង់ចំណាយក្រៅផ្លូវការ។

## ២.២. មូលហេតុនៃការទារចំណាយក្រៅផ្លូវការ

គ្រប់សហគ្រិនទាំងអស់ត្រូវបានស្នើសុំឱ្យផ្តល់កម្រិតនៃមូលហេតុ ដែលបណ្តាលឱ្យមានអំពើពុករលួយនៅក្នុងវិស័យឯកជន។ សហគ្រិនស្ទើរតែទាំងអស់យល់ដឹងអំពីមូលហេតុនៃអំពើពុករលួយនៅក្នុងវិស័យឯកជន។ សហគ្រិនបានផ្តល់នូវគំនិតយោបល់ផ្សេងៗ អំពីមូលហេតុដ៏ចំបងនៃអំពើពុករលួយនៅក្នុងវិស័យឯកជននេះ។

មីក្រូសហគ្រាសយល់ថា កង្វះនូវប្រព័ន្ធតុលាការដែលឯករាជ្យ និងមានប្រសិទ្ធភាព គឺជាមូលហេតុសំខាន់បំផុតនៃអំពើពុករលួយ បន្ទាប់មកគឺ កង្វះនូវយន្តការប្រឆាំងអំពើពុករលួយដ៏មានប្រសិទ្ធភាពប្រាក់ខែទាបរបស់មន្ត្រីសាធារណៈ និងការអនុវត្តច្បាប់នៅខ្សោយ (សូមមើលរូបភាព ២.៤)។

### រូបភាព ២.៤: ការយល់ឃើញពីមូលហេតុនៃការទារចំណាយក្រៅផ្លូវការរបស់មីក្រូសហគ្រាស
### (១=មិនមែនជាមូលហេតុ ៧=ជាមូលហេតុដ៏ចំបងបំផុត)




**ប្រភព:** *វ.ស.ក. ការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា - មេសា ២០០៦*

សហគ្រាសធុនតូច និងមធ្យមយល់ថា: ប្រាក់បៀវត្សរ៍ទាបរបស់មន្ត្រីសាធារណៈ បន្ទាប់មក គឺ វប្បធម៌នៃអំពើពុករលួយ កង្វះនូវប្រព័ន្ធតុលាការឯករាជ្យនិងមានប្រសិទ្ធភាព និងកង្វះនូវយន្តការប្រឆាំងអំពើពុករលួយដ៏មានប្រសិទ្ធភាព គឺជាមូលហេតុដ៏ចំបងនៃអំពើពុករលួយ (រូបភាព ២.៥) ។

### រូបភាព ២.៥: ការយល់ឃើញពីមូលហេតុនៃការទារចំណាយក្រៅផ្លូវការរបស់
### សហគ្រាសធុនតូច និងមធ្យម (១=មិនមែនជាមូលហេតុ ៧=មូលហេតុដ៏ចំបងបំផុត)




**ប្រភព:** *វ.ស.ក. ការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា - មេសា ២០០៦*

សហគ្រាសធុនធំជឿជាក់ថា មូលហេតុដ៏សំខាន់នៃអំពើពុករលួយស្ថិតក្នុងលំដាប់ដូចតទៅ: កង្វះនូវយន្តការប្រឆាំងអំពើពុករលួយដ៏មានប្រសិទ្ធភាព ប្រាក់ខែទាបរបស់មន្ត្រីសាធារណៈ ការអនុវត្តច្បាប់នៅទន់ខ្សោយ និងវប្បធម៌នៃអំពើពុករលួយ ។

**រូបភាព ២.៦: ការយល់ឃើញពីមូលហេតុនៃការទារចំណាយក្រៅផ្លូវការរបស់សហគ្រាសធុនធំ**
**(១=មិនមែនជាមូលហេតុ ៧=ជាមូលហេតុដ៏ចំបងបំផុត)**




**ប្រភព:** *វ.ស.ក. ការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា - មេសា ២០០៦*

បើទោះជាមានលំដាប់ខុសគ្នានៃមូលហេតុចំបងៗនៃអំពើពុករលួយក្តី ក៏គម្លាតទាំងនោះមិនជាសូវខុសគ្នាប៉ុន្មានឡើយ ។ ដូច្នេះ យើងអាចសន្និដ្ឋានបានថា ក្នុងចំណោមមូលហេតុនៃអំពើពុករលួយក្នុងវិស័យឯកជនខាងលើនេះ (កម្រិតលើសពី ៤) មូលហេតុចំបងនៃអំពើពុករលួយក្នុងវិស័យឯកជនមាន ប្រាក់ខែទាបរបស់មន្ត្រីសាធារណៈ ប្រព័ន្ធតុលាការមិនឯករាជ្យ និងគ្មានប្រសិទ្ធភាព យន្តការប្រឆាំងអំពើពុករលួយគ្មានប្រសិទ្ធភាព វប្បធម៌នៃអំពើពុករលួយ និងការអនុវត្តច្បាប់នៅទន់ខ្សោយ ។

ចម្លើយជារួមមួយរបស់អ្នកចូលរួមក្នុងក្រុមពិភាក្សាមីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យមគឺថា ប្រាក់បៀវត្សរ៍ទាបរបស់មន្ត្រីសាធារណៈជាមូលហេតុដ៏ចំបង។ សហគ្រិនមីក្រូសហគ្រាសក្នុងខេត្តកំពង់ចាមនិយាយថា *"មន្ត្រីមានប្រាក់ខែទាប ដូច្នេះពួកគេត្រូវតែរកកំរៃក្រៅផ្លូវការដើម្បីទ្រទ្រង់ជីវភាពរបស់ខ្លួន"*។ មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យមក៏បានបង្ហាញទស្សនៈដូចគ្នាដែរថា មន្ត្រីសាធារណៈខ្វះខាតក្នុងការទ្រទ្រង់ការចំណាយប្រចាំថ្ងៃរបស់ពួកគេ ដូច្នេះពួកគេគ្មានជម្រើសអ្វីក្រៅពី ពុករលួយនោះទេ។

ក្រៅពីប្រាក់បៀវត្សរ៍របស់មន្ត្រីសាធារណៈ មូលហេតុនៃអំពើពុករលួយនៅក្នុងវិស័យឯកជនផ្សេងៗទៀតមាន: វប្បធម៌នៃអំពើពុករលួយដែលការបង់ចំណាយក្រៅផ្លូវការបានក្លាយទៅជាទំលាប់អាក្រក់មួយ

នៅក្នុងសង្គម ការអនុវត្តច្បាប់នៅខ្សោយ បក្សពួកនិយម និងប្រព័ន្ធនៃភាពជាចៅហ្វាយដែលមន្ត្រីថ្នាក់ទាបត្រូវផ្តល់ប្រាក់ឱ្យទៅចៅហ្វាយដើម្បីអាចរក្សាតំណែងរបស់ខ្លួន។ អ្នកឆ្លើយតបបានប្រៀបធៀបស្ថានភាពអំពើពុករលួយទៅនឹងសុភាសិតខ្មែរថា *"ទន្សោងគោព្រៃរកស៊ីជើងភ្នំ តូចស៊ីដោយតូច ធំស៊ីដោយធំ រកស៊ីជើងភ្នំ ផឹកទឹកដងអូរ"* ដែលត្រូវបានសំដៅដល់ប្រព័ន្ធនៃភាពជាចៅហ្វាយនេះ។

មន្ត្រីសាធារណៈស្ទើរតែទាំងអស់ ដែលត្រូវបានធ្វើសម្ភាសន៍យល់ស្របលើមូលហេតុ ដែលបានលើកឡើងទាំងអស់នេះ។ ប៉ុន្តែ មន្ត្រីសាធារណៈបានយល់ឃើញថា ប្រាក់បៀវត្សរ៍ទាប គឺជាមូលហេតុដ៏ចំបងដែលធ្វើឱ្យពួកគាត់ប្រព្រឹត្តិអំពើពុករលួយ។ មន្ត្រីម្នាក់និយាយថា *"នៅពេលកំពុងធ្វើដំណើរ បើយើងស្រេកទឹក យើងត្រូវតែផឹកទឹក បើទោះជាទឹកនោះល្អ ឬមិនល្អក្តី។ ប៉ុន្តែ ប្រសិនបើយើងមិនស្រេកទេ យើងនឹងមិនផឹកទេ"*។

ទន្ទឹមពេលដែលមន្ត្រីរាជការទទួលកំហុសរបស់ពួកគេនៅក្នុងការទទួលសំណូកពីសហគ្រិន ពួកគេមានពេលខ្លះលើកឡើងថាមានការឃុបឃិតគ្នារវាងវិស័យឯកជន និងមន្ត្រីរាជការ ដោយនិយាយថា *"ទះដៃម្ខាងវាមិនឮទេ"* ។ ការឃុបខិតគ្នានេះ ជាញឹកញាប់អាចកើតមាននៅពេលដែលវិស័យឯកជនបានប្រព្រឹត្តកំហុស ឬក៏ធ្វើសកម្មភាពដែលជាប់ទាក់ទងទៅនឹងអំពើខុសច្បាប់រឺក្រៅផ្លូវការ ឬមិនបានអនុវត្តតាមបទបញ្ញត្តិ ឬច្បាប់ ការគេចពន្ធ...។ល។ នៅក្នុងករណីនេះ ឈ្មួញចាំបាច់ត្រូវចំណាយក្រៅផ្លូវការទៅអោយមន្ត្រីរាជការដើម្បីពួកគាត់ជួយសម្រួល។

លើសពីនេះទៅទៀត ការជាប់ពាក់ព័ន្ធនឹងច្បាប់ និងបទបញ្ញត្តិនានា ត្រូវបានចាត់ទុកថាជាមូលហេតុសម្រាប់ឱ្យមានការចំណាយក្រៅផ្លូវការ។ ជាធម្មតា ឈ្មួញមិនមានពេលគ្រប់គ្រាន់សម្រាប់បែបបទការិយាធិបតេយ្យដែលស្មុគ្រស្មាញនោះទេ។ ហើយឈ្មួញខ្លះ មានបំណងចង់ជៀសវាងនូវការកំហិតពេលវេលានៃដំណើរការតាមបែបផ្លូវការដែលមាន ឧទាហរណ៍អាជ្ញាប័ណ្ណអាជីវកម្ម ដូចនេះពួកគេស្វះស្វែងរកជំនួយពីមន្ត្រីរាជការ។ មន្ត្រីរាជការជាច្រើនទទួលស្គាល់នូវការជួយឈ្មួញ ដែលជាថ្នូរនឹងប្រាក់ជាទូទៅសម្រាប់ថ្លៃសាំង ទឹកតែ អាហារពេលព្រឹក ,,, ប៉ុណ្ណោះ។

# ជំពូកទី ៣
# វិសាលភាពនៃអំពើពុករលួយ និងផលប៉ះពាល់

ការត្អូញត្អែរជាច្រើនអំពីអំពើពុករលួយមានទូទាំងប្រទេស ពិសេសអំពើពុករលួយក្នុងវិស័យឯកជន។ ជំពូកនេះនឹងធ្វើការបកស្រាយនឹងបង្ហាញពីវិសាលភាពនៃការចំណាយក្រៅផ្លូវការ និងផ្តល់នូវពត៌មានអំពីចំនួនទឹកប្រាក់ដែលបានបាត់ទៅលើអំពើពុករលួយ ដោយផ្អែកលើប្រព័ន្ធម៉ូដែលរបស់វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា។

## ៣.១. ភាពធ្ងន់ធ្ងរនៃការបង់ចំណាយក្រៅផ្លូវការ

គ្រប់សហគ្រាសទាំងអស់ ត្រូវបានស្នើសុំអោយដាក់ចំណាត់ថ្នាក់លើភាពធ្ងន់ធ្ងរនៃការបង់ចំណាយក្រៅផ្លូវការនៅកម្ពុជា[៩]។ និយមន័យនៃភាពធ្ងន់ធ្ងរនៃការបង់ចំណាយក្រៅផ្លូវការត្រូវបានគេកំណត់ថា ជាកម្រិតចំណាយក្រៅផ្លូវការខ្ពស់ៗ ដែលប្រជាពលរដ្ឋទូទៅ ចាំបាច់ ត្រូវបង់ទៅឱ្យមន្ត្រីរាជការ។ នៅពេលឆ្លើយនឹងសំណួរនេះ អ្នកតបសម្ភាសន៍នីមួយៗ ជារឿយៗបានកំណត់ "ភាពធ្ងន់ធ្ងរ" នេះ ដោយផ្អែកលើលទ្ធភាពក្នុងការបង់ចំណាយក្រៅផ្លូវការនេះ និងចំណូលរបស់គេ។ សហគ្រាសទាំងបីប្រភេទមានទស្សនៈខុសៗគ្នាលើបញ្ហានេះ។ មីក្រូសហគ្រាស និងសហគ្រាសធុនធំ បានឆ្លើយថា ការបង់ចំណាយក្រៅផ្លូវការក្នុងប្រទេសកម្ពុជាមានកម្រិតខ្ពស់ រីឯសហគ្រាសធុនតូច និងមធ្យមមើលឃើញថា មិនមានភាពធ្ងន់ធ្ងរប៉ុន្មានទេ។ ទោះបីជាយ៉ាងណាក៏ដោយ អ្វីដែលអ្នកតបសម្ភាសន៍ទូទៅយល់ឃើញ គឺការបង់ ចំណាយក្រៅផ្លូវការក្នុងវិស័យឯកជនរបស់ប្រទេសកម្ពុជាគឺមានកម្រិតខ្ពស់គួរសម ដោយបានទទួលពិន្ទុ ចាប់ពីជិតកម្រិតលេខ ៤ ទៅ ៥ (តារាង ៣.១)។

កម្រិតភាពធ្ងន់ធ្ងរនៃការបង់ចំណាយក្រៅផ្លូវការដែលអ្នកតបសម្ភាសន៍ផ្តល់អោយ គឺមានភាពខុសៗគ្នា ពីខេត្តមួយទៅខេត្តមួយ។ មីក្រូសហគ្រាសដែលគេមើលឃើញថាការបង់ចំណាយក្រៅផ្លូវការមានភាពធ្ងន់ធ្ងរបំផុត គឺស្ថិតក្នុងខេត្តកំពត និងបន្ទាប់មកទៀតមានខេត្តសៀមរាប បាត់ដំបង បន្ទាយមានជ័យ និងក្រុងភ្នំពេញ ចំណែកឯមីក្រូសហគ្រាសក្នុងខេត្តព្រៃវែង និងក្រុងព្រះសីហនុ មានការបង់ចំណាយក្រៅផ្លូវការតិចជាងគេ។ ផ្ទុយមកវិញ សហគ្រាសធុនតូច និងមធ្យមក្នុងក្រុងព្រះសីហនុបង់ចំណាយក្រៅផ្លូវការធ្ងន់ធ្ងរជាងគេ និងបន្ទាប់មកទៀតមានខេត្ត កណ្តាល ព្រៃវែង និងក្រុងភ្នំពេញ។ ភាពខុសគ្នានៃការ

---

[៩] នៅពេលសួរសំណួរនេះ អ្នកតបសម្ភាសន៍ចង់បញ្ចេញគំនិតរបស់គេលើបញ្ហាអំពើពុករលួយទាំងមូលក្នុងប្រទេសកម្ពុជា ជាជាងតែក្នុងវិស័យឯកជន។ ដូច្នេះ មតិនេះគឺ ភាគច្រើនសំដៅលើអំពើពុករលួយទូទៅក្នុងប្រទេសកម្ពុជា ជាជាងសហគ្រាសផ្ទាល់ខ្លួនរបស់គេ។

បង់ចំណាយក្រៅផ្លូវការពីខេត្តមួយទៅខេត្តមួយ មានការជាប់ទាក់ទងគ្នាយ៉ាងខ្លាំងជាមួយ រដ្ឋបាលសាធារណៈ ដែលសហគ្រាសមានការជាប់ពាក់ព័ន្ធជាមួយ និងសកម្មភាពសេដ្ឋកិច្ចរបស់ខេត្តក្រុងទាំងនោះ។

**តារាង ៣.១: ភាពធ្ងន់ធ្ងរនៃចំណាយក្រៅផ្លូវការ**

**(១ = មិនធ្ងន់ធ្ងរ ៧ = ធ្ងន់ធ្ងរបំផុត)**

| | មីក្រូសហគ្រាស | សហគ្រាសធុនតូច និងមធ្យម | សហគ្រាសធុនធំ |
|---|---|---|---|
| ព្រៃវែង | ៤.០៨ | ៤.៣៣ | - |
| ក្រុងព្រះសីហនុ | ៤.១០ | ៤.៥០ | - |
| កំពង់ចាម | ៤.២៧ | ៣.៥២ | - |
| កណ្ដាល | ៤.៣៥ | ៤.៣៤ | - |
| ភ្នំពេញ | ៤.៥៣ | ៤.២២ | ៤.៩៨ |
| បន្ទាយមានជ័យ | ៤.៦១ | ៣.៧៣ | - |
| បាត់ដំបង | ៤.៦៥ | ៣.៥៧ | - |
| សៀមរាប | ៤.៨៨ | ៣.២១ | - |
| កំពត | ៥.២៩ | ៤.១១ | - |
| **មធ្យម** | **៤.៥៣** | **៣.៩៥** | **៤.៩៨** |

ប្រភព: *វ.ស.ក. ការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា - មេសា ២០០៦*

*ចំនួនអ្នកឆ្លើយតប: (សហគ្រាសធុនតូច = ៨១០ សហគ្រាសធុនតូច និងមធ្យម = ២៣៦ សហគ្រាសធុនធំ = ៤៤)*

ទោះបីជាយ៉ាងណាក៏ដោយ ការបង់ចំណាយក្រៅផ្លូវការរបស់សហគ្រាសនីមួយៗដែលបានចូលរួមក្នុងក្រុមពិភាក្សាមិនសូវមានភាពធ្ងន់ធ្ងរទេ។ អ្នកចូលរួមក្នុងក្រុមពិភាក្សាភាគច្រើន ស្ទើរតែគ្រប់ខេត្តក្រុងទាំងអស់បានអះអាងថា ការបង់ចំណាយក្រៅផ្លូវការមិនសូវធ្ងន់ធ្ងរទេសម្រាប់ក្រុមហ៊ុនតូចៗ ពីព្រោះពួកគាត់អាចបង់បាន។ សហគ្រិននៃសហគ្រាសធុនតូចបាននិយាយថា *"ការបង់ចំណាយក្រៅផ្លូវការ គឺមិនសូវធ្ងន់ធ្ងរទេសម្រាប់ក្រុមហ៊ុនតូចៗ ប៉ុន្តែធ្ងន់ធ្ងរសម្រាប់ក្រុមហ៊ុនធំៗ។ សហគ្រាសធុនតូចបង់តិចជាងសហគ្រាសធុនធំ អាស្រ័យលើទំហំ និងសកម្មភាពរបស់គេ"*។ យ៉ាងណាក៏ដោយ អ្នកតបសម្ភាសន៍មួយចំនួនតូចបានត្អូញត្អែរពីភាពធ្ងន់ធ្ងរនៃការបង់ចំណាយក្រៅផ្លូវការរបស់គាត់ផងដែរ។

ភាពធ្ងន់ធ្ងរនៃការបង់ចំណាយក្រៅផ្លូវការ គឺអាស្រ័យលើប្រភេទ ទីតាំង និងចំណូលរបស់សហគ្រាស រួមទាំងអាជ្ញាធរសាធារណៈដែលពាណិជ្ជករមានការជាប់ពាក់ព័ន្ធជាមួយ។ ម្ចាស់ម៉ាស៊ីនកិនស្រូវម្នាក់នៅ

អ្នកលឿងបានត្អូញត្អែរថាៈ *"មន្ត្រីសាធារណៈគិតថាយើងជាអ្នកមាន និងរកចំណូលបានច្រើន ដូច្នេះ គេទារចំណាយក្រៅផ្លូវការពីយើងច្រើនជាងអាជីវកម្មដទៃទៀត"*។

ការបង់ចំណាយក្រៅផ្លូវការមានកម្រិតកាន់តែខ្ពស់ខ្លាំង សម្រាប់ប្រភេទអាជីវកម្មមានលក្ខណៈខុសច្បាប់ ឧទាហរណ៍ដូចជា អាជីវកម្មលក់ឈើដែលបានមកពីតំបន់ព្រៃហាមឃាត់។ សហគ្រាសស្របច្បាប់ និងមិនស្របច្បាប់ គឺជាលក្ខខណ្ឌមួយទៀត ដែលទាក់ទងនឹងភាពធ្ងន់ធ្ងរនៃចំណាយក្រៅផ្លូវការ។ អ្នកចូលរួមពិភាក្សាបានបង្ហាញថា សហគ្រាសផលិតកម្មបង់សំណូកច្រើនជាងប្រភេទអាជីវកម្មដទៃទៀត ពីព្រោះពួកគេត្រូវដោះស្រាយជាមួយមន្ត្រីសាធារណៈផ្សេងៗគ្នាជាច្រើន ក្នុងដំណាក់កាលផលិតកម្មខុសៗគ្នា។

អ្នកចូលរួម ភាគច្រើន ក្នុងក្រុមពិភាក្សាបានយល់ស្របថា ទោះបីជាចំណាយក្រៅផ្លូវការមិនបានដាក់ការគំរាមកំហែងធ្ងន់ធ្ងរដល់ពួកគាត់ក៏ដោយ ពួកគាត់នៅតែមានភាពធុញទ្រាន់ និងភ័យខ្លាចចំពោះការចុះត្រួតពិនិត្យរបស់មន្ត្រីសាធារណៈទាំងនេះ។ សហគ្រិនភាគច្រើនចាំបាច់ត្រូវចំណាយពេលវេលារកស៊ីរបស់គេជាមួយមន្ត្រីទាំងនោះ ហើយសហគ្រិនមួយចំនួនទៀតត្អូញត្អែរពីការរំខានដល់អាជីវកម្មរបស់គេ។

ចំណុចសំខាន់មួយទៀតនៃការបង់ប្រាក់ដោយមិនស្មើភាពក៏ត្រូវបានលើកឡើង ដោយអ្នកចូលរួមនៅក្នុងក្រុមពិភាក្សាផងដែរ។ ការបង់ចំណាយក្រៅផ្លូវការក៏អាចខុសគ្នាដែរ ទៅតាមទំនាក់ទំនង រឺខ្សែបណ្តាញ និងខ្សែរយៈជាមួយមន្ត្រីរាជការ ទោះបីជាសហគ្រាសមានប្រភេទអាជីវកម្មប្រហាក់ប្រហែលគ្នាក៏ដោយ។ ដូច្នេះ សហគ្រាសដែលបង់ច្រើនជាងមិនអាចប្រកួតប្រជែងជាមួយដៃគូប្រកួតប្រជែងរបស់ខ្លួនទេ។ ករណីនេះធ្វើឱ្យមានស្ថានភាពមិនយុត្តិធម៌ក្នុងការប្រកួតប្រជែង។

ទោះបីជាយ៉ាងណា សហគ្រាសជាច្រើនទទួលស្គាល់ថា ស្ថានភាពពុករលួយបានប្រសើរឡើងជាងមុន បើប្រៀបធៀបនឹង ៣ ឬ ៤ ឆ្នាំចុងក្រោយនេះ។ ការប្រសើរឡើងនេះ សំដៅចំពោះបរិយាកាសអាជីវកម្មល្អជាងមុន។ សហគ្រាសជាច្រើនទទួលស្គាល់ផងដែរថា ចំនួននៃស្ថាប័នសាធារណៈ និងមន្ត្រីសាធារណៈដែលចូលមកសហគ្រាសរបស់ពួកគេដើម្បីទាររកប្រាក់ក្រៅផ្លូវការត្រូវបានកាត់បន្ថយ។ សហគ្រិនដែលប្រកបអាជីវកម្មធុនតូច និងមធ្យមម្នាក់បានលើកឡើងថា *"ចាប់តាំងពីឆ្នាំ ២០០០ មក ការបង់ចំណាយក្រៅផ្លូវការត្រូវបានកាត់បន្ថយ។ វាមិនសូវធ្ងន់ធ្ងរដូចពីមុនទេ ប៉ុន្តែខ្ញុំនៅតែមានអារម្មណ៍ធុញទ្រាន់ជាមួយពួកគេ"*។

## ៣.២. តើមានអំពើពុករលួយកម្រិតណាក្នុងវិស័យឯកជន ?

វិស័យឯកជនបង់ចំណាយជាមធ្យម ៣.៩ ភាគរយ នៃចំណូលពីការលក់ប្រចាំឆ្នាំសរុប[១០] ទៅលើចំណាយផ្លូវការ និងក្រៅផ្លូវការ។ ដែលក្នុងនោះប្រហែល ២៨ ភាគរយ ស្ថិតក្នុងរូបភាពជាចំណាយផ្លូវការ

[១០] ពាក្យថា "ចំណូលប្រចាំឆ្នាំ" សំដៅដល់បរិមាណសរុបនៃទំនិញ ឬសេវា ដែលបានលក់ដោយសហគ្រាសមួយ ក្នុងរយៈពេល ១២ ខែ។

ដែលបង្កើតបានជាការចំណូលពន្ធដែលប្រមូលបាន[១១] ចំណែកឯ ៧២ ភាគរយ ដែលនៅសល់ គឺជាចំណាយក្រៅផ្លូវការ ដែលចំណាយដោយវិស័យឯកជនទៅអោយមន្ត្រីរដ្ឋាភិបាល។ ជាក់ស្តែង ក្រុមហ៊ុនមានទំហំកាន់តែធំការ ចំណាយដែលទាររដោយមន្ត្រីរដ្ឋសាធារណៈក៏មានកាន់តែច្រើនដែរ។ លទ្ធផលពីការស្ទង់មតិបង្ហាញថាសហគ្រាសធុនធំបង់ចំណាយជាមធ្យមគឺ ៥ ភាគរយនៃប្រាក់ចំណូល ពីការលក់ប្រចាំឆ្នាំរបស់ពួកគាត់ រីឯមីក្រូសហគ្រាសបង់ត្រឹមតែ ៣.១ ភាគរយ និងសហគ្រាសធុនតូច និងមធ្យមបង់តែ ៣.៦ ភាគរយប៉ុណ្ណោះ (មើលតារាង ៣.២)។

**តារាង ៣.២: ចំណាយរបស់សហគ្រាសទៅមន្ត្រីសាធារណៈ**

(គិតជាភាគរយនៃប្រាក់ចំណូលពីការលក់)

| | មីក្រូសហគ្រាស | សហគ្រាសធុនតូចនិងមធ្យម | សហគ្រាសខ្នាតធំ | មធ្យម |
|---|---|---|---|---|
| **ចំណាយសរុប** | **៣.១ %** | **៣.៦ %** | **៥.០%** | **៣.៩ %** |
| ចំណាយផ្លូវការ | ១.៣ % | ១.១ % | ០.៩ % | ១.១ % |
| ចំណាយក្រៅផ្លូវការ | ១.៨ % | ២.៥ % | ៤.១ % | ២.៨ % |

**ប្រភព:** *ការព្យាករណ៍របស់ វ.ស.ក. ដោយផ្អែកលើការស្ទង់មតិការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជន នៅកម្ពុជា - មេសា ២០០៦*

តារាង ៣.២ បង្ហាញថា ចំណាយផ្លូវការដែលបានបង់ដោយសហគ្រាស ឬពន្ធដែលប្រមូលបានហាក់ដូចជាដាក់បន្ទុកបន្ថែមទៅលើមីក្រូសហគ្រាសធ្ងន់ជាងលើសហគ្រាសធុនតូច មធ្យម និងធំ។ អត្រាចំណាយផ្លូវការដែលបានបង់ដោយសហគ្រាស កាត់បន្ថយពី ១.៣ ភាគរយសម្រាប់មីក្រូសហគ្រាស ដល់ ១.១ ភាគរយ សម្រាប់ សហគ្រាសធុនតូចនិងមធ្យម និង ០.៩ ភាគរយ សម្រាប់សហគ្រាសធុនធំ។ ការពន្យល់សម្រាប់បញ្ហានេះគឺថា សហគ្រាសធុនតូច មធ្យម និងធំ មានអំណាចទាមទារច្រើនជាងក្នុងការចចារជាមួយមន្ត្រីពន្ធ ដើម្បីសុំអោយមាននូវអត្រាពន្ធទាប។ លើសនេះទៀត សហគ្រាសធុនធំ ភាគច្រើន ទទួលផលប្រយោជន៍ពីការលើកលែងពន្ធ ដែលជាងគោលនយោបាយរបស់រដ្ឋាភិបាល ក្នុងការទាក់ទាញ អ្នកវិនិយោគបរទេស។

គួរកត់សំគាល់ថា ចំណាយផ្លូវការដែលបានបង់ដោយសហគ្រាសមានអត្រាប្រហាក់ប្រហែលគ្នា។ នេះមានន័យថា ចំណាយសរុប ដែលបានបង់ដោយសហគ្រាស មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធទៅនឹងចំណាយក្រៅផ្លូវការ។ សហគ្រាសធុនធំបង់ចំណាយផ្លូវការក្នុងអត្រាមួយទាប ប៉ុន្តែត្រូវបង់ចំណាយក្រៅផ្លូវការក្នុងអត្រាដ៏ខ្ពស់ ៤.១ ភាគរយ នៃចំណូលប្រចាំឆ្នាំរបស់គាត់។ ចំណែកឯ ចំណាយក្រៅផ្លូវការ ដែលបង់ដោយ

[១១] ពាក្យថា ពន្ធដែលប្រមូលបាន សំដៅទៅលើពន្ធជាក់ស្តែងដែលបង់ដោយវិស័យឯកជន។ ជាទូទៅ បង្កាន់ដៃពន្ធត្រូវបានផ្តល់អោយ។

មីក្រូសហគ្រាស មានចំនួនត្រឹមតែ ១.៨ ភាគរយ និងសហគ្រាសធុនតូច និងមធ្យម មាន ២.៥ ភាគរយនៃចំណូល ពីការលក់របស់គាត់ប៉ុណ្ណោះ។

គួរកត់សំគាល់ផងដែរថា បរិមាណនៃអំពើពុករលួយក្នុងវិស័យឯកជន ហាក់ដូចជាថយចុះច្រើន បើធៀប នឹងលទ្ធផលដែលបានរកឃើញដោយធនាគារពិភពលោក ឆ្នាំ ២០០៤ (ប្រហែល ៥ ទៅ ៦ ភាគរយ នៃចំណូលសរុប)។[១២]

**ប្រអប់ ៣.១: តើចំណាយក្រៅផ្លូវការដែលបង់ដោយវិស័យឯកជនត្រូវបានកំណត់របៀបណា?**

ការកំណត់នូវចំណាយក្រៅផ្លូវការ គឺជាការងារដ៏លំបាកមួយ ដោយសារជាទូទៅសហគ្រិនមិនបានដឹងថា តើពួកគាត់ត្រូវបង់ប្រាក់ប៉ុន្មានសម្រាប់ការចំណាយផ្លូវការដែលតម្រូវដោយរដ្ឋាភិបាល។ ការរំលឹកទ្រឹស្តីពីឯកសារផ្សេងៗអាច សន្និដ្ឋានថា កាតព្វកិច្ចបង់ពន្ធ គឺជាកាតព្វកិច្ចចំណាយតែមួយគត់ ដែលសហគ្រាសឯកជនត្រូវតែបង់សម្រាប់ប្រតិបត្តិការណ៍ ប្រចាំឆ្នាំរបស់ពួកគេ។ ថ្លៃចំណាយផ្លូវការផ្សេងៗដែលក្រៅពីពន្ធនោះអាចនឹងត្រូវទាមទារដោយភ្នាក់ងាររដ្ឋាភិបាលនានា ប៉ុន្តែចំនួនទឹកប្រាក់ត្រូវបង់នេះ មានចំនួនតិចតួចអាចចោលបាន។ ដូច្នេះ រាល់ការចំណាយមិនមែនពន្ធជូនមន្ត្រីរាជការ ត្រូវបានចាត់ទុកថា ជាថ្លៃចំណាយក្រៅផ្លូវការ ដែលបង់ដោយវិស័យឯកជន។

ដើម្បីវាយតម្លៃកម្រិតនៃថ្លៃចំណាយសរុបឱ្យមន្ត្រីសាធារណៈដោយវិស័យឯកជន គេប្រើវិធីសាស្ត្រពីរផ្សេង គ្នា។ វិធីសាស្ត្រទី ១ គឺវិធីសាស្ត្រគណនា ដោយធ្វើផលចែករវាងចំណាយសរុប និងចំណូលប្រចាំឆ្នាំ ដែលបានប្រកាស ដោយសហគ្រិន។ វិធីសាស្ត្រទី ២ គឺ សហគ្រិនទាំងអស់ធ្វើការប៉ាន់ស្មានដោយខ្លួនឯងនូវចំណាយឱ្យមន្ត្រីរាជការសរុប របស់ខ្លួន ដោយគិតជាភាគរយនៃចំណូលប្រចាំឆ្នាំ។ វិធីសាស្ត្រទាំងពីរនេះ ផ្តល់នូវលទ្ធផលផ្សេងៗគ្នា ដែលជាហេតុធ្វើឱ្យ មានការពិបាកក្នុងការជ្រើសរើសវិធីសាស្ត្រណាមួយមកអនុវត្ត។ ទោះបីជាយ៉ាងណាក៏ដោយ វិធីសាស្ត្រទី ២ ត្រូវបាន គេពេញនិយមជាង បន្ទាប់ពីកិច្ចប្រជុំក្រុមផ្តល់ប្រឹក្សាពិសេស នៅក្នុង ខែឧសភា ឆ្នាំ ២០០៥ ដោយធ្វើការសន្មតថា សហគ្រិនដែលត្រូវបានជួបសម្ភាសអាចមិនបានរៀបរាប់អស់ពីការចំណាយរបស់គេ ជាពិសេសការចំណាយក្រៅផ្លូវការ។

ជាងនេះទៅទៀត ដើម្បីឱ្យទិន្នន័យមានភាពទៀងទាត់ និងភាពអាចយកជាការបានគេប្រើគំរូតែមួយផ្អែក ក្នុងការវាយតម្លៃនូវកម្រិតអំពើពុករលួយ។ គំរូដែលជ្រើសរើសក្នុងគោលដៅនេះ គឺផ្អែកទៅលើភាពយកជាការបាននៃធាតុ សំខាន់ៗបី ដែលប្រកាសដោយសហគ្រាស។ ធាតុទាំងនោះ គឺចំណូលប្រចាំឆ្នាំ ការចំណាយឱ្យមន្ត្រីរាជការសរុប និងការចំណាយឱ្យមន្ត្រីរាជការជាភាគរយនៃប្រាក់ចំណូលប្រចាំឆ្នាំ។ សហគ្រាសដែលមិនបានផ្តល់នូវព័ត៌មានទាំងបីខាង លើ គឺមិនត្រូវបានរាប់ចូលនៅ ក្នុងការគណនាកម្រិតអំពើពុករលួយទេ។

ប្រភព: *វ.ស.ក. ការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា - មេសា ២០០៦*

ដោយផ្អែកលើចំនួនប្រាក់ចំណូលព្យាករណ៍ដោយវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា[១៣] ចំណាយក្រៅផ្លូវការដែល បានបង់ដោយសហគ្រាសឯកជន មានចំនួន ៣៣០ ពាន់លាន ដុល្លារអាមេរិក ស្មើនឹង ប្រហែល ២.៥ ដង ខ្ពស់ជាង

[១២] សំគាល់: ការស្ទង់មតិដែលធ្វើឡើងដោយ វ.ស.ក. និង ធនាគារពិភពលោក ប្រើវិធីសាស្ត្រខុសគ្នា។ វ.ស.ក. បានផ្តោតជាសំខាន់លើអំពើ ពុករលួយនៅតាមខេត្តនានា ដែលជាទូទៅ មានអំពើពុករលួយតិចជាងនៅភ្នំពេញ ។

ចំណាយផ្លូវការដែលបានបង់របស់ពួកគាត់ ឬពន្ធដែលប្រមូលបានដោយមន្ត្រីពន្ធដារ។ ចំនួននេះស្មើនឹងប្រហែល ៥០ ភាគរយ នៃចំណូលថវិការរបស់រដ្ឋាភិបាលសរុប ក្នុងឆ្នាំ ២០០៥។

តារាង ៣.៣: ចំណាយរបស់សហគ្រាសទៅមន្ត្រីសាធារណៈ (លានដុល្លារអាមេរិក)

| | មីក្រូសហគ្រាស | សហគ្រាសធុនតូច និងមធ្យម | សហគ្រាសធុនធំ | សរុប |
|---|---|---|---|---|
| ចំណាយសរុប | ១២០ | ១៥០ | ១៩០ | ៤៦០ |
| ចំណាយផ្លូវការ | ៥០ | ៤៦ | ៣៤ | ១៣០ |
| ចំណាយក្រៅផ្លូវការ | ៧០ | ១០៤ | ១៥៦ | ៣៣០ |
| *អនុស្សារណៈ* | | | | |
| ចំណូល (*) | ៣ ៨៨៥ | ៤ ១៩៤ | ៣ ៨០៥ | ១១ ៨៨៤ |

ប្រភព: *ការព្យាករណ៍របស់ វ.ស.ក. ដោយផ្អែកលើការស្ទង់មតិការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជន នៅកម្ពុជា - មេសា ២០០៦*

*(*) មិនរួមបញ្ចូលវិស័យកសិកម្ម និងរដ្ឋបាលសាធារណៈ ដែលមិនបង់ពន្ធ*

## ៣.៣. ផលប៉ះពាល់នៃអំពើពុករលួយលើថវិការដ្ឋ

កំរិតចំណាយក្រៅផ្លូវការនេះ ហាក់បីដូចជា មានការប៉ះពាល់ទៅលើប្រសិទ្ធភាពនៃការប្រមូលពន្ធ។ លទ្ធផលដែលបានមកពីការស្ទង់មតិបង្ហាញថា អត្រាពន្ធផ្លូវការ[១៤] សម្រាប់សហគ្រាសឯកជន មានកំរិតខ្ពស់ជាងអត្រាពន្ធដែលប្រមូលបាន[១៥]ជាក់ស្តែង។ ការគណនាបានបង្ហាញថា អត្រាពន្ធផ្លូវការសម្រាប់មីក្រូសហគ្រាស ៣.៧ ភាគរយ សហគ្រាសធុនតូចនិងមធ្យម ៥.៨ ភាគរយ និងសហគ្រាសធុនធំ ៣.៨ ភាគរយ នៃចំណូលដែលបានមកពីការលក់ (តារាង ៣.៤)។

គួរកត់សំគាល់ថា សហគ្រាសធុនធំបានបង់ពន្ធអត្រាផ្លូវការមានចំនួនប្រហាក់ប្រហែលមីក្រូសហគ្រាសដែរ តែទាបជាងសហគ្រាសធុនតូច និងមធ្យម។ ការពន្យល់ដ៏សមហេតុផលមួយគឺថា សហគ្រាសធុនធំជាច្រើន

[១៣] មិនមានស្ថិតិផ្លូវការណាមួយស្តីពីចំណូលរបស់មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម និងសហគ្រាសធុនធំ ក្នុងប្រទេសកម្ពុជាទេ។ ទោះបីជាយ៉ាងណាក៏ដោយ ការព្យាករណ៍លើកម្លាំងពលកម្ម និងតម្លៃបន្ថែមរបស់សហគ្រាសផ្លូវការ និងក្រៅផ្លូវការដែលទទួលស្គាល់ដោយអង្គការពលកម្មអន្តរជាតិ ត្រូវបានធ្វើឡើងដោយវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិ ក្នុងឆ្នាំ ២០០៥។ ផ្អែកលើបទពិសោធន៍វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ចងក្រងចំណូលរបស់មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម និងសហគ្រាសធុនធំ ពីគណនេយ្យជាតិរបស់វិទ្យាស្ថានជាតិស្ថិតិ ដែលទើបតែបានចេញផ្សាយថ្មីៗនេះ ដោយប្រើប្រាស់ម៉ូដែល CGE និង I/O (ធាតុចូល - ធាតុចេញ)។

[១៤] ពន្ធផ្លូវការសក្តានុពល សំដៅលើចំនួនពន្ធដែលសហគ្រាសគួរបង់តាមអត្រាពន្ធផ្លូវការ។

[១៥] អត្រាពន្ធដែលប្រមូលបាន គឺជាអត្រាពន្ធដែលបានបង់ដោយសហគ្រាស

រួមបញ្ចូលទាំងរោងចក្រកាត់ដេរ ទទួលបានអត្ថប្រយោជន៍ពីការលើកលែងពន្ធ ដែលជាគោលនយោបាយរបស់រដ្ឋាភិបាល ក្នុងការទាក់ទាញវិនិយោគទុនបរទេស[១៦] ។

### តារាង ៣.៤: អត្រាពន្ធដែលប្រមូលបាន អត្រាពន្ធផ្លូវការ និងការខាតបង់របស់រដ្ឋាភិបាល

| | មីក្រូសហគ្រាស | សហគ្រាសធុនតូច និងមធ្យម | សហគ្រាសធុនធំ | មធ្យម |
|---|---|---|---|---|
| (ជាភាគរយចំណូល) | | | | |
| អត្រាពន្ធដែលប្រមូលបាន | ១.៣% | ១.១% | ០.៩% | ១.១% |
| អត្រាពន្ធផ្លូវការ | ៣.៧% | ៥.៨% | ៣.៨% | ៤.៤% |
| ការខាតបង់របស់រដ្ឋាភិបាល | ២.៤% | ៤.៧% | ២.៩% | ៣.៣% |
| (លានដុល្លារ) | | | | |
| ពន្ធដែលប្រមូលបាន | ៥០ | ៤៦ | ៣៤ | ១៣០ |
| ពន្ធផ្លូវការ | ១៤៤ | ២៤០ | ១៤៦ | ៥៣០ |
| ការខាតបង់របស់រដ្ឋាភិបាល | ៩៤ | ១៩៤ | ១១២ | ៤០០ |
| *អនុស្សារណៈ* | | | | |
| **ចំណូល** | **៣ ៨៨៥** | **៤ ១៥៤** | **៣ ៨០៥** | **១១ ៨៤៤** |

ប្រភព: *ការព្យាករណ៍របស់វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ដោយផ្អែកលើការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជន ខែមេសា ឆ្នាំ ២០០៦*

ទោះបីជា រដ្ឋាភិបាលប្រឹងប្រែងគួរឱ្យកត់សំគាល់ក្នុងការកែលំអប្រព័ន្ធប្រមូលពន្ធក៏ដោយ ក៏សហគ្រិននៅតែយល់ថា បញ្ហាប្រមូលពន្ធនេះ មួយផ្នែក គឺដោយសារតែប្រព័ន្ធពន្ធបច្ចុប្បន្នមានភាពស្មុគ្រស្មាញ និងគ្មានតម្លាភាព។ ប្រព័ន្ធពន្ធដារគួរត្រូវកែសម្រួលអោយមានភាពសាមញ្ញ និងមានតម្លាភាពជាងនេះ រួមទាំងការផ្តល់ជាគំនិតមូលដ្ឋាលគ្រឹះអំពីរបៀបគណនាពន្ធដារដល់សហគ្រិននីមួយៗ ក៏ជាការចាំបាច់ផងដែរ ដើម្បីឱ្យសហគ្រិននានាយល់ដឹងពីចំនួន និងកាតព្វកិច្ចរបស់ខ្លួនក្នុងការបង់ពន្ធ។

[១៦] ប្រសិនបើគ្មានការលើកលែងពន្ធទេ អត្រាពន្ធសក្តានុពលសម្រាប់សហគ្រាសធុនធំគួរតែមានចំនួន ៦.៤ ភាគរយ នៃចំណូល។

**ប្រអប់ ៣.២ : ការយកពន្ធតាមរបបពិត និងរបបម៉ៅការ**

បច្ចុប្បន្ន របបពន្ធពីរគឺ របបពន្ធពិត និងរបបពន្ធម៉ៅការ ត្រូវបានយកមកអនុវត្តនៅក្នុងប្រទេសកម្ពុជា។ សហគ្រាស ដែលនៅក្រោមរបបពន្ធពិត គឺអាស្រ័យទៅលើ (១) ទម្រង់ស្របច្បាប់របស់សហគ្រាស (២) កម្រិតនៃប្រាក់ចំណូលពីការលក់ (៣) ប្រភេទនៃសកម្មភាពរបស់អាជីវកម្ម។ ជាទូទៅ សហគ្រាសឯកកម្មសិទ្ធត្រូវយកពន្ធនៅក្រោមរបបម៉ៅការ ប្រសិនបើ ប្រាក់ចំណូលពីការលក់: - តិចជាង ៥០០ លានរៀល (ស្មើនឹង ១២៥ ០០០ ដុល្លារអាមេរិក) ចំពោះករណីការផ្គត់ផ្គង់ទំនិញ ឬផ្គត់ផ្គង់ចម្រុះ - តិចជាង ២៥០ លាន រៀល (ស្មើនឹង ៦២ ៥០០ ដុល្លារអាមេរិក) ចំពោះករណីការផ្គត់ផ្គង់សេវាកម្ម - រឺតិចជាង ១២៥ លានរៀល (ស្មើនឹង ៣១ ២៥០ ដុល្លារអាមេរិក) ចំពោះករណីមានកិច្ចសន្យាជាមួយរដ្ឋាភិបាល។ នៅក្នុងការគណនា វ.ស.ក. សន្មតថារបបពន្ធម៉ៅការត្រូវអនុវត្តចំពោះមីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម ចំណែកឯសហគ្រាសធុនធំ ត្រូវស្ថិតនៅក្រោមរបបពន្ធពិត។

នៅក្នុងរបបពន្ធម៉ៅការ ដែលប្រព័ន្ធគណនេយ្យមិនជាមានភាពចាំបាច់នោះ សហគ្រិនភាគច្រើនមិនសូវយល់អំពីមូលដ្ឋានសម្រាប់ការគណនាពន្ធទេ។ សហគ្រិននៃមីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យមតែងតែបង់ពន្ធដោយយោងទៅតាមមន្ត្រីពន្ធនិងតាមអំណោចចរចារបស់សហគ្រិនសុំអោយមានការបង់ពន្ធតិច។ តាមពិតសមាសធាតុពន្ធសំខាន់ៗ ចំនួន បី រួមមានពន្ធប៉ាតង់ ពន្ធម៉ៅការលើចំណូលពីការលក់ និងពន្ធម៉ៅការលើប្រាក់ ចំណេញបង់នៅក្នុងរបបពន្ធម៉ៅការ។ ពន្ធប៉ាតង់ត្រូវកំណត់ដោយផ្អែកលើសកម្មភាពអាជីវកម្ម និងកំរិតនៃប្រាក់ចំណូលពីការលក់។ រីឯពន្ធលើប្រាក់ចំណូល គឺកម្រិតនៅត្រឹម ២ ភាគរយ នៃប្រាក់ចំណូលពីការលក់ដែលប៉ាន់ស្មានជាមុនរបស់សហគ្រាស។ ចំណែកឯពន្ធលើប្រាក់ចំណេញវិញ ការគណនាមានការខុសគ្នាពីសហគ្រាសមួយទៅសហគ្រាសមួយទៀត ហើយអត្រាពន្ធខុសគ្នា ត្រូវបានអនុវត្តដោយអាស្រ័យទៅលើសកម្មភាពរបស់សហគ្រាស និងកម្រិតប្រាក់ចំណេញដែលប៉ាន់ស្មានដោយមន្ត្រីពន្ធ។

ប្រភព: *ច្បាប់ស្តីពីការយកពន្ធ ១៩៩៧ ប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ ២០០៤ និងការសម្ភាសជាមួយមន្ត្រីពន្ធ*

## ៣.៤. ផលប៉ះពាល់នៃអំពើពុករលួយមកលើសេដ្ឋកិច្ច

ទោះបីចំណាយក្រៅផ្លូវការរបស់វិស័យឯកជន ហាក់ដូចជាបានកាត់បន្ថយគួរឱ្យកត់សំគាល់ក្តី (ពីចន្លោះ ៥-៧ ភាគរយ នៃចំណូលដែលបានមកពីការលក់ នៅឆ្នាំ ២០០៤ មក ២-៤ ភាគរយ នៅក្នុងឆ្នាំ ២០០៦) ក៏ ចំណាយក្រៅផ្លូវការចំនួន ៣៣០ លានដុល្លារអាមេរិក នេះ នៅតែមានកំរិតខ្ពស់នៅឡើយ បើប្រៀបធៀបទៅនឹងទំហំសេដ្ឋកិច្ចកម្ពុជា។ ចំនួនថ្លៃចំណាយក្រៅផ្លូវការមានប្រហែល ៦ ភាគរយ នៃផលិតផលជាតិសរុប ឬស្មើនឹង ប្រហែល ៥០ ភាគរយ នៃចំណូលក្នុងស្រុករបស់រដ្ឋាភិបាល (ដោយមិនរាប់បញ្ចូលជំនួយបរទេស)។

បរិមាណចំណាយក្រៅផ្លូវការនេះ អាចត្រូវបានប្រើប្រាស់សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយតម្លាភាព និង មានផលិតភាពជាងនេះ ដូចជា ការបង្កើនប្រាក់ខែមន្ត្រីរាជការដើម្បីពង្រឹងរដ្ឋបាលសាធារណៈបច្ចុប្បន្ន ដែលនៅខ្សោយ បង្កើតនូវប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ដើម្បីកាត់បន្ថយភាពក្រីក្រនៅជនបទ ឬពង្រឹងប្រព័ន្ធអប់រំមួយចំនួន ដើម្បីកម្មករកម្ពុជាមានលទ្ធភាពប្រកួតប្រជែងនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចពិភពលោកបច្ចុប្បន្ន។

ផលប៉ះពាល់នៃចំណាយក្រៅផ្លូវការលើសេដ្ឋកិច្ចមានដូចខាងក្រោមនេះ:

### ក- ការតម្លើងបៀវត្សរ៍មន្ត្រីរាជការ

បរិមាណចំណាយក្រៅផ្លូវការដែលបង់ដោយវិស័យឯកជន មានចំនួនច្រើនជាងតម្រូវការរបស់រដ្ឋាភិបាលក្នុងការតម្លើងប្រាក់ខែអោយដល់កំរិតសមរម្យ ជាមធ្យមពី ១៣០ ដុល្លារ ដល់ ១៥០ ដុល្លារ ក្នុងមួយខែ ដល់មន្ត្រីរបស់ខ្លួនដែលមានចំនួន ៣០០ ០០០ នាក់ (ដែលរួមមាន គ្រូបង្រៀន គិលានុបដ្ឋាយិការ នគបាល ទាហាន ...)។

ការស្រាវជ្រាវពីវិស័យឯកជននេះបានបញ្ជាក់ផងដែរថា បញ្ហាប្រាក់ខែមន្ត្រីរាជការទាប ជាបុព្វហេតុមួយក្នុងចំណោមបុព្វហេតុសំខាន់បំផុតដែលនាំអោយមានអំពើពុករលួយ។ លើសនេះទៅទៀត របាយការណ៍ស្តីអំពីលទ្ធភាពប្រកួតប្រជែង ២០០៥-២០០៦[១៧] របស់អង្គការវេទិកាសេដ្ឋកិច្ចពិភពលោក និង វិទ្យាស្ថានសេដ្ឋកិច្ច កម្ពុជាបានបង្ហាញយ៉ាងច្បាស់ថា ប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានលទ្ធភាពប្រកួតប្រជែងទាបជាងគេបំផុតនៅក្នុងពិភពលោក ដោយសារតែអំពើពុករលួយមានកំរិតខ្ពស់។ ដូច្នេះហើយ ការតម្លើងប្រាក់ខែដល់មន្ត្រីរាជការអោយដល់កំរិតសមរម្យមួយនោះ និងជួយសេដ្ឋកិច្ចកម្ពុជាអោយមានលក្ខណៈប្រកួតប្រជែង បង្កើតការងារ និងកាត់បន្ថយភាពក្រីក្របានយ៉ាងច្រើន។

### ខ- ការបង្កើតប្រព័ន្ធធារាសាស្ត្រ

ជាមួយនឹងបរិមាណចំណាយក្រៅផ្លូវការដែលបង់ដោយវិស័យឯកជននៅកម្ពុជានេះដែរ រដ្ឋាភិបាលអាចបង្កើតនូវប្រព័ន្ធធារាសាស្ត្រដែលអាចមានលទ្ធភាពស្រោចស្រពផ្ទៃដីដាំដុះចំនួន ៥០០ ០០០ ហិចតា ដែលអាចតំបន់ដាំដុះរបស់កម្ពុជាអាចក្លាយទៅជាកន្លែងដែលមានការស្រោចស្រពច្រើនបំផុតនៅក្នុងតំបន់ក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ។ ដូច្នេះ កម្ពុជាអាចនឹងក្លាយទៅជាប្រទេសមួយក្នុងចំណោមប្រទេសនាំចេញស្រូវដ៏សំខាន់នៅក្នុងពិភពលោក ដូចដែលខ្លួនធ្លាប់ធ្វើនៅ៤០ ឆ្នាំមុន។ ចំណូលរបស់គ្រួសារនៅតាម ជនបទអាចកើនឡើងពីរដង រឺបីដង ដែលនឹងជួយកាត់បន្ថយភាពក្រីក្រនៅជនបទថែមមួយចំនួនធំទៀត។

---

[១៧] ចាន់ វុទ្ធី និង សុខ ក្លារ៉ា របាយការណ៍ស្តីពីលទ្ធភាពប្រកួតប្រជែងនៅកម្ពុជា ២០០៥-២០០៦ វ.ស.ក.

### គ- បង្កើនប្រព័ន្ធអប់រំ

ប្រព័ន្ធអប់រំនៅកម្ពុជាត្រូវបានគេវាយតំលៃថា មានកំរិតស្តង់ដារទាបនៅឡើយ។ ប្រព័ន្ធអប់រំបច្ចុប្បន្ន មិនបំពេញសមស្របទៅតាមតំរូវការរបស់វិស័យឯកជននៅឡើយទេ។ ដូច្នេះ វិនិយោគិន ជាទូទៅមានការត្អូញត្អែរអំពីកង្វះខាតធនធានមនុស្សនៅកម្ពុជា។

គម្រោងថវិកាឆ្នាំ ២០០៥ សម្រាប់វិស័យអប់រំ មានចំនួនសរុប ៨៥ លានដុល្លាអាមេរិក។ ដូច្នេះ បរិមាណចំណាយក្រៅផ្លូវការរបស់វិស័យឯកជនមានប្រហែលជាបីដងនៃគម្រោងថវិកានេះ។ ជាមួយនឹងនូវឆន្ទៈនយោបាយខ្ពស់ រដ្ឋាភិបាលអាចកែលំអប្រព័ន្ធអប់រំនៅក្នុងប្រទេសកម្ពុជា ដោយការបែងចែកជាថ្មីនូវប្រាក់ដែលខាតបង់ដោយសារអំពើពុករលួយនេះ អោយដល់ការអប់រំដល់យុវជនកម្ពុជា។ ធ្វើដូច្នេះ សេដ្ឋកិច្ចកម្ពុជានឹងមានលក្ខណៈប្រកួតប្រជែងជាងមុន ដោយតាមរយៈការកែលំអសមត្ថភាពធនធានមនុស្ស។

សរុបមក អ្វីដែលគួរពិចារណាគឺថា ប្រទេសកម្ពុជាសំបូរធនធាន ដូចប្រទេសជិតខាងរបស់ខ្លួនដែរ ប៉ុន្តែ ប្រទេសទាំងនោះទទួលជោគជ័យក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់គេ ដោយសារតែមាននូវការគ្រប់គ្រងល្អទៅលើធនធានដែលមាន។ ដោយការប្រយុទ្ធប្រឆាំងទៅនឹងអំពើពុករលួយនៅក្នុងរដ្ឋបាលរបស់ខ្លួន ប្រទេសទាំងនោះបានប្រមូលផ្តុំនូវធនធានដែលមាន ដើម្បីធានាអោយមាននូវការអភិវឌ្ឍ ដែលមានប្រយោជន៍ដូចជាវិស័យអប់រំ និងផ្នែកធារាសាស្ត្រ។

# ជំពូកទី ៤

# យុទ្ធសាស្ត្រទប់ស្កាត់អំពើពុករលួយក្នុងវិស័យឯកជន

*"បើសិនជាយើងនៅស្ងៀមនិងធ្វើដូចជាខ្សោយ ពួកគាត់នៅតែបន្តមករកលុយពីយើង។*
*ប៉ុន្តែ បើយើងហ៊ានចរចា និងជជែកតវ៉ាតាមផ្លូវច្បាប់ជាមួយពួកគាត់*
*ពួកគាត់នឹងមិនហ៊ានមកទៀតទេ"។*

-ម្ចាស់មីក្រូសហគ្រាសម្នាក់ នៅបន្ទាយមានជ័យ

យោងតាមទស្សនៈរបស់សហគ្រិនជាច្រើន ទោះបីជាចំណាយក្រៅផ្លូវការ និងបញ្ហាអំពើពុករលួយរាប់រយជំពូកនៅក្នុងវិស័យឯកជនមានសភាពធ្ងន់ធ្ងរក៏ដោយ ក៏រដ្ឋាភិបាលយកចិត្តទុកដាក់ និងចាត់វិធានការណ៍តិចតួចនៅឡើយ ដើម្បីទប់ស្កាត់អំពើពុករលួយក្នុងវិស័យនេះ។ ជាពិសេស នៅពេលដែលសួរសំណួរថា តើរដ្ឋាភិបាលបានចាត់វិធានការណ៍ដើម្បីដោះស្រាយបញ្ហាពុករលួយក្នុងវិស័យឯកជនដែរឬទេ? សហគ្រិនទាំងអស់បានឆ្លើយសំណួរនេះប្រកបដោយទុទ្ទិដ្ឋិនិយម (រូបភាព ៤.១)។

**រូបភាព ៤.១: សកម្មភាពរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ**
**(១=មិនជោគជ័យទាល់តែសោះ ៧=ប្រកបដោយជោគជ័យ)**




**ប្រភព:** *វ.ស.ក. ការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា - មេសា ២០០៦*

ដើម្បីអោយរដ្ឋាភិបាលប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយប្រកបដោយជោគជ័យ សហគ្រិននៃមីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម និងមន្ត្រីសាធារណៈបានបញ្ចេញគំនិត និងអនុសាសន៍ជាច្រើន។ សហគ្រិនក៏បានសម្តែងតួនាទីរបស់ខ្លួនជាអ្នកចូលរួមក្នុងវិស័យឯកជន ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុក-

រលួយផងដែរ។ ជំពូកនេះនឹងពិនិត្យមើលអនុសាសន៍របស់ពួកគាត់ និងតួនាទីរបស់វិស័យឯកជនក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។

គួរកត់សំគាល់ថា ទោះបីជាអនុសាសន៍ខាងក្រោមនេះជាចំណុចដោយឡែកៗពីគ្នាក្តី ប៉ុន្តែអនុ-សាសន៍ទាំងនោះគួរត្រូវបានអនុវត្តព្រមៗគ្នា។ ជាឧទាហរណ៍ កំណែទម្រង់ដោយតម្លើងបៀវត្សរ៍មន្ត្រីរាជ-ការតែឯង ដោយគ្មានការអនុវត្តច្បាប់ប្រឆាំងនឹងអំពើពុករលួយប្រកបដោយប្រសិទ្ធភាព នោះមិនអាចកាត់បន្ថយអំពើពុករលួយបានទេ។

## ៤.១. ការបង្កើតយន្តការប្រឆាំងនឹងអំពើពុករលួយប្រកបដោយប្រសិទ្ធភាព

ច្បាប់ប្រឆាំងអំពើពុករលួយចាំបាច់ត្រូវតែអនុម័ត។ ក្រុមអ្នកពិភាក្សាជាច្រើនមានទស្សនៈថា វាមានសារៈសំខាន់ណាស់ក្នុងការអនុម័តច្បាប់នេះជាមុនសិន ដោយសារពួកគាត់ជឿថានៅពេលមានច្បាប់យ៉ាងហោចណាស់ក៏មានការខ្លាចក្រែងក្នុងការប្រព្រឹត្តិអំពើពុករលួយដែរ។

### ៤.១.១. អនុម័តនូវច្បាប់ប្រឆាំងនឹងអំពើពុករលួយ "ដ៏ល្អ" មួយ

មកដល់ពេលនេះ កម្ពុជាមិនទាន់មានច្បាប់ប្រឆាំងនឹងអំពើពុករលួយទេ។ កាលពីកិច្ចប្រជុំពិគ្រោះយោបល់របស់ប្រទេសម្ចាស់ជំនួយ និងរដ្ឋាភិបាលលើកទី ៨ កាលពីខែ មីនា ២០០៦ រដ្ឋាភិបាលប្តេជ្ញាចិត្តអនុម័តពង្រាងច្បាប់នេះត្រឹមដំណាច់ ខែមិថុនា ឆ្នាំ ២០០៦ និងរៀបចំគំរោងដើម្បីពង្រឹង និងគ្រប់គ្រងការអនុវត្តច្បាប់ នេះឱ្យបានមុនខែ តុលា ឆ្នាំ ២០០៦[១៨] ។

នៅពេលដែលកំពុងសរសេររបាយការណ៍នេះ ពង្រាងច្បាប់នេះ ត្រូវបានបញ្ជូនទៅគណៈរដ្ឋមន្ត្រីដើម្បីពិភាក្សាអំពីភាពស្របគ្នានៃពង្រាងច្បាប់នេះទៅនឹងពង្រាងក្រមព្រហ្មទណ្ឌ និងនីតិវិធីក្រមព្រហ្មទណ្ឌ។ ពង្រាងច្បាប់ប្រឆាំងអំពើពុករលួយមិនអាចត្រូវបានអនុម័តនៅមុនបំណាច់ ខែកក្កដា ឆ្នាំ ២០០៦ ដូចដែលរដ្ឋាភិបាលបានសន្យានោះទេ។

គួរកត់សំគាល់ថា សហគ្រាសមួយចំនួនធំដឹងថា រដ្ឋាភិបាលកំពុងពង្រាងច្បាប់ប្រឆាំងនឹងអំពើពុករលួយ (រូបភាព ៤.២)។ ទោះបីជាយ៉ាងនេះក្តី មិនមានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ដោយសារទីតាំងដែលបាន ធ្វើការស្ទង់មតិស្ថិតនៅទីប្រជុំជនដែលមានភាពងាយស្រួលក្នុងការទទួលព័ត៌មាននានា។

[១៨] ទស្សនាវដ្តីឃ្លាំមើលសេដ្ឋកិច្ចកម្ពុជាលេខ ៤ ទំព័រ ៧៨

### រូបភាព ៤.២: ការយល់ដឹងរបស់សហគ្រិនអំពីពង្រាងច្បាប់ប្រឆាំងនឹងអំពើពុករលួយ




ប្រភព: *វ.ស.ក. ការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា - មេសា ២00៦*

ទោះបីជាច្បាប់នេះនឹងត្រូវអនុម័តដោយសភាក៏ដោយ ក៏នៅមានបញ្ហាចំរូងចំរាស់លើប្រការដែលថា ច្បាប់នេះពុំទាន់ស្របតាមស្តង់ដារអន្តរជាតិ។ អ្នករិះគន់បានលើកឡើងថា ពង្រាងច្បាប់នេះមិនស្របតាមបទដ្ឋាន អន្តរជាតិ លើ ៤ ចំណុចសំខាន់ៗ[១៩] :

- ពង្រាងច្បាប់នេះខ្វះឯករាជ្យភាពក្នុងការប្រតិបត្តិ និងថវិកាស្វយ័តសម្រាប់អជ្ញាធរប្រឆាំងអំពើពុករលួយ ។
- ពង្រាងច្បាប់នេះមិនបានផ្តល់នូវឯករាជ្យភាពគ្រប់គ្រាន់ក្នុងការស៊ើបអង្កេតសម្រាប់អាជ្ញាធរប្រឆាំងអំពើពុករលួយឡើយ ។
- ទាក់ទងនឹងការប្រកាសទ្រព្យសម្បត្តិ ច្បាប់នេះគួរអនុញ្ញាតឱ្យអគ្គលេខាធិការនៃអាជ្ញាធរប្រឆាំងអំពើពុករលួយអាចទទួលព័ត៌មានអំពីការប្រកាសទ្រព្យសម្បត្តិពេលស៊ើបអង្កេត។ ការប្រកាសទ្រព្យសម្បត្តិត្រូវធ្វើរួមទាំងទ្រព្យរបស់ប្តីឬប្រពន្ធ និងកូនផងដែរ និងអាចត្រូវប្រើជាភស្តុតាងនៃបទល្មើសព្រហ្មទណ្ឌ។
- ភាពស្របគ្នានៃពង្រាងច្បាប់នេះ ជាមួយនឹងក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌ (ឧទាហរណ៍ ការរក្សាការសំងាត់ដើម្បីការពារជនរងគ្រោះ និងសាក្សី និងទណ្ឌកម្មជាពិសេស ចំពោះការមិនរក្សាភាពសំងាត់) ។

[១៩] បទឧទ្ទេសនាមដោយ Pact បទដ្ឋានអន្តរជាតិ និងពង្រាង ច្បាប់ប្រឆាំងនឹងអំពើពុករលួយកាលពីថ្ងៃ ២៣ ឧសភា ២00៦

មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម មានទស្សនៈដូចគ្នានឹងអ្នកវិនិយោគខាងលើដែរ។ មីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម យល់ឃើញថា គួរមានអាជ្ញាធរ ឬភ្នាក់ងារ ឬក្រុមប្រឹក្សាមួយដែលឯករាជ្យ និងស្វយ័ត ដើម្បីត្រួតពិនិត្យ និងស៊ើបអង្កេតបញ្ហាពុករលួយ។ ខណៈដែលតុលាការត្រូវបានគេរកឃើញថា បានប្រព្រឹត្តអំពើពុករលួយច្រើនជាងគេ និងខ្វះឯករាជ្យភាព ក្រុមប្រឹក្សាប្រឆាំងអំពើពុករលួយនឹងដើរតួយ៉ាងសំខាន់ក្នុងការទប់ស្កាត់អំពើពុករលួយនេះ។

សហគ្រិននៃសហគ្រាសធុនតូច និងមធ្យមមានប្រសាសន៍ថា *"គោលនយោបាយ និងច្បាប់គួរមានភាពច្បាស់លាស់ សំរាប់ក្រុមប្រឹក្សាប្រឆាំងអំពើពុករលួយប្រើប្រាស់អំណាចរបស់គាត់ ប្រកបដោយឯករាជ្យភាព បើមិនដូច្នោះទេ អាជ្ញាធរដែលបង្កើតឡើងនេះនឹងពុករលួយដែរដែលធ្វើឱ្យបញ្ហាកាន់តែធ្ងន់ធ្ងរឡើង"*។ លើសពីនេះទៀត មីក្រូសហគ្រាស និងសហគ្រាសធុនតូចនិងមធ្យម យល់ឃើញថា ច្បាប់ប្រឆាំងអំពើពុករលួយគួរតម្រូវអោយមានការប្រកាសទ្រព្យសម្បត្តិរបស់មន្ត្រីថ្នាក់ខ្ពស់ ដើម្បីអនុញ្ញាតឱ្យអាជ្ញាធរ ឬក្រុមប្រឹក្សាដែលមានសមត្ថភាពធ្វើការតាមដាន និងស៊ើបអង្កេតអំពីអំពើពុករលួយដែលអាចកើតមានឡើង។

ហេតុដូចនេះហើយ ដើម្បីធ្វើការកាត់បន្ថយអំពើពុករលួយក្នុងវិស័យឯកជន ក៏ដូចជាក្នុងប្រទេសជាតិទាំងមូល ការអនុម័តនូវច្បាប់ប្រឆាំងនឹងអំពើពុករលួយដ៏ល្អមួយ ជាជំហានទីមួយដែលរដ្ឋាភិបាលគួរតែធ្វើ។ រដ្ឋាភិបាលបានបង្ហាញនូវឆន្ទៈដ៏ខ្លាំងក្លារបស់ខ្លួន តាមរយៈគោលនយោបាយជាច្រើន ជាពិសេសយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល។ ដើម្បីប្រែក្លាយឆន្ទៈនេះអោយទៅជាការពិតមួយ កិច្ចប្រឹងប្រែងក្នុងការអនុម័តនូវច្បាប់ប្រឆាំងនឹងអំពើពុករលួយមួយ ដែលស្របតាមស្តង់ដារអន្តរជាតិ ជាការចាំបាច់ណាស់។ កិច្ចប្រឹងប្រែងថែមទៀតរបស់រដ្ឋាភិបាលគួរតែផ្តោតលើការពន្លឿននៃនីតិវិធីក្នុងការអនុម័តនូវច្បាប់ប្រឆាំងនឹងអំពើពុករលួយមួយ ដែលអាចធ្វើអោយប្រទេសកម្ពុជាមានមូលដ្ឋានច្បាប់មួយដែលរឹងមាំ និងគួរអោយទុកចិត្តបាន ដើម្បីកាត់បន្ថយអំពើពុករលួយក្នុងវិស័យឯកជន ក៏ដូចជាក្នុងប្រទេសទាំងមូល។

### ៤.១.២. ការពង្រឹងការអនុវត្តច្បាប់ប្រឆាំងនឹងអំពើពុករលួយ

ច្បាប់ប្រឆាំងនឹងអំពើពុករលួយដែលបានអនុម័តហើយ មិនគួរមានតែនៅលើក្រដាសតែប៉ុណ្ណោះទេ។ ច្បាប់នេះត្រូវតែអនុវត្តអោយមានប្រសិទ្ធិភាព ដោយដាក់ទណ្ឌកម្មចំពោះមន្ត្រីដែលពុករលួយ។ មន្ត្រីសាធារណៈនឹងមិនប្រព្រឹត្តអំពើពុករលួយទៀតឡើយ ប្រសិនបើមានការអនុវត្តច្បាប់ប្រឆាំងនឹងអំពើពុករលួយប្រកបដោយប្រសិទ្ធិភាព ពីព្រោះពួកគាត់ខ្លាចបាត់បង់នូវការងាររបស់ខ្លួន និងទទួលនូវទណ្ឌកម្ម។

ទោះបីយ៉ាងណាក្តី ការអនុវត្តច្បាប់នេះគួរធ្វើឡើងដោយស្មើភាពគ្នា ទោះបីជាអ្នកនោះ ជានរណា រឺធ្វើអ្វីក៏ដោយ។ ប៉ុន្តែ យុទ្ធនាការប្រឆាំងនឹងអំពើពុករលួយគួរអនុវត្តពីលើចុះក្រោម ជាជាងពីក្រោមឡើង

លើ។ ប្រសិនបើមន្ត្រីជាន់ខ្ពស់ទទួលរងទណ្ឌកម្មដោយសារអំពើពុករលួយ មន្ត្រីថ្នាក់ទាបនឹងមានការក្រែងរអាក្នុងការប្រព្រឹត្តិអំពើពុករលួយ ហើយការអនុវត្តច្បាប់នឹងកាន់តែមានប្រសិទ្ធភាព ដូចដែលមន្ត្រីម្នាក់បានលើកឡើងថាៈ *"អ្នកដឹកនាំរដ្ឋាភិបាលថ្នាក់ជាតិត្រូវតែគោរពច្បាប់មុន ទើបប្រជាជនធ្វើតាម"* ។

ដូចគ្នាដែរ សហគ្រិនម្នាក់លើកឡើងថា ៖ *" ខ្ញុំគិតថាយើងគួរកែទម្រង់ពីលើចុះក្រោម។ មន្ត្រីថ្នាក់ទាបនឹងខ្លាចមិនហ៊ានរំលោភច្បាប់ឡើយ ដោយសារពួកគេឃើញចៅហ្វាយខ្លួនទទួលទណ្ឌកម្ម។ ប្រសិនបើយើងអនុវត្តពីថ្នាក់ក្រោម ថ្នាក់លើនឹងប្រឹងយកសំណូកទៀត ដោយសារពួកគេដឹងថាពួកគេគ្មានឱកាសទៀតឡើយ"*។

ទោះបីជាមានបញ្ហានៃអំពើពុករលួយយ៉ាងណាក៏ដោយ មីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម និងមន្ត្រីរាជការមានជំនឿទុកចិត្តលើកម្មវិធីកំណែទម្រង់របស់រដ្ឋាភិបាល។ ពួកគាត់ជឿថា រដ្ឋាភិបាលនឹងអនុវត្តច្បាប់ប្រឆាំងនឹងអំពើពុករលួយប្រកបដោយភាពជោគជ័យ នៅពេលដែលពង្រាងច្បាប់នេះអនុម័តដោយរដ្ឋសភា។ ពួកគាត់ជឿថា រដ្ឋាភិបាលនឹងដាក់ការអនុវត្តច្បាប់នេះ ជាអាទិភាពសំខាន់មួយ។ យ៉ាងហោចណាស់ ស្ថានការណ៍នឹងប្រសើរជាងពេលគ្មានច្បាប់ នេះបើយោងតាមមីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម។ ប៉ុន្តែ សហគ្រាសធុនធំ ហាក់ដូចជាមិនសូវមានទស្សនៈវិជ្ជមានប៉ុន្មានទេ។

**រូបភាព ៤.៣ៈ ជោគជ័យនៃការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ**

**(១=មិនជោគជ័យទាល់តែសោះ ៧=ជោគជ័យណាស់)**




**ប្រភព:** *វ.ស.ក. ការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា - មេសា ២០០៦*

មន្ត្រីសាធារណៈមួយចំនួនដែលបានសម្ភាសមានទស្សនៈដូច មីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យមដែរ។ មន្ត្រីសាធារាណៈ យល់ថា ការអនុវត្តច្បាប់នេះមិនអាចបានជោគជ័យ ១០០ ភាគរយទេ ប៉ុន្តែអាចកាត់បន្ថយអំពើពុករលួយបានមួយកំរិតដែរ។ មន្ត្រីសាធារណៈម្នាក់បាននិយាយថា *"ការ*

*អនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ មិនមានប្រសិទ្ធភាពទាំងស្រុងឡើយ ប្រសិនបើបៀវត្សរ៍នៅតែទាប ដដែលនោះ។ ប៉ុន្តែ វានឹងជួយកាត់បន្ថយអំពើពុករលួយបានមួយកំរិត។ ខ្ញុំមានការសប្បាយរីករាយណាស់ ប្រសិនបើគេអនុម័តច្បាប់នេះ"*។

ទំនុកចិត្តរបស់វិស័យឯកជន និងមន្ត្រីរាជការក្នុងកម្មវិធីកំណែទំរង់របស់រដ្ឋាភិបាល ជាការគាំទ្រ ផ្នែកសតិអារម្មណ៍មួយដល់រដ្ឋាភិបាល និងជួយលើទឹកចិត្តរដ្ឋាភិបាល ក្នុងការបង្កើនកិច្ចប្រឹងប្រែងថែម ទៀត ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ វិស័យឯកជន មន្ត្រីរាជការ សង្គមស៊ីវិល ម្ចាស់ជំនួយ ភ្នាក់ងារពាក់ព័ន្ធផ្សេងទៀត ព្រមទាំងប្រជាជនកម្ពុជាទាំងអស់ ទន្ទឹងចាំដោយសង្ឃឹមថានឹងមានការអនុ-វត្តច្បាប់ប្រឆាំងនឹងអំពើពុករលួយដែលនឹងត្រូវអនុម័តនៅពេលខាងមុខនេះ។

## ៤.២. ការតំឡើងប្រាក់ខែរបស់មន្ត្រីរាជការ

មីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យមស្ទើរតែទាំងអស់ បានលើកពីព្រំដែននៃការបង្ខំ អោយអនុវត្តច្បាប់ប្រឆាំងនឹងអំពើពុករលួយ។ មីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម ជឿជាក់ ថា វាមានទំនាក់ទំនងខ្លាំងរវាងការតម្លើងបៀវត្សរ៍ឱ្យមន្ត្រីរាជការ និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ប្រឆាំងនឹងអំពើពុករលួយនេះ។ ប្រសិនបើគ្មានប្រាក់ខែគ្រប់គ្រាន់ទេ ការចាប់បង្ខំអោយអនុវត្តច្បាប់ប្រឆាំង នឹងអំពើពុករលួយពុំអាចទទួលបានជោគជ័យទេ ដូចដែលសហគ្រិននៃមីក្រូសហគ្រាសម្នាក់បានមានប្រសាសន៍ ថា: *"ការអនុវត្តច្បាប់តឹងរ៉ឹងមិនអាចធ្វើបានឡើយ ពីព្រោះបៀវត្សរ៍មិនគ្រប់គ្រាន់"*។

**ប្រអប់ ៤.១: តើមន្ត្រីសាធារណៈចាយលុយពុករលួយរបៀបណា?**

តាមពិតទៅ នៅពេលនិយាយអំពីរបៀប និងមូលហេតុដែលមន្ត្រីសាធារណៈប្រើលុយបានពីអំពើពុករលួយមាន ការខុសគ្នារវាងមន្ត្រីធម្មតា និងមន្ត្រីថ្នាក់ខ្ពស់។ មន្ត្រីរាជការធម្មតាទទួលចំណាយក្រៅផ្លូវការពីវិស័យឯកជនដើម្បីរស់ និងចំណាយប្រចាំថ្ងៃប៉ុណ្ណោះ។ ការចំណាយប្រចាំថ្ងៃរបស់ពួកគាត់មាន ចំណាយផ្ទាល់ខ្លួន និងគ្រួសារ និងតម្រូវការ ចាំបាច់នានា ដូចជាអាហារ សំលៀកបំពាក់ ប្រេង និងព្រឹត្តិការណ៍សង្គមនានា ដូចជា អាពាហ៍ពិពាហ៍ ស៊ីផឹក និង ជប់លៀង។ល។

ទោះបីយ៉ាងណាក្តី មន្ត្រីជាច្រើនលើកឡើងថា មន្ត្រីជាន់ខ្ពស់ហាក់ដូចជាទទួលសំណូកដើម្បីមានបាន។ ដោយ សារតែប្រព័ន្ធនៃភាពជាចៅហ្វាយ មន្ត្រីសាធារណៈត្រូវប្រើលុយពុករលួយសូកចៅហ្វាយនាយ ដើម្បីរក្សាតំណែង ឬតម្លើង ឋានៈ។ មន្ត្រីទាំងនេះ បានចាយលុយពុករលួយ ដើម្បីបង្ហាញកិត្យានុភាពរបស់ពួកគេ សម្ភារៈនិយម និងដើម្បីបំពេញ សកម្មភាពកំសាន្តនានា ដូចជាលេងល្បែងជាដើម។ ពេលខ្លះមន្ត្រីទាំងនោះវិភាគទានលុយពុករលួយទៅបក្សនយោបាយ របស់ពួកគេ។

**ប្រភព:** *វ.ស.ក. ការស្ទង់មតិលើការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា - មេសា ២០០៦*

ដូចគ្នានេះដែរ សហគ្រិនម្នាក់ទៀតមានយោបល់ថា: *"មន្ត្រីរាជការតែងតែត្អូញត្អែរអំពីភាពមិនគ្រប់គ្រាន់នៃប្រាក់បៀវត្សរ៍។ ឥឡូវនេះ ពួកគាត់មានបៀវត្សរ៍វត្សរ៍គ្រប់គ្រាន់ហើយ ដូច្នេះ ពួកគាត់មិនអាចត្អូញត្អែរទៀតឡើយ។ ប្រសិនបើ ពួកគាត់ពុករលួយ យើងអាចដាក់ទណ្ឌកម្មគាត់តាមច្បាប់។ តម្លើងបៀវត្សរ៍ និងពង្រឹង ច្បាប់ប្រឆាំងនឹងអំពើពុករលួយនឹងធ្វើឱ្យការអនុវត្តច្បាប់កាន់តែប្រសើរ។ វាមិនអាចលុបអំពើពុករលួយទាំងអស់ទេ ប៉ុន្តែយ៉ាងហោចណាស់ក៏ជួយកាត់បន្ថយផងដែរ"*។

ប្រាក់ខែហាក់បីដូចជាចំណុចគ្រឹះរបស់បញ្ហានៃអំពើពុករលួយនៅប្រទេសកម្ពុជា។ យោងតាមក្រុមពិភាក្សានៅខេត្តក្រុងនានា សកម្មភាពចាំបាច់បំផុតដើម្បីប្រឆាំងនឹងអំពើពុករលួយក្នុងវិស័យឯកជន គឺត្រូវបង្កើនប្រាក់បៀវត្សរ៍មន្ត្រីរាជការ។ គ្មានបៀវត្សរ៍គ្រប់គ្រាន់ មន្ត្រីរាជការមិនអាចរស់បានទេ ដូចនេះពួកគាត់នឹងត្រូវតែពុករលួយដោយរកសំណូកពីវិស័យឯកជន។ យោងតាមមីក្រូសហគ្រាសសហគ្រាសធុនតូច និងមធ្យម បៀវត្សរ៍មានសារៈសំខាន់ណាស់សម្រាប់មន្ត្រីរាជការ ដោយសារជារឿយៗពួកគាត់ប្រឈមនឹងការចំណាយក្រៅផ្លូវការឱ្យមន្ត្រីសាធារណៈក្នុងអាជីវកម្មរបស់ពួកគាត់។

**ប្រអប់ ៤.២: គោលនយោបាយរដ្ឋអំពីបៀវត្សរ៍ និងការលើកទឹកចិត្តមន្ត្រីរាជការ**

នៅក្នុងយុទ្ធសាស្ត្រចតុកោណ រដ្ឋាភិបាលបានសន្យាបង្កើនបៀវត្សរ៍មន្ត្រីរាជការ ១០ ទៅ ១៥ ភាគរយដើម្បីបង្កើនជីវភាពរស់នៅរបស់ពួកគេអោយដល់កម្រិតសមរម្យមួយ។ ការប្តេជ្ញាចិត្តក្នុងការតម្លើងបៀវត្សរ៍នេះ បានអនុវត្តជាបណ្តើរៗហើយ។ ឧទាហរណ៍ តម្លៃនៃសន្ទស្សន៍បៀវត្សរ៍នៃមន្ត្រីរាជការត្រូវបានតម្លើងពី ៣០០ រៀល (ក្នុងឆ្នាំ ២០០២) ទៅ ៣៤៥ រៀល (ក្នុងឆ្នាំ ២០០៥) និង ៤០០ រៀល (ក្នុងឆ្នាំ ២០០៦)។ ក្នុងខែសីហា ឆ្នាំ ២០០៥ រដ្ឋាភិបាលក៏បានបង្កើនប្រាក់មុខងារឱ្យដល់បុគ្គលិករដ្ឋបាលថ្នាក់កណ្តាល និងជាន់ខ្ពស់ និងវិស័យអាទិភាពនានា (អប់រំ និងសុខភាព) ផងដែរ។

ជាធម្មតា បៀវត្សរ៍សរុបរបស់មន្ត្រីរាជការទាំងអស់រួមមាន បៀវត្សរ៍ស្ថូលរបស់ពួកគាត់បូកនឹងប្រាក់បំណាច់ដទៃទៀត (អាស្រ័យលើមុខងារ ហានិភ័យ និងប្រាក់បំណាច់គ្រួសារ)។ ចំនួនសន្ទស្សន៍ត្រូវបានអនុវត្តតាមលំដាប់ខាងក្រោម:មន្ត្រីរាជការប្រភេទ ឃ មានសន្ទស្សន៍ពី ១០០ ទៅ ១៧៥ មន្ត្រីរាជការប្រភេទ គ មានសន្ទស្សន៍ពី ១៥០ ទៅ ២៦២ មន្ត្រីរាជការ ប្រភេទ ខ មានសន្ទស្សន៍ពី ២២០ ទៅ ៣៨០ មន្ត្រីរាជការប្រភេទ ក មានសន្ទស្សន៍ពី ៣១៥ ទៅ ៥៥០ ។

បន្ថែមពីនេះ កាលពីដើមឆ្នាំ ២០០២ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល (CAR) គ្រោងអនុវត្តក្រុមបេសកកម្មអាទិភាព (PMG) ដើម្បីផ្តល់ការលើកទឹកចិត្តដល់មន្ត្រីរាជការ ១ ០០០ នាក់ ដែលបំពេញការងារក្នុងប្រភេទជាន់ខ្ពស់ "ក" (ថ្នាក់នយោបាយ និងថ្នាក់រដ្ឋបាលជាន់ខ្ពស់)។ គេក៏គ្រោងតម្លើងឱ្យមន្ត្រីរាជការ ៥០០ នាក់ទៀត រៀងរាល់ឆ្នាំរហូតដល់ឆ្នាំ ២០០៥ ឱ្យដល់កំរិតក្រុមបេសកកម្មអាទិភាព (PMG)។ ជាមធ្យមប្រភេទជាន់ខ្ពស់ "ក" និងមន្ត្រីរាជការក្នុង

**ប្រអប់ ៤.២: គោលនយោបាយរដ្ឋអំពីប្រាក់បៀវត្សរ៍ និងការលើកទឹកចិត្តមន្ត្រីរាជការ (តពីខាងលើ)**

ក្រុមអាទិភាពទទួលបានប្រាក់បៀវត្សរ៍ប្រហែល ២០០ ដុល្លារអាមេរិក ប៉ុន្តែ ក្នុងឆ្នាំ ២០០៥ សមាជិកក្រុម បេសកកម្មអាទិភាព (PMG) មានតែ ១២០៥ នាក់ ប៉ុណ្ណោះ ខណៈដែលក្រសួងជាច្រើនមិនទាន់បានបញ្ជូលឈ្មោះ បុគ្គលិកទៅក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល (CAR) នៅឡើយ។ មកដល់ពេលនេះ គឺមានតែមន្ត្រីរាជការ ៥៦០ នាក់ទេ ដែលទទួលប្រយោជន៍ពីក្រុមបេសកកម្មអាទិភាព (PMG)។ កម្មវិធីក្រុមបេសកកម្មអាទិភាពនេះមិនទាន់បានបញ្ចប់នៅ ឡើយទេ។

ទោះបីជារដ្ឋាភិបាលខិតខំតម្លើងប្រាក់បៀវត្សរ៍ឱ្យមន្ត្រីរាជការក្តី គេបានវាយតំលៃថាប្រាក់បៀវត្សរ៍នេះមិនគ្រប់គ្រាន់ទេ។ ថ្មីៗនេះ សមាគមគ្រូបង្រៀនឯករាជ្យដែលអះអាងថាមានសមាជិកប្រហែល ៧៨ ០០០ នាក់ ព្រមានថានឹងធ្វើកូដកម្ម ទាមទារតម្លើង ប្រាក់បៀវត្សរ៍ដល់គ្រូបង្រៀនពីជាមធ្យម ២៥ ដុល្លារអាមេរិក ទៅដល់ ១០០ ដុល្លារអាមេរិកក្នុងមួយខែ។ ជាការឆ្លើយតបនឹងតំរូវការនេះ រដ្ឋាភិបាលលើកបញ្ហាថវិកាមានកំណត់ជាអំណះអំណាង និងនិយាយថាអ្វីដែលរដ្ឋាភិបាលអាចធ្វើបាន គឺតម្លើងប្រាក់បៀវត្សរ៍ បន្តិចបន្តួចក្នុងមួយឆ្នាំ។

ប្រភព: *យុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល អនុក្រឹត្យលេខ ០៣ ចុះថ្ងៃទី ១៥ មករា ២០០៥ អនុក្រឹត្យលេខ ១៤០ ចុះថ្ងៃទី ០៩ ធ្នូ ២០០៥ - សារព័ត៌មាន ឌឹ ខែមបូឌា ដេលី ផ្សាយថ្ងៃ ២០ មិថុនា ២០០៦ ខួបទី ៣៤ ច្បាប់ទី ៦២ ទំព័រ ៦២— ទស្សនាវដ្តីឃ្លាំមើលសេដ្ឋកិច្ចកម្ពុជា របស់វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា លេខ ៣ ទំព័រ ៦១ - ទស្សនាវដ្តីឃ្លាំមើលសេដ្ឋកិច្ចកម្ពុជារបស់វិទ្យាស្ថានសេដ្ឋកិច្ច កម្ពុជា លេខ ៤ ទំព័រ ៧ - និងគេហទំព័ររបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល: http://www.car.gov.kh/document/report/achievement_CAR_brief_310506_kh.asp*

ដូចគ្នាដែរ មន្ត្រីដែលបានសម្ភាសមួយចំនួនធំជឿជាក់ថា តម្លើងប្រាក់បៀវត្សរ៍ជាវិធានការណ៍ប្រកបដោយប្រសិទ្ធភាពក្នុងការបន្ថយអំពើពុករលួយ។ ពួកគាត់ជឿថាមន្ត្រីរាជការជាច្រើននៅមានសីលធម៌នៅឡើយ។ មន្ត្រីសាធារណៈម្នាក់បាននិយាយថា *"ទោះបីជាយើងមិនអាចបញ្ឈប់អំពើពុករលួយនៅពេលដែលមានការតម្លើងប្រាក់បៀវត្សរ៍ក្តី ក៏គេអាចបន្ថយអំពើពុករលួយបានដែរ"*។ ប្រសិនបើប្រាក់បៀវត្សរ៍អាចឆ្លើយតបបានតម្រូវការចាំបាច់របស់មន្ត្រីសាធារណៈសាមញ្ញដែលពាក់ព័ន្ធនឹងអំពើពុករលួយសម្រាប់តែរស់ អំពើពុករលួយបែបនេះនឹងត្រូវបានទប់ស្កាត់បានយ៉ាងច្រើន។

ប្រធានឃុំម្នាក់លើកឡើងថា *"សំរាប់មន្ត្រីថ្នាក់ទាប ពួកមានការអៀនខ្មាស់ក្នុងការទទួលចំណាយក្រៅផ្លូវការ ប៉ុន្តែពួកគាត់គ្មានជំរើសណាក្រៅតែពីពុករលួយដើម្បីទ្រទ្រង់ជីវភាព។ ប្រាក់បៀវត្សរ៍គ្រប់គ្រាន់នឹងជំរុញឱ្យពួកគាត់ឈប់ប្រព្រឹត្តិអំពើពុករលួយ ពីព្រោះពួកគាត់មិនចង់ទទួលការមើលងាយពីពលរដ្ឋឡើយ"* ។ មន្ត្រីម្នាក់ទៀតក៏និយាយថា: *"ប្រាក់បៀវត្សគ្រប់គ្រាន់ក៏ជំរុញការអនុវត្តច្បាប់ និងវិន័យដែរ ដូចនេះពួកគាត់ក៏មិនហ៊ានប្រព្រឹត្តិខុសនឹងច្បាប់ដែរ ដោយសារពួកគាត់អាចនឹងបាត់បង់ការងារ"*។ ទោះបីយ៉ាងនេះក្តី គួរកត់សំគាល់ថា តម្លើងប្រាក់បៀវត្សរ៍តែឯងមិនអាចទប់ស្កាត់អំពើពុករលួយបានទេ។

សំណួរដែលចោទឡើងគឺថា តើប្រាក់ខែចំនួនប៉ុន្មានដែលអាចចាត់ទុកថាគ្រប់គ្រាន់សម្រាប់មន្ត្រីរាជការ? មន្ត្រីសាធារណៈដែលបានសម្ភាស ភាគច្រើនជឿជាក់ថាប្រាក់បៀវត្សរ៍ ១០០ ដុល្លារអាមេរិកក្នុងមួយខែ គឺគ្រប់គ្រាន់សម្រាប់មន្ត្រីសាធារណៈសាមញ្ញ ក្នុងការឆ្លើយតបចំពោះតម្រូវការចាំបាច់របស់គ្រួសារពួកគាត់។ ទោះបីយ៉ាងនេះក្តី មន្ត្រីមួយចំនួនតូចមានទស្សនៈថា បៀវត្សរ៍គួរចាប់ពី ១៥០ ទៅ ២០០ ដុល្លារអាមេរិក ទើបគ្រប់គ្រាន់ក្នុងជីវភាពរស់នៅ។

តើធ្វើដូចម្តេចតម្លើងបៀវត្សរ៍មន្ត្រីរាជការទៅនឹងសំណូមពររបស់ពួកគាត់? សហគ្រិនភាគច្រើនយល់ថា វាជាការលំបាកបន្តិចសំរាប់ឱ្យរដ្ឋាភិបាលតម្លើងបៀវត្សរ៍ឱ្យមន្ត្រីរាជការ ដោយសារតែកម្សោយក្នុងការប្រមូលចំណូលរដ្ឋ។ ពួកគាត់ជឿថា ដើម្បីដោះស្រាយបញ្ហា រដ្ឋាភិបាលគួរពង្រឹងការប្រមូលពន្ធដើម្បីបង្កើនចំណូលរបស់ខ្លួន។

## ៤.៣. ការជំរុញអោយមានអភិបាលកិច្ចល្អ និងសីលធម៌

អភិបាលកិច្ចល្អមានតួនាទីសំខាន់ក្នុងការទប់ស្កាត់អំពើពុករលួយ យោងតាមអាជីវករ។ ការផ្តល់អភិបាលកិច្ចល្អដល់អាជីវកម្មអាចធ្វើឡើងតាមរយៈប្រព័ន្ធមួយដែលអាជីវករ និងមន្ត្រីសាធារណៈអាចធ្វើការជាមួយគ្នាយ៉ាងងាយស្រួល ឧទាហរណ៍សេវាកម្មបង្អួចមួយសម្រាប់ពន្ធដារ អាជ្ញាបណ្ណ និងសេវាកម្មដទៃទៀតដែលពាក់ព័ន្ធ។ គេលើកឡើងជាញឹកញាប់អំពី "*សេវាកម្មបង្អួចមួយ*" នៅពេលដែលមន្ត្រីសាធារណៈ និង មីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម និយាយអំពីការកាត់បន្ថយអំពើពុករលួយ។

ក្នុងបរិបទនៃអភិបាលកិច្ចល្អនេះដែរ មន្ត្រីជាច្រើនជឿថា សហគ្រិនគួរទទួលបានព័ត៌មានអំពីបទបញ្ញត្តិ ច្បាប់ នីតិវិធី និងព័ត៌មានអំពីអាជីវកម្ម ដោយចំណាយតិច។ ក្រៅពីនេះ ច្បាប់ និងបទបញ្ញត្តិអំពីអាជីវកម្មមិនគួរមានភាពស្មុគ្រស្មាញ និងគួរសមស្របតាមបរិយាកាសអាជីវកម្ម ដើម្បីអោយវិស័យឯកជនគោរពតាមយ៉ាងងាយស្រួល។ ឧទាហរណ៍ រដ្ឋាភិបាលគួរធ្វើកំណែទម្រង់លើការទទួលខុសត្រូវជាន់គ្នារបស់ក្រសួងពាក់ព័ន្ធ។

ដើម្បីជំរុញអោយមានអភិបាលកិច្ចល្អ ទាំងមន្ត្រីសាធារណៈ និង មីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម គិតថា វាមានសារៈសំខាន់ក្នុងការផ្សព្វផ្សាយការចំណាយផ្លូវការទាំងអស់ ដែលអាជីវករត្រូវចំណាយ និងចំណាយឱ្យអ្នកណា ហើយចំណាយទាំងអស់ត្រូវផ្សព្វផ្សាយឱ្យអាជីវកម្មទាំងអស់ដឹង។ ការពង្រីកការយល់ដឹងរបស់អាជីវករ អំពីបទប្បញ្ញត្តិដែលពាក់ព័ន្ធ និងការលើកទឹកចិត្តពួកគេឱ្យគោរពច្បាប់ទាំងនោះជាការចាំបាច់។

អនុសាសន៍ទាំងនេះនឹងផ្តល់ប្រយោជន៍ដល់ទាំងរដ្ឋបាលសាធារណៈ និងទាំងសហគ្រិនក្នុងការង្កើនល្បឿនការងារ។ គុណប្រយោជន៍ចំពោះរដ្ឋបាលសាធារណៈ គឺបង្កើនពន្ធរដ្ឋ និងចំណូលមិនមែនពន្ធ ចំណែក

ឯចំពោះអាជីវកម្មវិញ គឺអាចចំណាយពេលតិចក្នុងការបំពេញពន្ធ និងកាតព្វកិច្ចអាជីវកម្មរបស់ខ្លួនតាមរយៈរដ្ឋបាលសាធារណៈនេះ។ ម្យ៉ាងវិញទៀត នីតិវិធីច្បាប់ និងបទបញ្ញត្តិស្មុគស្មាញគួរត្រូវបានកាត់បន្ថយ។ សហគ្រិននៃមីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម ម្នាក់និយាយថា: *"ខ្ញុំចង់ឱ្យរដ្ឋាភិបាលបង្កើតប្រព័ន្ធមួយ ដែលតម្រូវឱ្យយើងបង់អ្វីៗទាំងអស់នៅកន្លែងតែមួយ។ ខ្ញុំមិនចង់ខ្ជះខ្ជាយពេលវេលាធ្វើដំណើរពីកន្លែងមួយទៅមួយនោះទេ"*។

### ប្រអប់ ៤.៣: ការិយាល័យបង្អួចមួយនៅស្រុកបាត់ដំបង និងសៀមរាប

ដោយទទួលបានជំនួយបច្ចេកទេសពីគម្រោង EU/Asia Urbs ផ្តល់មូលនិធិដោយសហគមន៍អឺរ៉ុប តាមរយៈ Konrad Adenueur ការិយាល័យសេវាកម្មបង្អួចមួយនៅស្រុក ២ (ស្រុកបាត់ដំបង និងសៀមរាប) នៃខេត្តបាត់ដំបង និងខេត្ត សៀមរាប ដែលជាគម្រោងសាកល្បងត្រូវបានបើកដោយប្រកាសលេខ ៧៩២ របស់ក្រសួងមហាផ្ទៃ។ គោលបំណងសំខាន់របស់ការិយាល័យនេះ គឺជួយជំរុញអភិបាលកិច្ចល្អ និងកំណែទម្រង់រដ្ឋបាល សម្រាប់ផ្តល់សេវាកម្មរដ្ឋបាលដល់ប្រជាពលរដ្ឋ។ ឋិតក្រោមសេវាកម្មបង្អួតមួយនេះ សេវាកម្មរដ្ឋបាលត្រូវបានប្រមូលផ្តុំក្រោមសមត្ថកិច្ចរបស់ស្រុកបាត់ដំបង និងសៀមរាប ហើយត្រូវផ្តល់ឱ្យពលរដ្ឋតាមទ្វារតែមួយគត់។

រចនាសម្ព័ន្ធរបស់ការិយាល័យបង្អួតមួយរបស់ស្រុកទាំង ២ នេះគឺថា ការិយាល័យនេះត្រូវបែងចែកជា ការិយាល័យជួរមុខដែលទទួលដោះស្រាយបញ្ហារកស៊ីជាមួយពលរដ្ឋទាំងអស់ និងការិយាល័យជួរក្រោយដែលមានអ្នកជំនាញការនៃផ្នែកនានាធ្វើការ។ សារៈសំខាន់នៃសេវាកម្មបង្អួតមួយគឺថា រាល់ការចំណាយដែលពាក់ព័ន្ធត្រូវបានផ្សព្វផ្សាយតាមលក្ខណៈតម្លាភាព។ សេវាកម្មនៃការិយាល័យបង្អួតមួយរួមមាន:

- វប្បធម៌ និងវិចិត្រសិល្បៈ (អាជ្ញាប័ណ្ណសម្រាប់អ្នកថតរូប ឬហាងជួលថតវីដេអូ)
- ទេសចរណ៍ (អាជ្ញាប័ណ្ណសម្រាប់ផ្ទះសំណាក់ដែលមានបន្ទប់ដល់ទៅ ៥ និង
  ភោជនីយដ្ឋានដែលមានកៅអីដល់ទៅ ៥០)
- ការដឹកជញ្ជូន (ការចុះបញ្ជីម៉ូតូ និងយានយន្ត)
- វិស័យឧស្សាហកម្ម រ៉ែ និងថាមពល (អាជ្ញាប័ណ្ណ និងបទបញ្ញត្តិអំពីហាងលក់វត្ថុសិប្បកម្ម និងអាជីវកម្មក្នុងវិស័យរ៉ែ)
- ពាណិជ្ជកម្ម (ការចុះបញ្ជីអាជីវកម្ម)

យោងតាមប្រធាននាយកដ្ឋានឧស្សាហកម្ម រ៉ែ និងថាមពលប្រចាំខេត្តសៀមរាប ប្រជាជននៅស្រុកសៀមរាបមានការភ្ញាក់ផ្អើលដោយឃើញការចំណាយផ្លូវការត្រូវបានគេផ្សព្វផ្សាយ ហើយចំនួនដែលពួកគេបង់លើសេវាកម្មសាធារណៈតិចជាងកាលពីមុន។ ការចូលរួមពីប្រជាជនក្នុងការប្រើប្រាស់សេវាកម្មសាធារណៈមានការកើនឡើង។ សម្រាប់នាយកដ្ឋានឧស្សាហកម្មប្រចាំខេត្តសៀមរាបតែមួយ សេវាកម្មសាធារណៈបានកើនឡើងដល់ទៅ ៥៥ ភាគរយ។

**ប្រអប់ ៤.៣: ការិយាល័យបង្គួចមួយនៅស្រុកបាត់ដំបង និងសៀមរាប (តពីខាងលើ)**

ថ្មីៗនេះ ពង្រាងអនុក្រឹត្យអំពីសេវាកម្មបង្គួតមួយដែលរៀបចំដោយលេខាធិការក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលរបស់គណរដ្ឋមន្ត្រី ត្រូវបានពិនិត្យ និងពិភាក្សាដោយក្រុមប្រឹក្សានេះ បន្ទាប់ពីកិច្ចប្រជុំអន្តរក្រសួងចំនួន ២ ដងរួចមក។ គេរំពឹងថាពង្រាងអនុក្រឹត្យនេះ នឹងត្រូវអនុម័តដោយគណរដ្ឋមន្ត្រីក្នុងខែ កក្កដា ឆ្នាំ ២០០៦ ។

ប្រភព: *បទសម្ភាសន៍ លោក សូរី រង្សី អនុប្រធានការិយាល័យសេវាកម្មបង្គួចមួយ និងកិច្ចសម្ភាសន៍ នឹងលោក ថ្នាច ស៊ីណា ប្រធាននាយដ្ឋានឧស្សាហកម្ម រ៉ែ និងថាមពល ប្រចាំខេត្តសៀមរាប*

វិធានការណ៍បន្ថែមមួយទៀត ដើម្បីពង្រឹងអភិបាលកិច្ចល្អដែលលើកឡើងដោយមន្ត្រីសាធារណៈ គឺការផ្លាស់ប្តូរមន្ត្រីរាជការពីកន្លែងមួយទៅកន្លែងមួយទៀត។ ការផ្លាស់មន្ត្រីពីកន្លែងមួយទៅកន្លែងមួយ ក៏ជាមធ្យោបាយសំខាន់មួយ ដែលចូលរួមចំណែកក្នុងការពង្រឹងអភិបាលកិច្ចល្អ និងនាំអោយមានការកាត់បន្ថយអំពើពុករលួយដែរ។ មន្ត្រីរាជការម្នាក់ក្នុងខេត្តកំពង់ចាមបានមានប្រសាសន៍ថា *"មិនគួរទុកឱ្យនៅកន្លែងដដែលៗយូរឡើយ ដោយសារពួកគាត់អាចពង្រឹងបណ្តាញ និងបង្កើតឱកាសសំរាប់ពុករលួយ"* ។

លើសពីនេះទៀត ការគ្រប់គ្រងនិងត្រួតពិនិត្យពីមន្ត្រីថ្នាក់លើលើមន្ត្រីថ្នាក់ក្រោមអោយបានហ្មត់ចត់ មានសារៈសំខាន់ណាស់។ មន្ត្រីថ្នាក់ខ្ពស់គួរមានគោលនយោបាយច្បាស់លាស់ ការណែនាំ និងការត្រួតពិនិត្យតឹងតែងលើអ្នកក្រោមបង្គាប់។ សហគ្រិនម្នាក់លើកឡើងថា : *"គួរតែមានវិធីមួយដ៏មានប្រសិទ្ធិភាព ដើម្បីត្រួតពិនិត្យអ្នកក្រោមបង្គាប់ដែលពាក់ព័ន្ធនឹងអំពើពុករលួយ។ មន្ត្រីរាជការជាន់ខ្ពស់គួរទទួលខុសត្រូវចំពោះអំពើពុករលួយរបស់មន្ត្រីរាជការក្រោមឱវាទខ្លួន"*។

មីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម ក៏បានលើកអំពីអភិបាលកិច្ចល្អ តាមរយៈការជំរុញអោយមានប្រសិទ្ធិភាពនៃរដ្ឋបាលសាធារណៈ ដូចជាការជ្រើសរើស ការវាយតំលៃ និង ការតំឡើងឋានៈមន្ត្រីរាជការ។ មីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម ក៏បញ្ជាក់ផងដែរថា វាជាការចាំបាច់ក្នុងការពង្រឹងសមត្ថភាពរបស់មន្ត្រីរាជការ ដើម្បីអោយពួកគេអាចអនុវត្តតួនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងធានាអោយបានថា មន្ត្រីដែលទទួលបានការអប់រំខ្ពស់ និងមានសមត្ថភាពពិតប្រាកដ ទទួលបានឋានៈសមរម្យ ។ ការអនុវត្តចំណុចនេះមានសារៈសំខាន់ណាស់ ក្នុងការលុបបំបាត់អំពើបក្សពួកនិយម និងប្រព័ន្ធពុករលួយដែលមានភាពជាចៅហ្វាយ។ បន្ថែមលើនេះ វាក៏មានសារៈសំខាន់ផងដែរ ក្នុងការលើកតម្កើងមន្ត្រីស្មោះត្រង់ ដោយផ្អែកលើការអនុវត្តកាតព្វកិច្ចរបស់ពួកគេ។

**ប្រអប់ ៤.៤: តម្លាភាពក្នុងប្រព័ន្ធពន្ធដារ : ធ្វើឱ្យប្រព័ន្ធគណនេយ្យមានភាពសាមញ្ញ**

ថ្មីៗនេះ កាតព្វកិច្ចមួយក្នុងចំណោមកាតព្វកិច្ចនានាសម្រាប់សហគ្រាសកម្ពុជាត្រូវបានដាក់ឱ្យគោរពតាមបទដ្ឋានគណនេយ្យកម្ពុជា (CAS) និងប្រព័ន្ធសវនកម្មដែលតម្រូវដោយច្បាប់កម្ពុជា។ ទោះបីជាវិស័យឯកជនមានចំណែក ៨០ ភាគរយ ជាសហគ្រាសធុនតូច និងមធ្យមក្តី ក៏ សហគ្រាសដែលតូចៗមិនអាចអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្ម។ ជាទូទៅ គេអនុវត្តរបបពន្ធ ម៉ៅការ (ប្រព័ន្ធវាយតម្លៃ ផ្លូវការ) ចំពោះសហគ្រាសធុនតូច និងមធ្យម។ ប្រព័ន្ធនេះ មិនអនុញ្ញាតឱ្យមីក្រូសហគ្រាស និង សហគ្រាសធុនតូច និងមធ្យម ដឹងថាតើពួកគេត្រូវបង់ប៉ុន្មានទេចំពោះកាតព្វកិច្ចពន្ធដារ។

ដើម្បីលើកកម្ពស់ មីក្រូសហគ្រាស និងសហគ្រាសធុនតូចនិងមធ្យម ទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុ និងដើម្បីលើកកម្ពស់តម្លាភាពក្នុងប្រព័ន្ធពន្ធដារ ក្រុមប្រឹក្សាគណនេយ្យជាតិ គួរផ្តល់ប្រព័ន្ធគណនេយ្យបែបសាមញ្ញមួយឱ្យមីក្រូសហគ្រាស និងសហគ្រាសធុនតូចនិងមធ្យម អនុវត្តពីឆ្នាំ ២០០៧ ខាងមុខនេះ។ មិនត្រឹមតែ ចំណាយតិច និងអាចអនុវត្តបានទៀតនោះ ប្រព័ន្ធគនេយ្យសាមញ្ញនេះគួធ្វើឱ្យមីក្រូសហគ្រាស និងសហគ្រាសធុនតូចនិងមធ្យម ដឹងពីចំណូលរបស់ពួកគេ និងដឹងថា តើពួកគេត្រូវបង់ពន្ធប៉ុន្មាន ដោយគ្រាន់តែធ្វើការគណនាដ៏សាមញ្ញមួយ។

ដើម្បីឱ្យមីក្រូសហគ្រាស និងសហគ្រាសធុនតូចនិងមធ្យម ដឹងកាន់តែច្រើនពីប្រព័ន្ធគណនេយ្យនេះ ក្រុមប្រឹក្សាគណនេយ្យជាតិក៏គួរតែបង្កើនការយល់ដឹងរបស់មីក្រូសហគ្រាស និងសហគ្រាសធុនតូចនិងមធ្យម អំពីប្រព័ន្ធនេះតាមរយៈការផ្សព្វផ្សាយជាសាធារណៈ ការបណ្តុះបណ្តាល និងប្រព័ន្ធផ្សព្វផ្សាយ ។ល។

**ប្រភព:** *បទសម្ភាសន៍ជាមួយ ឯកឧត្តមសាស្ត្រាចារ្យ ងី តាយី អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាយកក្រុមប្រឹក្សា គណនេយ្យជាតិ*

ជាផ្នែកមួយនៃអភិបាលកិច្ចល្អដែរផងដែរនោះ គឺការរាយការណ៍ពីអំពើពុករលួយ។ រដ្ឋបាលសាធារណៈ គួរតែបង្កើតនូវប្រព័ន្ធមួយ ដែលអនុញ្ញាតអោយប្រជាជនអាចធ្វើការរាយការណ៍ពីអំពើពុករលួយនៅក្នុងករណីដែលវាកើតមានឡើង។ ការរាយការណ៍នេះ គួរតែធ្វើឡើងដោយសំងាត់ ហើយអ្នករាយការណ៍គួរតែត្រូវបានការពារ។ របាយការណ៍ ដែលធ្វើឡើងដោយពលរដ្ឋ គួរតែត្រូវចាត់វិធានការណ៍ អោយមានមុតមាំ ដើម្បឱ្យប្រជាជនមានទឹកចិត្តធ្វើការរាយការណ៍នៅពេលក្រោយ។ សហគ្រិនម្នាក់បានមានប្រសាសន៍ថា: *"ការបង្កើតប្រព័ន្ធមួយ ដែលអនុញ្ញាតឱ្យប្រជាជនអាចរាយការណ៍អំពីអំពើពុករលួយទៅអាជ្ញាធរមានសមត្ថកិច្ច អាចជាជំនួយមួយប្រកបដោយប្រសិទ្ធិភាពក្នុងការប្រឆាំងអំពើពុករលួយ"* ។

សីលធម៌មានសារៈសំខាន់ណាស់សម្រាប់បង្រៀនឱ្យស្អាតស្អំ។ មីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម ជឿជាក់ថា សីលធម៌ជាវិធីមួយដ៏សំខានសម្រាប់ទប់ស្កាត់អំពើពុករលួយ និងគួរត្រូវបានជំរុញ និងពង្រឹងឡើងតាមរយៈការអប់រំ។ ទាំងវិស័យឯកជន និងមន្ត្រីរាជការគួរតែត្រូវបានបង្រៀនអោយមានភាពស្មោះត្រង់ គំនិតស្នេហាជាតិ ស្មារតីជាតិនិយម និងមនសិការជាតិ។ សហគ្រិនម្នាក់និយាយថា: *"ការអប់រំដើរតួនាទីសំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ ប្រសិនបើសិស្សរៀនចេះពុករលួយចាប់*

*តាំងពីពេលចូលសាលា ពួកគេនឹងប្រព្រឹត្តដូចគ្នាពេលដែលចាប់ផ្តើមធ្វើការ។ អ្នកដែលទទួលការអប់រំតិច ជាទូទៅ ជាអកវងគ្រោះពីការកេងប្រវ័ញ្ច*"។

## ៤.៤. ការចូលរួមរបស់វិស័យឯកជន

មីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម ក៏ត្រូវបានសួរអំពីតួនាទីរបស់ពួកគាត់ក្នុងការជួយទប់ស្កាត់អំពើពុករលួយក្នុងវិស័យឯកជនផងដែរ។ ពួកគាត់អោយគំនិត ២ សំខាន់ៗ: ទី ១ ពួកគាត់ជឿថា ពួកគាត់អាចជួយកាត់បន្ថយអំពើពុករលួយ តាមរយៈការរក្សាភាពស្មោះត្រង់ចំពោះទឹកដីកំណើតរបស់ខ្លួនដោយចាប់ផ្តើមពីបុគ្គលម្នាក់ៗទៅ។ ដូចនេះ ប្រសិនបើគ្មាននរណាម្នាក់ពុករលួយទេនោះអំពើពុករលួយមិនអាចកើតមានបានឡើយ។ សហគ្រាសនីមួយៗក្នុងវិស័យឯកជន គួរចៀសវាងកុំផ្តល់សំណូក ដល់មន្ត្រីសាធារណៈ។ គំនិតនេះហាក់ដូចជាស្របនឹងយុទ្ធនាការ "*បាទដៃស្អាតស្អំ*" របស់ Pact ដែលធ្វើឡើងក្នុង ឆ្នាំ ២០០៥ ដែលអប់រំមនុស្សគ្រប់រូបឱ្យចៀសវាងអំពើពុករលួយ។ ក្នុងន័យនេះ ការអប់រំមានសារៈសំខាន់ណាស់ក្នុងការបង្រៀនក្មេងៗឱ្យស្អប់អំពើពុករលួយ និងក្លាយជាមនុស្សស្នេហាជាតិ ដែលមានសីលធម៌ និង ឧត្តមគតិខ្ពស់។

ទី ២ មីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម ភាគច្រើន យល់ស្របថា ពួកគាត់គួរចូលរួមក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដោយក្នុងនាមជាផ្នែកមួយនៃសហគមន៍ និងសមាគមប្រឆាំងអំពើពុករលួយ។ ពួកគាត់ជឿថា សំលេងតែម្នាក់របស់ពួកគាត់មិនខ្លាំងល្មមឱ្យមន្ត្រីសាធារណៈដោះស្រាយបញ្ហា និងផលប្រយោជន៍របស់ពួកគាត់ឡើយ។ សមាគមអាចនាំយកសំលេង និងការបារម្ភរបស់ពួកគាត់ឱ្យដល់អ្នកធ្វើគោលនយោបាយ។ សមាគមអាចមានឥទ្ធិពលទៅលើអាជ្ញាធរសាធារណៈក្នុងការពិចារណាអំពីបញ្ហារបស់ពួកគាត់ ដូចជាបញ្ហាពុករលួយ និងដោះស្រាយជួយបញ្ហាផ្សេងៗរបស់ពួកគាត់។ សមាគមដើរតួនាទីសំខាន់ ក្នុងការតស៊ូមតិជាមួយនឹងអាជ្ញាធរសាធារណៈ ដើម្បីការពារផលប្រយោជន៍របស់ពួកគាត់ និងទប់ស្កាត់អំពើពុករលួយ។

ទោះបីយ៉ាងនេះក្តី សមាគមដែលបង្កើតឡើងនេះគួរតែអព្យាក្រិត្យមិនពាក់ព័ន្ធនឹងនយោបាយ មានការរៀបចំល្អ និងការពារផលប្រយោជន៍ពិតប្រាកដរបស់សមាជិករបស់ខ្លួន ដើម្បីនិរន្តរភាព។ សមាគមនេះត្រូវការអ្នកដឹកនាំប្រកបដោយសមត្ថភាព និងការចូលរួម និងវិភាគទានពីសមាជិក។

បន្ថែមពីនេះ មីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម ភាគច្រើនជឿថា ពួកគាត់ត្រូវការការគាំទ្រពីរដ្ឋាភិបាល និងបរិយាកាសអនុគ្រោះ ដែលអនុញ្ញាតឱ្យពួកគាត់អាចប្រើប្រាស់សិទ្ធិដោយសេរីក្នុងការចចារ និងបង្កើតសមគម ដោយគ្មានការភ័យខ្លាច។ អ្នកពិភាក្សាមួយចំនួនមកពីខេត្តនានា បានសំដែងការព្រួយបារម្ភអំពីការចូលរួមក្នុងសមាគម ដោយនិយាយថា "*យើងមានការស្ទាក់ស្ទើរក្នុងការ*

*ចូលរួមក្នុងសមាគមនេះ។ វាមិនងាយស្រួលធ្វើដូច្នេះទេ។ អ្នកខ្លះខ្លាចពីសុវត្ថិភាពរបស់គេ។ មនុស្សជាច្រើនមិនចង់ធ្វើអ្វីដែលតម្រូវឱ្យពួកគាត់ផ្តិតមេដៃនោះទេ"។*

# សេចក្តីសន្និដ្ឋាន

អំពើពុករលួយក្នុងវិស័យឯកជនមានលក្ខណៈស្មុគ្រស្មាញ។ ទាំងសហគ្រាស និងទាំងមន្ត្រីសាធារណៈសុទ្ធតែបានពាក់ព័ន្ធនឹងអំពើពុករលួយ ដែលមានពាសពេញផ្ទៃប្រទេសដោយសារតែប្រព័ន្ធនៃភាពជាចៅហ្វាយនេះ និងបក្សពួក។

មន្ត្រីសាធារណៈ ដែលត្រូវធ្វើការជាមួយវិស័យឯកជន ជាញឹកញាប់ចុះទស្សនកិច្ចទីតាំងសហគ្រាស ក្រោមរូបភាពអធិការកិច្ចក្នុងគោលបំណងដើម្បីទារសំណូក។ ជាទូទៅ មន្ត្រីទាំងនេះរួមមានៈ ភ្នាក់ងារពន្ធដារ ប៉ូលីស អាជ្ញាធរមូលដ្ឋាន មន្ត្រីសុវត្ថិភាពអគ្គីភ័យនិងអាគារ មន្ត្រីបរិស្ថាន។ល។ ការិយាធិបតេយ្យស្មុគ្រស្មាញ និងកង្វះតម្លាភាពក្នុងបទបញ្ញត្តិ និងច្បាប់នានា ជាមូលហេតុមួយយ៉ាងសំខាន់នៃការរីករាលដាលអំពើពុករលួយ។

ទោះបីជា ទំហំនៃអំពើពុករលួយក្នុងវិស័យឯកជនហាក់បីដូចជាធ្លាក់ចុះ បើធៀបនឹងការវាយតម្លៃរបស់ធនាគារពិភពលោកក្នុងឆ្នាំ ២០០៤ ក៏ដោយ ក៏ទំហំនេះនៅតែខ្ពស់នៅឡើយ។ ដើម្បីទប់ស្កាត់អំពើពុករលួយ បញ្ហាឫសគល់ដែលនាំអោយមានអំពើពុករលួយទាំងនេះ គួរត្រូវតែដោះស្រាយ។ មូលហេតុចំបង៧នៃអំពើពុករលួយនៅក្នុងវិស័យឯកជននេះរួមមានៈ "ប្រាក់ខែទាបរបស់មន្ត្រីរាជការ" "កង្វះយន្តការប្រឆាំងនឹងអំពើពុករលួយ" "វប្បធម៌នៃអំពើពុករលួយ" "កង្វះឯករាជ្យភាពតុលាការនិងប្រសិទ្ធភាព" និង "ការអនុវត្តច្បាប់ខ្សោយ"។

ប្រសិនជាអំពើពុករលួយក្នុងវិស័យឯកជនត្រូវបានលុបបំបាត់ចំនួនប្រាក់ ដែលបាត់ដោយសារអំពើពុករលួយនេះ អាចយកមកប្រើឱ្យកាន់តែមានប្រសិទ្ធភាពជាងនេះទៅទៀតក្នុងការអភិវឌ្ឍ។ បរិមាណនៃការបាត់បង់នេះ (៣៣០ លានដុល្លារ ក្នុងឆ្នាំ ២០០៥) មានចំនួនលើសពីសេចក្តីត្រូវការចាំបាច់សម្រាប់យកទៅតម្លើងបៀវត្សរ៍មន្ត្រីរាជការដល់កម្រិត ជាមធ្យម ១០០ ដុល្លារអាមេរិក ក្នុងមួយខែ។ អំពើពុករលួយត្រូវកាត់បន្ថយ ឯសេវាសាធារណៈក៏កាន់តែមានប្រសិទ្ធភាព។

ជាងនេះទៅទៀត ដោយសារប្រព័ន្ធអំពើពុករលួយ រដ្ឋាភិបាលអាចប្រមូលពន្ធបានតែប្រហែល ២៥ ភាគរយ នៃចំណូលពន្ធសក្តានុពលសរុបប៉ុណ្ណោះ។ ការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការប្រមូលចំណូលរដ្ឋឱ្យបានកាន់តែច្រើន គួរផ្តោតលើការធ្វើឱ្យប្រព័ន្ធពន្ធដារមានលក្ខណៈសាមញ្ញ និងប្រកបដោយតម្លាភាពក្នុងការប្រមូលពន្ធ។ ប្រព័ន្ធមានលក្ខណៈសាមញ្ញ និងប្រកបដោយតម្លាភាព ធ្វើឱ្យសហគ្រាសឯកជនងាយយល់ និងជៀសវាងការបង់សំណូក។ ជាមួយគ្នានេះផងដែរ រដ្ឋាភិបាលគួរពិចារណាឡើងវិញពីអត្រាពន្ធដែលត្រូវបង់ដោយ មីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម ដើម្បីលើកទឹកចិត្តពួកគាត់ក្នុងការបង់ពន្ធ។

# ឯកសារយោង

**AAC & ILO.(2004):** *Study on legal requirements for micro and small businesses, NGOs, and associations and procedures and practices for exporting Cambodian handicrafts*

**CSD. (1998):** *National Survey on Public Attitude toward Corruption*

____ (2005): *Corruption and Cambodian households*

____ (2005): *Living under the rule of corruption, an analysis of everyday forms of corrupt practices in Cambodia*

**Economic Institute of Cambodia. (2006):** *Economic Watch*, Issue 4

____ *Economic Watch*, Issue 3

**Monyrath Nuth. (2005):** *Informal economy profile and suggestions for policy development in Cambodia*, draft final report, ILO & EIC

**MPDF. (2000):** *The private manufacturing sector in Cambodia: a survey of 63 firms*

**Pact. (2006):** *International Standards and the Draft Law on Anti-corruption*, slide presentation

**Transparency International. (2006):** *Corruption Perception Index*

**UNDP. (2005):** *Pathway to justice, access to justice with a focus on poor women and indigenous peoples.*

**UNIFEM, WB, ADB, UNDP and DFID/UK (2004):** *A fair share for women: Cambodia gender assessment*, 2004

**United Nations Office on Drugs and Crime, Regional Office for Southern Africa. (2003):** *Country Corruption Assessment Report*, South Africa

**USAID. (2004):** *Cambodian Corruption Assessment*

____ (2005): *Assessment of Corruption in Mongolia*, final report

**Vuthy Chan and Klara Sok. (2005):** *Cambodia Competitiveness Report 2005-2006*, EIC

**World Bank. (2000):** *Cambodia Governance and Corruption Diagnostic: Evidence from citizen, enterprise and public official surveys*

____ (2004): *Cambodia Seizing the Global Opportunity: Investment Climate Assessment & Reform Strategy*, 2004

**World Economic Forum. (2005):** *Global Competitiveness Report 2005-2006*

***Newspapers:***

**Cambodia Daily**, October 21, 2005, Vol. 32, issue 88

____ June 20, 2006, Volume 34, Issue 62, p. 12

______ May 29, 2006, Vol. 34, issue 46

______ June 20, 2006, Volume 34, Issue 62, p. 12

***Websites:***

**Council of Administrative Reform:**
http://www.car.gov.kh/document/report/achievement_CAR_brief_310506_kh.asp

**Transparency International:**
http://ww1.transparency.org/cpi/2005/2005.10.18.cpi.en.html#cpi

***Other sources:***

Government Rectangular Strategy

Law on Taxation 1997

Sub-decree No. 03, dated 15 January 2005;

Sub-decree No. 140 dated 09 December 2005;

Prakas on the Profit Tax 2004

# សេចក្តីបន្ថែម ១

# ប្រមើលមើលទស្សនវិស័យនៃបរិយាកាសអំពើពុករលួយ

## ១. សន្ទស្សន៍អំពើពុករលួយអន្តរជាតិ

ប្រទេសកម្ពុជា ត្រូវបានចាត់បញ្ចូលជាលើកដំបូងទៅក្នុងសន្ទស្សន៍ការយល់ដឹងអំពើពុករលួយ (CPI) នៅក្នុងឆ្នាំ ២០០៥ ដោយអង្គការអន្តរជាតិដើម្បីតម្លាភាព (Transparency International) ដែលជាអង្គការក្រៅរដ្ឋាភិបាលឈានមុខមួយ ក្នុងការប្រឆាំងអំពើពុករលួយ។ ដោយផ្អែកលើការស្ទង់មតិចំនួន ៤ ស្តីអំពីបរិយាកាសអាជីវកម្មដែលធ្វើឡើងដោយវេទិកាសេដ្ឋកិច្ចពិភពលោក (World Economic Forum) រួមជាមួយ និងវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (វ.ស.ក.) មជ្ឈមណ្ឌលស្រាវជ្រាវទីផ្សារពិភពលោក (World Market Research Center) ទស្សនាវដ្តីសេដ្ឋកិច្ច (Economist Magazine) និងក្រុមពាណិជ្ជករអន្តរជាតិ (Merchant International Group) នោះ[១] កម្ពុជាទទួលបានពិន្ទុ ២.៣ ដែលធ្វើអោយប្រទេសកម្ពុជាមានចំណាត់ថ្នាក់ទាបក្នុងតារាងសន្ទស្សន៍ ប្រហាក់ប្រហែលនឹងប្រទេសកំពុងអភិវឌ្ឍដទៃទៀត។អង្គការអន្តរជាតិដើម្បីតម្លាភាពបានចាត់ថ្នាក់ប្រទេសកម្ពុជា លេខ ១៣០ ក្នុងចំណោមប្រទេស ១៥៨[២] ខណៈពេលដែលប្រទេសជិតខាងយើងជាច្រើន ដែលមានដូចជា: ប្រទេសថៃ មានចំណាត់ ថ្នាក់លេខ ៥៩ ប្រទេសឡាវ មានចំណាត់ថ្នាក់លេខ ៧៧ ប្រទេសចិនមានចំណាត់ថ្នាក់លេខ ៧៨ និងប្រទេសវៀតណាមមានចំណាត់ថ្នាក់លេខ ១០៧។

ទោះជាយ៉ាងណាក៏ដោយ វិធីសាស្ត្រស្រាវជ្រាវដែលប្រើប្រាស់ដោយអង្គការអន្តរជាតិដើម្បីតម្លាភាព បាននាំអោយមានការចោទសួរពីទំនុកចិត្តរបស់ការវាយតំលៃនៃសន្ទស្សន៍យល់ដឹងអំពើពុករលួយ (CPI)នេះ។ ពួកអ្នករិះគន់តែងតែលើកពីកំហុសឆ្គងផ្នែកវិធីសាស្ត្រស្រាវជ្រាវសំខាន់ៗ ដែលត្រូវបានយកមកប្រើដើម្បីធ្វើចំណាត់ថ្នាក់អំពើពុករលួយរបស់ប្រទេសនីមួយៗ។ កំហុសឆ្គងទាំងនោះ រួមមាន: និយមន័យនៃអំពើពុករលួយរបស់ប្រទេសនីមួយៗមានលក្ខណៈផ្សេងៗគ្នា ដោយសារតែប្រទេសនីមួយៗមានឥរិយាបទខុសប្លែកពីគ្នាចំពោះអំពើពុករលួយ។ ម្យ៉ាងទៀត ទិន្នន័យដែលប្រើសំរាប់ធ្វើការប្រៀបធៀបអំពើពុករលួយសំរាប់ប្រទេសនីមួយៗ មានប្រភពផ្សេងៗគ្នាអាស្រ័យទៅលើប្រភពដែលអាចមាននៅក្នុងប្រទេសនីមួយៗ[៣]។

## ១. ទិន្នន័យមានស្រាប់មួយចំនួនស្តីពីអំពើពុករលួយនៅកម្ពុជា

ជាទូទៅអំពើពុករលួយនៅក្នុងប្រទេសកម្ពុជាបានក្លាយទៅជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា។ ប្រជាជនយល់ឃើញថា ប្រព្រឹត្តិអំពើពុករលួយនៅកម្ពុជា គឺមាននៅគ្រប់កំរិត ដែលមានចាប់តាំងពីមន្ត្រីសាធារណៈតូចតាចរហូតដល់មន្ត្រីកំពូលៗ ដែលមានពាសពេញស្ថាប័នសាធាណៈរបស់ប្រទេសនេះ។ មិន

[១] យោងតាមកាសែត ឌីឃែមបូឌាដែលី ចុះថ្ងៃទី ២១ តុលា ២០០៥ លេខ ៣២

[២] សូមមើលសន្ទស្សន៍យល់ដឹងអំពើពុករលួយទាំងស្រុងរបស់អង្គការអន្តរជាតិដើម្បីតម្លាភាពនៅគេហទំព័រ: http://ww1.transperancy.org/cpi/2005/2005.10.18.cpi.en.html#cpi, May 18, 2006

[៣] សូមមើលបន្ថែមនៅ USAID: របាយការណ៍ចុងក្រោយស្តីពីការវាយតំលៃនូវអំពើពុករលួយនៅម៉ុងហ្គោលី ឆ្នាំ ២០០៥ ទំព័រ ៨-៩

មានទូវភស្តុតាងច្បាស់លាស់ណាមួយ ដែលថាតើបញ្ហាអំពើពុករលួយបានកើនឡើង រឺធ្លាក់ចុះដោយមិនមានការស្រាវជ្រាវទៅលើអំពើពុករលួយដែលត្រូវបានគេធ្វើជាប្រចាំ។ ទោះបីជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវមួយចំនួនដែលបានធ្វើកន្លងមកហើយនោះ អាចបង្ហាញពីរូបភាពនៃអំពើពុករលួយនៅកម្ពុជា ទោះបីជា ពេលខ្លះលទ្ធផលនៃការស្រាវជ្រាវទាំងនោះ មិនមានភាពស៊ីសង្វាក់គ្នាក៏ដោយ។ ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបនៃការរកឃើញសំខាន់ៗរបស់ការសិក្សាមុនៗទៅលើអំពើពុករលួយ។

## ២.១. និដ្ឋភាពទូទៅនៃអំពើពុករលួយ

របាយការណ៍វាយតំលៃលើអំពើពុករលួយមួយ ដែលធ្វើឡើងដោយ Casals & Associates, Inc (C&A )ក្រោមការឧបត្ថម្ភពី USAID/Cambodia បង្ហាញនូវទិដ្ឋភាពដ៏ទូលំទូលាយមួយនៃអំពើពុករលួយនៅក្នុងប្រទេសកម្ពុជា [៤] ។ របាយការណ៍នោះក៏ពន្យល់អំពីរបៀប ដែលអំពើពុករលួយកើតមានឡើងនៅក្នុងប្រទេសកម្ពុជា។ បើយោងទៅតាមអ្នកនិពន្ធជាធម្មតាបរិយាកាសនៃអំពើពុករលួយនៅក្នុងប្រទេសកម្ពុជារួមបញ្ចូលនូវអំពើពុករលួយតូចតាចសម្រាប់ចិញ្ចឹមជីវិត។ អំពើពុករលួយតូចតាចនេះ កើតមានចំពោះប្រជាជនក្រីក្រ និងមធ្យម។ រីឯអំពើពុករលួយមានទ្រង់ទ្រាយធំវិញគឺ អំពើពុករលួយដើម្បីធ្វើមានបានរបស់មន្ត្រីដ៏មានឥទ្ធិពល។

អ្នកនិពន្ធបានប្រើប្រាស់ពាក្យធ្ងន់ៗជាច្រើនដូចជាពាក្យថា: "រដ្ឋមួយដែលប្រើអំពើពុករលួយដើម្បីមកដឹកនាំប្រទេស" ដើម្បីធ្វើការពិពណ៌នាអំពីស្ថានភាពអំពើពុករលួយ ដែលកើតមានឡើងដោយចាប់ផ្តើមពីការប្រមូលប្រាក់ចំណូលរដ្ឋ (តាមរយៈពន្ធដារ និងជំនួយបរទេស) ការគ្រប់គ្រងធនធានរដ្ឋរហូតដល់ការចែកចាយចំណាយសាធារណៈតាមរយៈការប្រើអំណាច និងប្រព័ន្ធមានលក្ខណៈជាបក្ខពួកនិយម។

ទោះបីជាយ៉ាងនេះក៏ដោយ របាយការណ៍លើកឡើងនូវបញ្ហាប្រឈមសំខាន់ៗក្នុងការប្រឆាំងនឹងអំពើពុករលួយដែលធ្វើឡើងដោយសង្គមស៊ីវិល វិស័យឯកជន ប្រព័ន្ធផ្សព្វផ្សាយ គណបក្សនយោបាយ អង្គការអន្តរជាតិនានាដែលជាពិសេស WTO និងកម្មវិធីផ្សេងៗ ដែលផ្តួចផ្តើមឡើងដោយសហគមន៍ផ្តល់ជំនួយដើម្បីជំរុញអោយស្ថាប័នសាធារណៈមានគណនេយ្យភាព និងតម្លាភាព។ អនុសាសន៍ជាច្រើនដើម្បីបំបាត់អំពើពុករលួយក្នុងប្រទេសកម្ពុជា ក៏ត្រូវបានផ្តល់ដល់ម្ចាស់ជំនួយនានាផងដែរ។

## ២.២. អំពើពុករលួយ និងប្រជាជន

---

[៤] USAID ការវាយតំលៃអំពើពុករលួយនៅកម្ពុជា ២00៤

មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) មានសកម្មភាពយ៉ាងសកម្មក្នុងការស្រាវជ្រាវបញ្ហានានាទាក់ទងនឹងសង្គម ជាពិសេសបញ្ហាអំពើពុករលួយ។ មជ្ឈមណ្ឌលនេះបានធ្វើការសិក្សាផ្សេងៗ ជាច្រើនលើអំពើពុករលួយ។

ការស្រាវជ្រាវលើកដំបូងរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមបានសិក្សាលើប្រធានបទ ឥរិយាបទរបស់សាធារណជនចំពោះអំពើពុករលួយ ដែលធ្វើឡើងនៅក្នុងឆ្នាំ១៩៩៨[៥] ។ លទ្ធផលនៃការស្រាវជ្រាវរួមមាន:

- ប្រជាជនកម្ពុជាភាគច្រើនជឿជាក់ថា អំពើពុករលួយគឺវាជារឿងទូទៅមួយ។ អំពើពុករលួយត្រូវបានគេទទួលស្គាល់ថាជាផ្នែកមួយនៃជំនួញដ៏ផ្លូវការ និងនៃទំនាក់ទំនងប្រចាំថ្ងៃក្នុងសង្គម។
- ទោះបីជាអំពើពុករលួយត្រូវបានទទួលថាជាទំលាប់ក៏ដោយ ក៏ប្រជាជនកម្ពុជាយល់ថាអំពើពុករលួយគួរតែត្រូវបញ្ចប់ ហើយប្រជាជនភាគច្រើនជឿថា ការបញ្ឈប់អំពើពុករលួយនៅក្នុងកំរិតថ្នាក់ខ្ពស់គឺជារឿងសំខាន់។
- មធ្យោបាយដែលត្រូវបានលើកឡើងដើម្បីបញ្ចប់នូវអំពើពុករលួយ មានផ្តល់ប្រាក់បៀវត្សរ៍ ដែលអាចអោយចិញ្ចឹមជីវិតបានដល់មន្ត្រីរាជការ និងការអនុម័តនូវបញ្ញត្តិប្រឆាំងអំពើពុករលួយ។

ការសិក្សាស្រាវជ្រាវមួយទៀត ធ្វើឡើងដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមនៅក្នុងឆ្នាំ ២០០៥[៦] ក៏បង្ហាញដែរថា ជាទូទៅ ប្រជាជនមិនយល់ថាអំពើពុករលួយគឺជាការគំរាមកំហែងដ៏ចំបងដល់ជីវភាពរបស់ពួកគេទេ។ ការចំណាយខ្ពស់ក្នុងជីវភាព ហេដ្ឋារចនាសម្ព័ន្ធអន់ថយ សុវត្ថិភាពសង្គម ការចំណាយខ្ពស់ និងគុណភាពទាបនៃការថែទាំសុខភាព ត្រូវបានរាប់ថាជាក្តីបារម្ភដ៏ធ្ងន់ធ្ងររបស់ប្រជាជន ជាពិសេសសំរាប់ប្រជាជន ដែលរស់នៅតំបន់ដាច់ស្រយាល។ ទាក់ទងទៅនឹងសំណួរ ដែលសួរថា អំពើពុករលួយកើតមានឡើងយ៉ាងណានោះ របាយការណ៍ស្រាវជ្រាវ ក៏បានបង្ហាញថា នៅពេលដែលមានសំណូក ជាធម្មតា អ្នកសូកគេជាអ្នកផ្តួចផ្តើមគំនិត។

ក្រៅពីនោះ របាយការណ៍ក៏បានរកឃើញដែរថា ទំនាក់ទំនងជាបុគ្គលជួយសម្រាលនូវការបំភិតបំភ័យ។ ទោះបីជាថាអំពើពុករលួយបានរីករាលដាលក៏ដោយ ក៏អំពើពុករលួយមិនបានទទួលយកបានទេបើគិតពីសីលធម៌វិញ។ ហើយប្រាក់ខែស្តួចស្តើងមិនអាចជាលេសអោយមន្ត្រីរាជការទទួលសំណូកនោះឡើយ។ ស្ថាប័នដែលមិនស្មោះត្រង់បំផុត គឺតុលាការ នាយកដ្ឋានពន្ធគយ និងនគរបាល ។ ស្ថាប័នដែលស្មោះត្រង់បំផុតគឺ: អង្គការក្រៅរដ្ឋាភិបាល សាលារៀន និងវត្តអារាម ។ សំខាន់ជាងនេះទៀត គ្រួសារនីមួយៗចំណាយលើអំពើពុករលួយអស់ប្រហែល ១,៤ ភាគរយនៃចំណាយសរុប។ សកម្មភាពជាអាទិភាពប្រឆាំងនឹងអំពើពុករលួយគួរតែជាការលុបបំបាត់នូវវដ្តបាលរបស់មន្ត្រីដែលប្រព្រឹត្តអំពើពុករលួយ។

---

[៥] CSD: ការសិក្សាស្រាវជ្រាវលើឥរិយាបទចំពោះអំពើពុករលួយឆ្នាំ ១៩៩៨

[៦] CSD : អំពើពុករលួយ និងប្រជាជនកម្ពុជា ឆ្នាំ ២០០៥

ការសិក្សាស្រាវជ្រាវបែបគុណភាពមួយទៀត ដែលធ្វើឡើងដោយ CSD នៅក្នុងឆ្នាំ ២០០៥[៧] ក៏បានផ្តល់នូវរបកគំហើញស្រដៀងគ្នាទៅនឹងការសិក្សាខាងលើនេះដែរ ។ របាយការណ៍នោះបង្ហាញថា ប្រជាជនសាមញ្ញ (ទាំងអ្នកផ្តល់សំណូក និងអ្នកទទួលសំណូក) បានលើកពីទុក្ខកង្វល់អំពីអំពើពុករលួយនៅប្រទេសកម្ពុជាដែលកង្វល់នោះ រួមមានៈ ការទទួលបាននូវសេវាកម្មពីស្ថាប័នសាធារណៈរបស់ប្រជាជនក្រីក្រ ដោយសារតែ កង្វះខាតនូវទំនាក់ទំនងជាមួយនឹងអ្នកកាន់អំណាចនានាក្នុងមូលដ្ឋាន ការប្រព្រឹត្តមិនយុត្តិធម៌របស់ស្ថាប័នសាធារណៈ ដោយសារតែកង្វះខាតនូវតម្លាភាពប្រព័ន្ធបក្ខពួកនិយមនៃអំពើពុករលួយ ឧបសគ្គដល់ការលើកទឹកចិត្តក្នុងការកែលំអជីវភាព ដោយសារតែកង្វះទំនុកចិត្តទៅលើក្នុងស្ថាប័នសាធារណៈ។

រឿងគួរអោយចាប់អារម្មណ៍ជាងនេះទៅទៀតនោះ គឺស្ត្រីត្រូវបានគេរកឃើញថាជាអ្នកបង់លុយពុករលួយដ៏សំខាន់ ដោយសារតែតួនាទីរបស់គេ ជាអ្នកមើលការខុសត្រូវលើការចំណាយ ក្នុងគ្រួសារ និងជាអ្នកមើលថែរក្សាគ្រួសារ។ លើសនេះទៅទៀត ប្រជាជនតែងតែប្រើប្រាស់ពាក្យចចាមអារ៉ាម និងការខ្សឹមខ្សៀវគ្នា ដើម្បីតបតទៅនឹងអំពើពុករលួយ រឺ ដើម្បីបញ្ចៀសអំពើពុករលួយខណៈពេលដែលមន្ត្រីរាជការប្រើប្រាស់នូវវិធីសាស្ត្រផ្ទាល់ ដូចជាការតវ៉ា រឺ ការទាក់ទងមន្ត្រីដែលមានឋានៈខ្ពស់ជាង ។ បញ្ហានេះ បានធ្វើអោយប្រជាជនក្រីក្រមិនអាចទទួលបាននូវសេវាសាធារណៈ។

បើយោងទៅតាមរបាយការណ៍ ដើម្បីដោះស្រាយបញ្ហានេះ ប្រជាពលរដ្ឋសូមអោយមានតម្លាភាពទាំងនៅក្នុងការិយាធិបតេយ្យថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ជាពិសេសសំណូមពរឱ្យមានការផ្សាយព័ត៌មាន និងការបង្កើនការយល់ដឹងអោយច្បាស់ពីនីតិវិធីសាធារណៈ ។ ក៏មានសំណូមពរឱ្យមានការអប់រំស្តីពីការចាត់ចែងអោយមានការចូលរួមរបស់ថ្នាក់មូលដ្ឋាននៅក្នុងគំរោងអភិវឌ្ឍន៍សហគមន៍។

ការសិក្សាក្នុងឆ្នាំ ២០០៥ របស់កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិមានចំណងជើងថា : "វិធីទៅកាន់យុត្តិធម៌ លទ្ធភាពទទួលបានយុត្តិធម៌" ក៏មាននិយាយអំពីអំពើពុករលួយដែរ[៨] ។ របាយការណ៍រកឃើញថា អំពើពុករលួយដែលប៉ះពាល់ដល់ស្ត្រីក្រីក្រនិងជនជាតិភាគតិចនៅកម្ពុជា គឺកើតតាមរូបភាពផ្សេងៗដែលរួមមានៈ ការខ្វះខាតនូវតម្លាភាព អំពើពុករលួយនៅក្នុងការគ្រប់គ្រងធនធានសាធារណៈ ដូចជាៈ ការសម្បទានដីធ្លី ធនធានធម្មជាតិ ការផ្តល់អាជ្ញាប័ណ្ណ អាជីវកម្ម កិច្ចការហេដ្ឋារចនាសម្ព័ន្ធ និងការសំរេចចិត្តខាងនយោបាយផ្សេងៗទៀតទៅលើធនធានសាធារណៈ សេវាកម្ម និងពន្ធដារ។ របាយការណ៍ក៏បង្ហាញពីមូលហេតុនៃការទារប្រាក់ខុសច្បាប់ ដោយមន្ត្រីរាជការដែលជាផ្នូរនៃការផ្តល់នូវសេវាសាធារណៈផងដែរ។ មូលហេតុនោះ គឺបណ្តាលមកពីប្រាក់ខែទាបរបស់មន្ត្រីរាជការ។ លុយក្រៅផ្លូវការ (ដែលបានរារាំងមិនអោយកុមារបានចូលរៀន រារាំងអ្នកក្រីក្រក្នុងការទទួលបាននូវសេវាសុខភាពសាធារណៈ និងរារាំងជនរងគ្រោះ

---

[៧] CSD: ជីវភាពនៅក្រោមការគ្រប់គ្រងរបស់អំពើពុករលួយ ការវិភាគលើគ្រប់រូបភាពនៃការប្រព្រឹត្តិអំពើពុករលួយនៅកម្ពុជាឆ្នាំ ២០០៥

[៨] UNDP វិថីឆ្ពោះទៅកាន់យុត្តិធម៌ លទ្ធភាពទទួលបានយុត្តិធម៌ ២០០៥ ទំព័រ ២

ពីបទល្មើសឧក្រិដ្ឋមិនឱ្យទទួលនូវការកោសល្យវិច័យដ៏ត្រឹមត្រូវ) ជាមូលហេតុធ្វើអោយប្រជាជនជួបប្រទះនឹងភាពក្រីក្រ។

## ២.៣. អំពើពុករលួយ និងវិស័យឯកជន

ការសិក្សាស្ទង់មតិមួយដោយធនាគារពិភពលោក ជាមួយនឹងប្រជាពលរដ្ឋ សហគ្រាស និងមន្ត្រីរាជការ បានឆ្លុះបញ្ចាំំពីអភិបាលកិច្ច និងអំពើពុករលួយនៅកម្ពុជា។ សេវាសាធារណៈជាច្រើន ជាពិសេស តុលាការ គយ អាជ្ញាធរពន្ធ សេវាផ្លូវ និងនគរបាលគឺនៅមានកំរិតអន់ខ្សោយ[៩]។ បញ្ហាចំបងរបស់ប្រជាពលរដ្ឋ និងសហគ្រាសគឺអំពើពុករលួយរបស់ស្ថាប័នសាធារណៈ។ កិច្ចប្រឹងប្រែង ដើម្បីអោយមានកំណែទំរង់ជាអាទិភាពគួរតែផ្តោតបន្ថែមទៅលើស្ថាប័នមួយចំនួនដូចជា ស្ថាប័ន តុលាការ អង្គភាពប្រមូលចំណូលរដ្ឋ និងអង្គភាពដែលគ្រប់គ្រងទ្រព្យរបស់រដ្ឋមិនបានល្អ។

មានទំនាក់ទំនងរវាងភាពទន់ខ្សោយនៃការបំពេញភារកិច្ចរបស់ភ្នាក់ងាររដ្ឋាភិបាល និងសុច្ចរិតភាពរបស់ខ្លួន។ ជាងនេះទៅទៀត ការគ្រប់គ្រងទន់ខ្សោយ បង្កឱ្យមានការបាត់បង់ចំណូលរដ្ឋ និងការគេចវេសកាតព្វកិច្ចពន្ធដារ និងគយ។ អំពើពុករលួយបង្អាក់អ្នកវិនិយោគមិនអោយវិនិយោគនៅកម្ពុជា។ មន្ត្រីរាជការយល់ថា ដើម្បីដោះស្រាយបញ្ហាអំពើពុករលួយ វិធានការណ៍មួយចំនួនមានសារៈសំខាន់ណាស់ៈ ការផ្តល់ប្រាក់ខែអាចចិញ្ចឹមជីវិតគ្រប់គ្រាន់សម្រាប់មន្ត្រីរាជការ ប្រព័ន្ធគ្រប់គ្រងជាបុគ្គលនៅក្នុងវិស័យសាធារណៈ (ការតំឡើងឋានៈ និងប្រាក់ខែដោយផ្អែកលើការអនុវត្តការងារ) ការត្រួតពិនិត្យមើលនូវមុខងាររបស់រដ្ឋាភិបាលដោយសាធារណជន និងសង្គមស៊ីវិល ការប្រកាសជាទៀងទាត់នូវទ្រព្យសម្បត្តិរបស់មន្ត្រីរាជការ។

ការសិក្សាមួយផ្សេងទៀតរបស់ធនាគារពិភពលោកទៅលើបរិយាកាសវិនិយោគនៅកម្ពុជា[១០] ក៏បានផ្តល់ព័ត៌មានអំពីអភិបាលកិច្ច និងអំពើពុករលួយ។ របាយការណ៍ក៏បានបញ្ជាក់ថា ក្រុមហ៊ុនភាគច្រើនយល់ស្របថា ដើម្បីឱ្យមន្ត្រីរាជការធ្វើការអោយខ្លួន ពួកគេត្រូវចំណាយលុយ។ របាយការណ៍បញ្ជាក់ថា ការចំណាយក្រៅផ្លូវការនៅប្រទេសកម្ពុជា មានចំនួនពីរដងច្រើនជាងការរកឃើញនៅក្នុងការសិក្សាស្រដៀងគ្នាមួយនៅប្រទេសបង់ក្លាដែស ប្រទេសប៉ាគីស្ថាន និងប្រទេសចិន។ ហើយបញ្ហាចំបងសំរាប់ក្រុមហ៊ុនក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធនៅទីក្រុង គឺអំពើពុករលួយ។ ជាទូទៅ ទំហំនៃការចំណាយក្រៅផ្លូវការដែលប៉ាន់ស្មានដោយវិស័យឯកជនមានចំនួនលើសពី ៥ ភាគរយនៃប្រាក់ចំណូលប្រចាំឆ្នាំរបស់ពួកគេហើយក៏អាចលើសពី ៦ ភាគរយនៃតំលៃលក់សរុបសម្រាប់ក្រុមហ៊ុនធំៗ ដោយអាស្រ័យលើទំហំក្រុមហ៊ុន និងភាពផ្លូវការរបស់ក្រុមហ៊ុននីមួយៗ។

---

[៩] World Bank Cambodia Governance and Corruption Diagnostic: Evidence from citizen, enterprise and public

[១០] World Bank, Cambodia Seizing the Global Opportunity: Investment Climate Assessment & Reform Strategy, 2004, p.14-15

**តារាង A១.១. ការប៉ាន់ស្មានការចំណាយក្រៅផ្លូវការ (គិតជា %នៃចំណុលពីការលក់)**

| ក្រុមហ៊ុនបរទេស | ក្រុមហ៊ុនធំ | សហគ្រាសធុនតូច និងមធ្យម | មីក្រូសហគ្រាស | ក្រុមហ៊ុនក្រៅប្រព័ន្ធនៅទីក្រុង | ក្រុមហ៊ុនមិនមែនកសិកម្មនៅជនបទ |
|---|---|---|---|---|---|
| ៦,៩០ % | ៦,១០% | ៥,៥០% | ៤,00% | ២,៣0% | ១,៣0% |

ប្រភព: *ធនាគារពិភពលោក កម្ពុជាក្នុងការច្បាមយកឱកាសវិនិយោគ: ការវាយតំលៃបរិយាកាសវិនិយោគ និងយុទ្ធសាស្រ្តកំនែទំរង ២០០៤ ទំព័រ ១៥*

លើសពីនេះ វេទិកាសេដ្ឋកិច្ចពិភពលោក (WEF)ដែលជាស្ថាប័នឈានមុខមួយនៅក្នុងការវាយតំលៃពីលទ្ធភាពប្រកួតប្រជែងរបស់ប្រទេសក្នុងពិភពលោកដោយសហការជាមួយនឹងវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ក៏បានធ្វើការសិក្សាស្រាវជ្រាវជាមួយនឹងនាយកប្រតិបត្តិជាច្រើននៅក្នុងប្រទេសកម្ពុជា។ លទ្ធផលបានដាក់ចំណាត់ថ្នាក់សន្ទស្សន៍នៃលទ្ធភាពប្រកួតប្រជែងរបស់ប្រទេសកម្ពុជានៅលេខរៀងទី ១១២ ក្នុងចំណោមប្រទេស ១១៧[១១]។ លទ្ធផលក៏បានបង្ហាញដែរថា អំពើពុករលួយ គឺជាកត្តាចំបងបំផុតក្នុងការធ្វើពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជា[១២]។

ផ្ទុយទៅវិញ ការសិក្សាស្រាវជ្រាវលើក្រុមហ៊ុនចំនួន ៦៣ នៅក្នុងវិស័យផលិតកម្មដែលធ្វើឡើងដោយ MPDF[១៣] នៅក្នុងឆ្នាំ ២000 នោះបានបង្ហាញថា: មានក្រុមហ៊ុនតិចតួច ប៉ុណ្ណោះដែលលើកឡើងថាអំពើពុករលួយថាឧបសគ្គមួយចំបងសំរាប់ពាណិជ្ជកម្មរបស់ខ្លួន។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ក្រុមហ៊ុនទាំងនោះយល់ថាអំពើពុករលួយគឺជារឿងធម្មតាមួយនៅក្នុងបរិយាកាសអាជីវកម្ម។ ទោះជាយ៉ាងនេះ ក៏ក្រុមហ៊ុនជាច្រើនបានអះអាងថា មន្ត្រីរាជការជាច្រើនបានទៅពិនិត្យក្រុមហ៊ុនខ្លួនជាប្រចាំ។ មន្ត្រីរាជការទាំងនោះ មានចាប់ពីមន្ត្រីមូលដ្ឋានរហូតទៅដល់មន្ត្រីថ្នាក់ក្រសួងដែលរួមមាន: ប៉ូលីសមូលដ្ឋាន យោធា បុគ្គលិកក្នុងការិយាល័យ។

ការសិក្សាស្រាវជ្រាវរបស់ MPDF បានរកឃើញថា ការសូកប៉ាន់មានសារៈសំខាន់ដើម្បីគេចវេសពីបទបញ្ញត្តិនានា។ វិស័យឯកជនចាំបាច់ត្រូវផ្តល់សំណូកដល់មន្ត្រីរាជការដើម្បីអោយមន្ត្រីទាំងនោះបំពេញកិច្ចការរបស់ខ្លួនឧទាហរណ៍ការងារទាក់ទងនឹងការចុះបញ្ជី ការធ្វើអធិការកិច្ចការរៀបចំឯកសារ....។ល។

---

11 World Economic Forum, Global Competitiveness Report 2005-2006, September 2005.

12 ចាន់វុទ្ធី និង អ្នកដទៃ:"របាយការណ៍ភាពប្រកួតប្រជែងកម្ពុជា ២០០៥-២០០៦" ទំព័រទី ២០ ដោយ វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា

13 MPDF, the private manufacturing sector in Cambodia: a survey of 63 firms, 2000.

# សេចក្តីបន្ថែម ២

# វិធីសាស្ត្រក្នុងការសិក្សា

បញ្ហាអំពើពុករលួយត្រូវបានប្រជាពលរដ្ឋទូទៅទទួលស្គាល់ និងសាយភាយពាសពេញប្រទេសកម្ពុជា។ ប្រជាពលរដ្ឋបាននិយាយថា *"អំពើពុករលួយកើតឡើងគ្រប់ថ្នាក់ទាំងអស់។ អ្នកធំស៊ីតាមធំ អ្នកតូចស៊ីតាមតូច"*។ ទោះបីជាវិស័យឯកជនទទួលស្គាល់ថា មានអំពើពុករលួយក៏ដោយ ក៏នៅពេលយើងសម្ភាសជាមួយអ្នកដែលពាក់ព័ន្ធនឹងអំពើពុករលួយនេះ ទាំងអ្នកទទួល និងទាំងអ្នកផ្តល់សំណូកព្យាយាមលាក់បាំងការជាប់ពាក់ព័ន្ធរបស់គេដែរ។ បញ្ហានេះបង្កការលំបាកដល់ការសិក្សាវាស់វែងអំពើពុករលួយទាំងនេះ។

ដោយមើលឃើញបញ្ហាទាំងនេះហើយ វិធីសាស្ត្រជាច្រើនត្រូវបានអនុវត្តក្នុងការសិក្សានេះ ក្នុងគោលបំណងដើម្បីធានាថា ការស្រាវជ្រាវនេះអាចជឿទុកចិត្តបាន។ វិធីសាស្ត្រទាំងនោះរួមមាន : ការសិក្សាអត្ថបទនានា ដែលទាក់ទងនឹងអំពើពុករលួយ ការស្ទង់មតិបែបគុណភាព និងបរិមាណ និងវិធីសាស្ត្រជាក់លាក់មួយសម្រាប់វាយតម្លៃផលប៉ះពាល់នៃអំពើពុករលួយលើវិស័យឯកជន និងសេដ្ឋកិច្ចជាតិ រួមជាមួយនឹងក្រុមប្រឹក្សាយោបល់មួយក្រុម ដែលមានជំនាញ និងបទពិសោធន៍ខ្ពស់ទាក់ទងនឹងបញ្ហាអំពីពុករលួយនេះ។

## ១.១. ការសិក្សាអត្ថបទដែលពាក់ព័ន្ធ

ឯកសារ និងការសិក្សាស្រាវជ្រាវ ដែលពាក់ព័ន្ធអំពើពុករលួយនានារបស់ស្ថាប័នផ្សេងៗ ត្រូវបានពិនិត្យ និងសិក្សាយ៉ាងហ្មត់ចត់ ដូចជាឯកសាររបស់ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម និងវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា រួមនឹងឯកសាររបស់ប្រទេសមួយចំនួន និងអង្គភាពដទៃទៀតផងដែរ។

គួរកត់សំគាល់ផងដែរថា មិនមាននិយមន័យផ្លូវការណាមួយស្តីពីប្រភេទខុសៗគ្នានៃសហគ្រាសក្នុងប្រទេសកម្ពុជាទេ។ ប៉ុន្តែ របាយការណ៍នេះផ្តោតលើពង្រាងក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសធុនតូចនិង មធ្យម ដែលរៀបចំដោយអ្នកជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលស្នើអោយរដ្ឋាភិបាលកំណត់និយមន័យដោយផ្អែកលើចំនួននិយោជិតពេញម៉ោងដូចខាងក្រោម[១]:

**តារាង A២.១: និយមន័យសហគ្រាស**

| | |
|---|---|
| មីក្រូសហគ្រាស | និយោជិត តិចជាង ១០ នាក់ |
| សហគ្រាសធុនតូច | និយោជិត ពី ១០-៥០ នាក់ |
| សហគ្រាសធុនមធ្យម | និយោជិត ពី ៥១-១០០ នាក់ |
| សហគ្រាសធុនធំ | និយោជិត ច្រើនជាង ១០០ នាក់ |

**ប្រភព:** *ធនាគារអភិវឌ្ឍន៍អាស៊ី និងក្រសួងឧស្សាហកម្មរ៉ែ និងថាមពល: ពង្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ សហគ្រាសធុនតូច និងមធ្យម ឆ្នាំ ២០០៤ ទំព័រ ២៥*

[១] នុត មុនីរតន៍ និង ... សេដ្ឋកិច្ចក្រៅប្រព័ន្ធ និងសំណូមពរសម្រាប់ការអភិវឌ្ឍគោលនយោបាយក្នុងប្រទេសកម្ពុជា ពង្រាងរបាយការណ៍ចុងក្រោយ ២០០៥ អង្គការពលកម្មអន្តរជាតិ និងវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ទំព័រ ១៣

## ១.២. ការស្ទង់មតិ

### ១.២.១. តំបន់ស្ទង់មតិ

ការស្ទង់មតិបានធ្វើឡើងលើក្រុងចំនួនពីរ និងខេត្តចំនួនប្រាំពីរ។ ខេត្តក្រុងទាំងនោះរួមមានៈ ភ្នំពេញ បាត់ដំបង សៀមរាប ក្រុងព្រះសីហនុ កំពង់ចាម បន្ទាយមានជ័យ ព្រៃវែង និងកំពត។ តំបន់ទាំងនេះត្រូវបានជ្រើសរើសសម្រាប់ការចុះស្ទង់មតិ ដោយសារតំបន់ទាំងនេះមានការចូលរួមយ៉ាង សំខាន់ក្នុងផលិតផលក្នុងស្រុកសរុប (ផ.ស.ស) និងមានសកម្មភាពសេដ្ឋកិច្ចខ្ពស់ ជាពិសេសមីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម។

**តារាង A២.២: ខេត្តសំរាប់ការសិក្សាអំពីការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជន**

| | ប្រជាជន (គិតជាពាន់) | ផ.ស.ស នាមករណ៏ (គិតជា លានដុល្លារអាមេរិក) | ផ.ស.ស ក្នុងមនុស្សម្នាក់ (គិតជាដុល្លារអាមេរិក) |
|---|---|---|---|
| បន្ទាយមានជ័យ | ៧៣៤ | ១៤១ | ១៩២ |
| បាត់ដំបង | ៩៩១ | ២៥៩ | ២៦២ |
| កំពង់ចាម | ១ ៨៨០ | ៤៦៥ | ២៤៧ |
| កំពត | ៦១៤ | ១៨៦ | ៣០២ |
| កណ្តាល | ១ ២៥៨ | ៤៦២ | ៣៦៧ |
| **ភ្នំពេញ** | **១ ២៣៧** | **១ ៤៩៣** | **១ ២០៧** |
| ព្រៃវែង | ១ ០៨៩ | ២២៣ | ២០៥ |
| សៀមរាប | ៨៣៤ | ២៥០ | ៣០០ |
| ក្រុងព្រះសីហនុ | ១៩៦ | ១៥៩ | ៨០៩ |
| **សរុបខេត្តទាំង ៩** | **៨ ៨៣៣** | **៣ ៦៣៨** | **៤១២** |
| % នៃប្រជាជនកម្ពុជាសរុប | ៦៥% | ៧៤% | |
| ខេត្ត ១៥ ដទៃទៀត | ៤ ៨៤១ | ១ ២៥០ | ២៥៨ |
| % នៃប្រជាជនកម្ពុជាសរុប | ៣៥% | ២៦% | |
| **ប្រជាជនកម្ពុជាសរុប** | **១៣ ៦៧៥** | **៤ ៨៨៨** | **៣៥៧** |

ប្រភព: *វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ចងក្រងចេញពីទិន្នន័យបឋមរបស់រដ្ឋាភិបាល*

### ១.២.២. ការស្ទង់មតិបែបបរិមាណ

#### *ការរៀបចំកម្រងសំណួរ*

កម្រងសំណួរស្រាវជ្រាវមួយត្រូវបានរៀបចំដោយវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា។ កម្រងសំណួរនេះត្រូវបានពិនិត្យឡើងវិញជាច្រើនដងតាមដំណាក់ការៈ (១) ការផ្តល់មតិកែលម្អដោយបុគ្គលិកក្នុងវិទ្យាស្ថាន (២) ការធ្វើតេស្តសាកល្បងលើកទីមួយជាមួយនឹងសហគ្រាសប្រហែល ៤០ ក្នុងទីក្រុងភ្នំពេញ និងខេត្តកណ្តាល (៣) ការជួបប្រជុំជាមួយអ្នកឯកទេសជំនាញផ្នែកអំពើពុករលួយ និងអភិបាលកិច្ច និង (៤) ការធ្វើតេស្តសាកល្បងលើកទីពីរៈ សម្ភាសជាមួយ មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម ក្នុងទីក្រុងភ្នំពេញ និងខេត្ត កណ្តាល ដើម្បីបញ្ចប់ការរៀបចំកម្រងសំណួរ។

#### *ប្រភព និងការជ្រើសរើសគំរូស្ទង់មតិ*

ការស្ទង់មតិបានផ្តោតលើមីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យមច្រើនជាងសហគ្រាសធុនធំ។ ការជ្រើសរើសយកសហគ្រាសធុនតូចច្រើនជាងនេះ គឺដោយសារការស្ទង់មតិលើសហគ្រាសធុនធំលើបញ្ហាអំពើពុករលួយត្រូវបានធ្វើឡើងដោយស្ថាប័នផ្សេងៗជាច្រើនរួចហើយ ក្នុងនោះរួមមាន ធនាគារពិភពលោក និងវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជាផងដែរ។

យើងត្រូវធ្វើការកត់សំគាល់ផងដែរថា ប្រទេសកម្ពុជាពុំមានតួលេខណាមួយពិតប្រាកដស្តីពីចំនួនសហគ្រាសសរុបនៅឡើយទេ។ ហេតុដូចនេះហើយ ទើបទីតាំងនៃការស្ទង់មតិត្រូវបានជ្រើសរើសយកដោយផ្អែកលើមូលដ្ឋាននៃសកម្មភាពសេដ្ឋកិច្ច និងការចូលរួមចំណែកក្នុងផលិតផលក្នុងស្រុកសរុប។ ឧទាហរណ៍ ទំហំគំរូនៃមីក្រូសហគ្រាសក្នុងទីក្រុងភ្នំពេញ ដែលមានសកម្មភាពសេដ្ឋកិច្ចច្រើនមាន ១៨ ភាគរយ បើប្រៀបធៀបទៅនឹងទំហំគំរូ ៩ ទៅ ១២ ភាគរយ របស់ខេត្តក្រុងដទៃទៀត ដែលមិនសូវមានសកម្មភាពសេដ្ឋកិច្ច ។ ដូចគ្នានេះដែរ ទំហំគំរូនៃសហគ្រាសធុនធំ ១០០ ភាគរយ ត្រូវបានធ្វើឡើងតែនៅក្នុងក្រុងភ្នំពេញតែមួយប៉ុណ្ណោះ ពីព្រោះសហគ្រាសធុនធំជាច្រើន មានទីតាំងនៅទីនោះ ។

## តារាង A២.៣: រចនាសម្ព័ន្ធគំរូ តាមបណ្ដាខេត្ត

| | មីក្រូសហគ្រាស | | សហគ្រាសធុនតូច និងមធ្យម | | សហគ្រាសធុនធំ | | សរុប | |
|---|---|---|---|---|---|---|---|---|
| ទីតាំង | គំរូ | % | គំរូ | % | គំរូ | % | គំរូ | % |
| ភ្នំពេញ | ១៤៩ | ១៨% | ៦៣ | ២៦% | ៤៥ | ១០០% | **២៥៧** | ២៣% |
| កណ្ដាល | ៨៧ | ១១% | ៣៥ | ១៤% | 0 | 0% | **១២២** | ១១% |
| សៀមរាប | ៨៥ | ១០% | ២៩ | ១២% | 0 | 0% | **១១៤** | ១០% |
| ក្រុងព្រះសីហនុ | ១០០ | ១២% | ១៣ | ៥% | 0 | 0% | **១១៣** | ១០% |
| កំពង់ចាម | ៨៧ | ១១% | ២៥ | ១០% | 0 | 0% | **១១២** | ១០% |
| បាត់ដំបង | ៧៨ | ១០% | ២៣ | ៩% | 0 | 0% | **១០១** | ៩% |
| បន្ទាយមានជ័យ | ៧៣ | ៩% | ១៦ | ៧% | 0 | 0% | **៨៩** | ៨% |
| ព្រៃវែង | ៧៧ | ៩% | ២០ | ៨% | 0 | 0% | **៩៧** | ៩% |
| កំពត | ៨២ | ១០% | ២០ | ៨% | 0 | 0% | **១០២** | ៩% |
| **សរុប** | **៨១៨** | ១០០% | **២៤៤** | ១០០% | **៤៥** | ១០០% | **១ ១០៧** | ១០០% |
| **%** | **៧៤%** | | **២២%** | | **៤%** | | **១០០%** | |

**ចំណាំ:** សហគ្រាសធុនតូច (និយោជិត<១០) សហគ្រាសធុនតូច និងមធ្យម (១០<= និយោជិត<១០០) សហគ្រាសធំ (និយោជិត>=១០០)

វិធីដូចគ្នានេះដែរ ត្រូវបានយកមកអនុវត្តនីចំពោះការជ្រើសរើសស្រុកខុសៗគ្នាក្នុងខេត្តក្រុងចំនួន ៩ ខាងលើនេះ។ ជាទូទៅ ការចុះបញ្ជីឧស្សាហកម្មនៅក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក្រសួងពាណិជ្ជកម្ម និងប្រភពពាក់ព័ន្ធដទៃទៀត ក៏ដូចជាភាពជាក់ស្ដែងនៃទីតាំងរបស់សហគ្រាស គឺជាប្រភពដ៏សំខាន់សម្រាប់យោងក្នុងការកំណត់ភាពសំបូរបែបនៃសកម្មភាពសេដ្ឋកិច្ចនៃស្រុកទាំងនោះ (កន្លែងដែលសហគ្រាសភាគច្រើនប្រមូលផ្ដុំនៅទីនោះ)។

បើពិនិត្យមើលលើផ្នែកនីមួយៗវិញ គំរូផ្ដោតច្រើនលើវិស័យសេវា និងបន្ទាប់មកទៀត មានផលិតកម្មសិប្បកម្ម និងកសិកម្ម (តារាង A២.៤)។

## តារាង A២.៤: រចនាសម្ព័ន្ធគម្រូតាមវិស័យ

| | មីក្រូសហគ្រាស | | សហគ្រាសធុនតូច និងមធ្យម | | សហគ្រាសធុនធំ | |
|---|---|---|---|---|---|---|
| **វិស័យ** | **គំរូ** | **%** | **គំរូ** | **%** | **ចំនួន** | **%** |
| កសិកម្ម | ៣ | ០% | ២ | ១% | 0 | ០% |
| ផលិតកម្ម/សិប្បកម្ម | ១៥៧ | ២០% | ១៤៦ | ៦០% | ២៦ | ៥៨% |
| សេវាកម្ម | ៦៥៨ | ៨០% | ៩៦ | ៣៩% | ១៩ | ៤២% |
| **សរុប** | **៨១៨** | ១០០% | **២៤៤** | ១០០% | **៤៥** | ១០០% |

**ចំណាំ:** សហគ្រាសធុនតូច (និយោជិត< ១០) សហគ្រាសធុនតូច និងមធ្យម (១០<= និយោជិត <១០០) សហគ្រាសធំ (និយោជិត >=១០០)

សកម្មភាពពាណិជ្ជកម្មរបស់អ្នកតបសម្ភាសន៍ មានដូចជា : មីក្រូសហគ្រាសភាគច្រើនជាប្រភេទអាជីវកម្មលក់ដូរ ឯសហគ្រាសធុនតូច និងមធ្យមភាគច្រើនជាប្រភេទ ម៉ាស៊ីនកិនស្រូវ ឡឥដ្ឋ និងអាជីវកម្មលក់ដូរ និងចំណែកឯសហគ្រាសធុនធំវិញភាគច្រើនជា រោងចក្រកាត់ដេរ (តារាង **A២.៥**) ។

## តារាង A២.៥: រចនាសម្ព័ន្ធគំរូ តាមសកម្មភាព

| | មីក្រូសហគ្រាស | | សហគ្រាសធុនតូច និងមធ្យម | | សហគ្រាសធុនធំ | |
|---|---|---|---|---|---|---|
| **ទីតាំង** | **គំរូ** | **%** | **គំរូ** | **%** | **គំរូ** | **%** |
| ម៉ាស៊ីនកិនស្រូវ | ៨ | ១% | ៣៥ | ១៤% | 0 | ០% |
| ឡឥដ្ឋ | ១ | ០% | ៣៤ | ១៤% | ៣ | ៧% |
| អាជីវកម្មលក់ដូរ | ៤២២ | ៥២% | ៣១ | ១៣% | ២ | ៤% |
| រោងចក្រកាត់ដេរ | 0 | ០% | 0 | ០% | ១៩ | ៤២% |
| សណ្ឋាគារ/ផ្ទះសំណាក់ | ៥២ | ៦% | ២១ | ៩% | ២ | ៤% |
| ផ្សេងៗ[២] | ៣៣៥ | ៤១% | ១២៣ | ៥០% | ១៩ | ៤២% |
| **សរុប** | **៨១៨** | ១០០% | **២៤៤** | ១០០% | **៤៥** | **១០០%** |

**ចំណាំ:** សហគ្រាសធុនតូច (និយោជិត< ១០) សហគ្រាសធុនតូច និងមធ្យម (១០<= និយោជិត <១០០) សហគ្រាសធំ (និយោជិត >=១០០)

---

[២] រួមបញ្ចូលសកម្មភាពជាច្រើន ដូចជា សិប្បកម្ម ការចិញ្ចឹមសត្វ សេវាបណ្តុះបណ្តាល និងអប់រំ ហាងលក់បាយ និងភេសជ្ជៈ សេវាកំសាន្ត សិប្បកម្មកែច្នៃឈើ យានដ្ឋាន ។ល។

កិច្ចប្រឹងប្រែងរួមគ្នានៃក្រុមស្រាវជ្រាវ បានធានាគុណភាពជឿទុកចិត្តបាននូវចម្លើយ ដែលបានផ្តល់ទាំងអស់។ អ្នកតបសម្ភាសន៍ជាង ៤០ ភាគរយ គឺជាស្ត្រីមកពីមីក្រូសហគ្រាស និងប្រហែល ៣០ ភាគរយមកពីសហគ្រាសធុនតូច និងមធ្យម និងមានតែ ៥ ភាគរយ ប៉ុណ្ណោះមកពីសហគ្រាសធុនធំ។

**តារាង A២.៦: រចនាសម្ព័ន្ធគំរូ តាមភេទរបស់អ្នកតបសម្ភាសន៍**

| | មីក្រូសហគ្រាស | | សហគ្រាសធុនតូច និងមធ្យម | | សហគ្រាសធុនធំ | |
|---|---|---|---|---|---|---|
| ទីតាំង | គំរូ | % | គំរូ | % | គំរូ | % |
| ប្រុស | ៤៦៦ | ៥៧% | ១៧៥ | ៧២% | ៤០ | ៨៩% |
| ស្រី | ៣៥២ | ៤៣% | ៦៩ | ២៨% | ៥ | ១១% |
| **សរុប** | **៨១៨** | ១០០% | **២៤៤** | ១០០% | **៤៥** | **១០០%** |

**ចំណាំ:** សហគ្រាសធុនតូច (និយោជិត<១០) សហគ្រាសធុនតូច និងមធ្យម (១០<= និយោជិត<១០០) សហគ្រាសធំ (និយោជិត>=១០០)

វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា បានរកទីតាំងសហគ្រាសតាមបណ្តាខេត្ត ក្រុង ទុកជាមុនសម្រាប់ការចុះអង្កេតស្ទង់មតិនេះ។ ការស្វែងរកទីតាំងនេះ ជាទូទៅធ្វើឡើងចំពោះសហគ្រាសណាដែលបានចុះបញ្ជីផ្លូវការជាមួយក្រសួងពាក់ព័ន្ធ។ ក្រុមស្រាវជ្រាវក៏បានកំណត់សហគ្រាសក្រៅប្រព័ន្ធ (មិនមានការចុះបញ្ជី) ដទៃទៀតផងដែរនៅពេលចុះទៅដល់ខេត្តក្រុងទាំងនោះ។

ក្នុងស្រុកនីមួយៗរបស់ខេត្ត ក្រុងដែលបានរើសយកសហគ្រាស ត្រូវបានជ្រើសរើសយកដោយចៃដន្យសម្រាប់ការស្ទង់មតិបែបបរិមាណ។ អ្នកតបសម្ភាសន៍ជាទូទៅត្រូវយល់ដឹងពីកម្រងសំណួរ។ ក្នុងបរិបទនេះ អ្នកតបសម្ភាសន៍ត្រូវតែជាអ្នកមានតួនាទីជាសហគ្រិន ឬអ្នកគ្រប់គ្រងជាន់ខ្ពស់ ដែលយល់ដឹងពីសហគ្រាសរបស់ខ្លួនច្រើនជាងគេ។

### ១.២.៣. ការស្ទង់មតិបែបគុណភាព

ការស្ទង់មតិបែបគុណភាព ធ្វើឡើងដោយប្រើប្រាស់វិធីសាស្ត្រពីរ: ក្រុមពិភាក្សា (FGD) និងការសម្ភាសន៍បុគ្គល។ ក្រុមពិភាក្សាធ្វើឡើងជាមួយមីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម ចំណែកឯការសម្ភាសន៍បុគ្គលធ្វើឡើងជាមួយមន្ត្រីសាធារណៈ។

បន្ទាប់ពីពិនិត្យតាមរយៈលទ្ធផលនៃការស្ទង់មតិបែបបរិមាណជាមួយសហគ្រាសនានា ជាទូទៅ មន្ត្រីដែលបានសំភាសភាគច្រើនជាអ្នកមានការជាប់ពាក់ព័ន្ធនឹងការប្រមូលប្រាក់ចំណាយទាំងផ្លូវការ និងក្រៅផ្លូវ

ការ[៣] ពីមីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម ត្រូវបានធ្វើបទសម្ភាសន៍ជាមួយ។ មន្ត្រីទាំងនេះរួមមានប៉ូលីស អាជ្ញាធរស្រុក និងមន្ត្រីនាយកដ្ឋានពន្ធដារ បរិស្ថាន ឧស្សាហកម្ម និងពាណិជ្ជកម្ម។

ក្រុមពិភាក្សាត្រូវបានរៀបចំឡើងមានចំនួនពីរក្នុងខេត្តក្រុងនីមួយៗ លើកលែងតែក្រុងភ្នំពេញមានចំនួនបួន។ ជាទូទៅ ចំនួនអ្នកចូលរួមក្នុងក្រុមពិភាក្សានីមួយៗមានពី ៧ ទៅ ១០ នាក់។ ក្រុមពិភាក្សាផ្តោតសំខាន់លើមូលហេតុ ទំហំ និងទស្សនៈរបស់អ្នកតបសម្ភាសន៍ក្នុងការប្រឆាំងអំពើពុករលួយនៅប្រទេសកម្ពុជា។

សរុបមក ក្រុមពិភាក្សាចំនួន ២០ ត្រូវបានរៀបចំឡើង ក្នុងនោះក្រុមពិភាក្សា ១០ សម្រាប់មីក្រូសហគ្រាស និង ១០ ទៀត សម្រាប់សហគ្រាសធុនតូច និងមធ្យម។ អ្នកចូលរួមមកពីសមាគមអាជីវកម្មមួយចំនួន ក៏ត្រូវបានអញ្ជើញចូលរួមក្នុងក្រុមពិភាក្សាផងដែរ។

អ្នកចូលរួមក្នុងក្រុមពិភាក្សា ត្រូវបានអញ្ជើញដោយអ្នកធ្វើបទសម្ភាសន៍ ខណៈពេលធ្វើសម្ភាសន៍បែបគុណភាព។ អ្នកសម្ភាសន៍បានជ្រើសរើសសហគ្រិនយ៉ាងផ្ចិតផ្ចង់ តាមរយៈការស្ទង់មតិមើល និងការយល់ឃើញរបស់ខ្លួនផ្ទាល់។ អ្វីដែលត្រូវការជាមុនសម្រាប់អ្នកសម្ភាសន៍ក្នុងការជ្រើសរើសយក អ្នកតបសម្ភាសន៍ណាមួយសម្រាប់ការចូលរួមក្នុងក្រុមពិភាក្សា គឺមានដូចជា អ្នកនោះត្រូវជាម្ចាស់ ឬអ្នកគ្រប់គ្រងសហគ្រាស ទីតាំងអាជីវកម្មគួរតែនៅជិតកន្លែងពិភាក្សា និងមានលក្ខណៈសហការ និងចង់យល់ដឹងពិតប្រាកដពីការពិភាក្សា[៤]។

ទិន្នន័យបែបគុណភាពដែលប្រមូលបានពីក្រុមពិភាក្សា និងការសម្ភាសន៍បែបគុណភាពត្រូវបានបែងចែកតាមប្រភេទ និងរៀបចំជាតារាងម៉ាទ្រីសតាមប្រធានបទខុសៗគ្នានៃសំណួរនីមួយៗ។ ព័ត៌មាន ដែលបានមកពីក្រុមពិភាក្សាមិនត្រូវបានបញ្ចូលទាំងអស់ទេ។ អ្នកស្រាវជ្រាវ ចាំបាច់ត្រូវផ្ទៀងផ្ទាត់រវាងព័ត៌មានដែលបានផ្តល់ដោយអ្នកតបសម្ភាសន៍ជាមួយភាពពិតជាក់ស្តែង និងការស្ទង់មតិទូទៅក្នុងពេលចុះ សម្ភាសន៍ជាពិសេស ក្នុងករណីដែលចម្លើយមានភាពផ្ទុយគ្នា។ ក្នុងករណីមានភាពមិនស្របគ្នា ព័ត៌មានមិនច្បាស់លាស់នោះមិនត្រូវបានរាប់បញ្ចូលឡើយ។

---

[៣] "ចំណាយផ្លូវការ" គឺប្រាក់ដែលគេបានបង់ទៅអោយភ្នាក់ងាររដ្ឋាភិបាល ដែលមានបង្កាន់ដៃត្រឹមត្រូវ តាមចំនួនទឹកប្រាក់ដែលបានបង់។ "ចំណាយក្រៅផ្លូវការ" គឺប្រាក់ដែលបានបង់ទៅអោយភ្នាក់ងាររបស់រដ្ឋាភិបាល ដោយគ្មានបង្កាន់ដៃត្រឹមត្រូវ ឬមានតែចំនួនទឹកប្រាក់មួយចំនួនតែប៉ុណ្ណោះ លើបង្កាន់ដៃ ដែលបានផ្តល់អោយនោះ។ ចំណាយក្រៅផ្លូវការ ក៏សំដៅលើពន្ធពុករលួយ លុយទឹកតែ អំណោយ ឬពាក្យផ្អែមល្ហែមជាដើម។ និយមន័យនេះ ត្រូវបានដកស្រង់ចេញពីរបាយការណ៍សិក្សាមួយរបស់ AAC និង ILO ដែលមានចំណងជើងថា "ការសិក្សាស្តីពីតម្រូវការ ច្បាប់ សំរាប់មីក្រូអាជីវកម្ម និង អាជីវកម្មធុនតូច អង្គការក្រៅរដ្ឋាភិបាល និង សមាគមន៍ និងនីតិវិធី និងការអនុវត្តសម្រាប់ការនាំចេញសិប្បកម្ម កម្ពុជា ឆ្នាំ ២០០៤ ។

[៤] ការកំណត់នេះធ្វើឡើងដោយផ្អែកលើការយល់ដឹងភ្លាមៗរបស់អ្នកតបសម្ភាសន៍ រួមបញ្ចូលទាំងភាពស្របគ្នានៃចម្លើយរបស់ គេព្រមទាំងការយល់ដឹងពីបញ្ហាអំពើពុករលួយផង។

### ១.២.៤. ព្រំដែននៃការស្ទង់មតិ

ការស្ទង់មតិផ្តោតជាចំបងលើសហគ្រាសនៅតំបន់ទីប្រជុំជន។ ជាងនេះទៅទៀត ដោយសារតែសហគ្រាសភាគច្រើនក្នុងប្រទេសកម្ពុជាមានលក្ខណៈក្រៅផ្លូវការ មិនមានព័ត៌មានច្បាស់លាស់ណាមួយ អំពីភាគរយពិតប្រាកដរបស់សហគ្រាសក្នុងគំរូអង្កេត ជាមួយចំនួនសហគ្រាសក្នុងប្រទេសកម្ពុជាទាំងមូលទេ។ ក្រៅពីនេះ នៅពេលឆ្លើយសំណួរ ដែលទាក់ទងនឹងប្រាក់ចំណាយ ឬការបង់ចំណាយក្រៅផ្លូវការ អ្នកតបសម្ភាសន៍ពិបាកក្នុងការញែកអោយបានច្បាស់រវាងចំណាយផ្លូវការ និងក្រៅផ្លូវការ ពីព្រោះអ្នកតបសម្ភាសន៍ភាគច្រើនមិនដឹងថា តើចំណាយណាមួយនឹងទៅកាន់មន្ត្រីណាខ្លះ ដែលជាប្រាក់ចំណាយផ្លូវការ។

## ១.៣. ការបញ្ចូលទិន្នន័យ និងការកែសម្រួលឡើងវិញ

ទម្រង់បញ្ចូលទិន្នន័យ និងការបញ្ចូលទិន្នន័យ ត្រូវបានធ្វើឡើងដោយក្រុមស្រាវជ្រាវ (អ្នកស្រាវជ្រាវ និងជំនួយការស្រាវជ្រាវ) របស់វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា។ ទិន្នន័យត្រូវបានកែពិនិត្យសម្រួលជាច្រើនដង: ទាំងនៅពេលកំពុងធ្វើស្ទង់មតិ និងក្រោយពេលស្ទង់មតិ។ ទីមួយ ក្នុងកំឡុងពេលធ្វើការ ស្ទង់មតិ ប្រធានក្រុម និងអ្នកគ្រប់គ្រងក្រុមបានត្រួតពិនិត្យគំរូដែលបានសម្ភាសន៍រួច និងក្នុងករណីដែលកម្រងសំណួរមានភាពមិនត្រឹមត្រូវ និងមិនបំពេញចប់ត្រឹមត្រូវគំរូនោះ ត្រូវបានបដិសេធចោល ។ក្រោយពេលចុះធ្វើអង្កេតរួចក្រុមចុះអង្កេត បានត្រួតពិនិត្យឡើងវិញម្តងទៀតនូវទិន្នន័យ ដែលបានប្រមូលរួច ។ សមាជិកក្រុមអាចត្រូវបានស្នើអោយទៅកាន់កន្លែងធ្វើអង្កេតម្តងទៀត ដើម្បីបំពេញព័ត៌មានដែលមិនបានសួរ។

ទីពីរ ពេលកំពុងបញ្ចូលទិន្ន័យ ជំនួយការស្រាវជ្រាវបានត្រួតពិនិត្យម្តងទៀត ដើម្បីរកភាពមិនស្របគ្នានៃចម្លើយពីសំណួរមួយទៅមួយ។ ទីបី ទិន្នន័យត្រូវពិនិត្យ និងសម្រួលដោយអ្នកស្រាវជ្រាវ។ សំណួរជាក់លាក់មួយចំនួន ត្រូវបានប្រើសំរាប់ធ្វើជាគំរូគោលប្រៀបធៀប ដើម្បីពិនិត្យមើលថាតើចម្លើយទាំងនោះអាចទទួលយកបានដែរឬទេ។ ឧទាហរណ៍ ចំពោះសំណួរស្តីពីប្រាក់ចំណូលអ្នកស្រាវជ្រាវបានពិនិត្យមើលថាតើចំណូលរបស់អ្នកតបសម្ភាសន៍ ដែលបានផ្តល់អោយនោះជឿទុកចិត្តបានដែរឬទេដោយធ្វើការពិចារណាលើតម្លៃបន្ថែមចំនួននិយោជិត និងសកម្មភាពពាណិជ្ជកម្ម។

## ១.៤. ក្រុមប្រឹក្សា

ក្រុមមួយដែលរួមមានអ្នកជំនាញខាងការប្រឆាំងអំពើពុករលួយ ត្រូវបានបង្កើតឡើងដើម្បីផ្តល់អនុសាសន៍ជាក់ស្តែងលើវិធីសាស្ត្រស្រាវជ្រាវ និងដំណើរការក្នុងការសិក្សាស្រាវជ្រាវ។ អ្នកជំនាញកិច្ចការផ្នែកអំពើពុករលួយ អភិបាលកិច្ច វិស័យឯកជន និងយេនឌ័រ ត្រូវបានអញ្ជើញជាកិត្តិយស និងប្រកបដោយ

ភាពស្និទ្ធស្នាល ដើម្បីចូលរួមក្នុងក្រុមប្រឹក្សា (សូមមើលឧបសម្ព័ន្ធ ១ សំរាប់បញ្ជីឈ្មោះរបស់ក្រុមប្រឹក្សាទាំងមូល)។

ក្រុមប្រឹក្សានេះបានជួបគ្នាចំនួនពីរដង ដោយបានផ្តល់មតិកែលម្អ និងយោបល់ល្អៗមុននឹងការសិក្សាស្រាវជ្រាវនេះបានបញ្ចប់។

## តារាងអ្នកពិគ្រោះយោបល់

| លេខរៀង | ឈ្មោះ | មុខងារ | ស្ថាប័ន |
|---|---|---|---|
| ១ | លោក អ៊ូច ចំរើន | មន្ត្រីកម្មវិធី | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ២ | លោក សុខ ណារិន | ប្រធានកម្មវិធីប្រឆាំងអំពើពុករលួយ | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| ៣ | កញ្ញា សៀង លក្ខិណា | ទីប្រឹក្សាថ្នាក់ជាតិ | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| ៤ | លោក ហោ សុនាថ | មន្ត្រីអភិវឌ្ឍន៍អាជីកម្ម | កម្មវិធីអភិវឌ្ឍន៍វិស័យឯកជន |
| ៥ | លោក ទា សាវ៉ា | ទីប្រឹក្សា | ឌី អេ អាយ |
| ៦ | លោក សេក បរិសុទ្ធ | ប្រធានកម្មវិធីប្រឆាំងអំពើពុករលួយ | អង្គការផេក |
| ៧ | លោក ឆាយ សារ៉ាត | មន្ត្រីកម្មវិធីអង្គការផេក | អង្គការផេក |
| ៨ | លោក សុក ហាច | នាយក | វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា |
| ៩ | លោក នុត មុនីរតន៍ | អ្នកស្រាវជ្រាវ | វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា |
| ១០ | ចាន់ វុទ្ធី | អ្នកស្រាវជ្រាវ | វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា |
| ១១ | កូវ ភិរម្យ | អ្នកស្រាវជ្រាវ | វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា |
| ១២ | នៅ សីហា | អ្នកស្រាវជ្រាវ | វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា |
| ១៣ | ឃៀង សុជីវី | អ្នកស្រាវជ្រាវ | វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា |
| ១៤ | លោក រិទ្ធ សីហា | នាយកប្រតិបត្តិ | អេស អ៊ីម អ៊ី ខេមបូឌា |
| ១៥ | ព្រំ វិសុទ្ធ | នាយក នាយកដ្ឋាននីតិកម្ម | ធនាគារ អេស៊ីលីដា ភីអិលស៊ី |

# សេចក្តីបន្ថែម ៣

# កម្រងសំណួរស្ទង់មតិ

# កម្រងសំណួរ
# (សម្រាប់មីក្រូសហគ្រាស)

*វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា* កំពុងធ្វើការសិក្សាស្តីពីការអភិវឌ្ឍវិស័យឯកជននៅកម្ពុជា ដោយមានការគាំទ្រ និងឧបត្ថម្ភពី*ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់កិច្ចអភិវឌ្ឍន៍អន្តរជាតិ* ***(USAID)*** *អង្គការផេក-កម្ពុជា* ***(Pact-Cambodia)*** និង ***PADCO|AECOM***។ ការសិក្សានេះ គឺធ្វើឡើងសម្រាប់ប្រទេសកម្ពុជាទាំងមូល ដែលក្នុងនោះក្រុម ស្រាវជ្រាវនៃវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា នឹងចុះធ្វើការសម្ភាសន៍ជាមួយ តំណាងសហគ្រាសធុនតូច មធ្យម និងធំ សរុបទាំងអស់ចំនួន ១២០០ នៅតាមបណ្តាខេត្ត-ក្រុង ចំនួន ៩ រួមមាន ក្រុងភ្នំពេញ ខេត្តកណ្តាល កំពង់ចាម ព្រៃវែង កំពត ក្រុងព្រះសីហនុ បាត់ដំបង បន្ទាយមានជ័យ និង សៀមរាប។

គោលបំណងចុងក្រោយតែមួយគត់នៃការសិក្សានេះ គឺស្វែងយល់អោយកាន់តែស៊ីជំរៅ នូវឧបសគ្គនានា សម្រាប់អាជីវកម្មដើម្បីអាចផ្តល់ជាអនុសាសន៍ដល់រាជរដ្ឋាភិបាល ក៏ដូចជាសហគមន៍អ្នកផ្តល់ជំនួយអន្តរជាតិសំដៅជំរុញ និងលើកស្ទួយវិស័យឯកជន ជាពិសេសអាជីវកម្មធុនតូច មធ្យម និងធំ នៅកម្ពុជា។

*យើងខ្ញុំសង្ឃឹមយ៉ាងជឿជាក់ថា លោក/លោកស្រីនឹងចំណាយពេលដ៏មានតំលៃប្រហែល ៣០នាទីដើម្បីចូលរួមក្នុងការស្ទាបស្ទង់មតិនេះ។*

**ព័ត៌មាននៅក្នុងកម្រងសំណួរនេះនឹងត្រូវរក្សាជាការសំងាត់ៗ**

០១. ជាទូទៅ តើចំណាយក្រៅផ្លូវការក្នុងវិស័យឯកជននៅប្រទេសកម្ពុជាមានភាពធ្ងន់ធ្ងរកម្រិតណា?

| មិនធ្ងន់ធ្ងរទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | ធ្ងន់ធ្ងរខ្លាំងបំផុត |
|---|---|---|---|---|---|---|---|---|

០២. ក្នុងរយៈពេល១២ខែកន្លងទៅ តើអាជ្ញាធរ/មន្ត្រីខាងក្រោមធ្លាប់បានចុះត្រួតពិនិត្យសហគ្រាសអ្នក ឬទេ? សម្រាប់ការចុះត្រួតពិនិត្យមួយលើកៗ តើអ្នកត្រូវចំណាយប្រហែលប៉ុន្មាន?

| | ចំណាយសរុប (*) | ភាពញឹកញាប់ (ចំនួនប៉ុន្មានដងក្នុង១ឆ្នាំ?) | ចំណាយផ្លូវការ | ចំណាយក្រៅផ្លូវការ |
|---|---|---|---|---|
| ☐ ប៉ូលីស | | | | |
| ☐ ភ្នាក់ងារពន្ធដារ | | | | |
| ☐ អាជ្ញាធរមូលដ្ឋាន | | | | |
| ☐ ភ្នាក់ងារត្រួតពិនិត្យអគ្គីភ័យ/សុវត្ថិភាព | | | | |
| ☐ ការត្រួតពិនិត្យស្តង់ដារ | | | | |
| ☐ ភ្នាក់ងារបរិស្ថាន | | | | |
| ☐ ភ្នាក់ងារសង្គមកិច្ច និង ការងារ | | | | |
| ☐ ផ្សេងៗ: | | | | |
| ☐ ផ្សេងៗ: | | | | |
| សរុប | | | | |
| ភាគរយ (%) | | | | |

(*) ព័ត៌មានទីនេះសំខាន់ណាស់: សូមបញ្ជាក់ឯកតារូបិយវត្ថុអោយច្បាស់ (ឧ. រៀល/R ដុល្លារ/$ បាត/B)

០៣. ជាមធ្យម ក្នុងមួយឆ្នាំ តើសហគ្រាសអ្នកត្រូវចំណាយសរុបដល់មន្ត្រីរាជការប្រហែលប៉ុន្មាន ភាគរយនៃចំណូលសរុបរបស់សហគ្រាសអ្នក?

ប្រហែល: ____________ភាគរយនៃចំណូលសរុបប្រចាំឆ្នាំ

០៤. តើសហគ្រាសអ្នកដំណើរការដោយមានអាជ្ញាប័ណ្ណ (អាជ្ញាប័ណ្ណប៉ាតង់ ឬ ទំរង់អាជ្ញាប័ណ្ណ ផ្សេងទៀត) ដែលចេញដោយស្ថាប័ន/អាជ្ញាធរផ្សេងៗដែរឬទេ?

☐ មាន

☐ អត់មានទេ (រំលងទៅសំណួរទី ០៦)

០៥. តើអ្នកត្រូវចំណាយប៉ុន្មានសម្រាប់ការចុះបញ្ជីសុំអាជ្ញាប័ណ្ណបើកអាជីវកម្ម?

| | ចំណាយសរុប | ចំណាយ ផ្លូវការ | ចំណាយ ក្រៅផ្លូវការ |
|---|---|---|---|
| □ ការចុះបញ្ជីសុំកន្លែងធ្វើអាជីវកម្ម (ពីអាជ្ញាធរមូលដ្ឋាន) | | | |
| □ អាជ្ញាប័ណ្ណបើកអាជីវកម្ម (ពីក្រសួង/មន្ទីផ្សេងៗ) | | | |
| □ ផ្សេងៗ: ____________________ | | | |
| សរុប | | | |

០៦. តើចំណាយបន្ថែម (ក្រៅផ្លូវការ) ទៅឱ្យមន្ត្រីរាជការត្រូវបានធ្វើតាមវិធីណា? (ចំលើយអាចលើសពី ១)

□ មន្ត្រីមានសមត្ថកិច្ចមកកាន់សហគ្រាសអ្នកផ្ទាល់

□ សហគ្រាសអ្នកទៅទាក់ទងផ្ទាល់ជាមួយមន្ត្រីមានសមត្ថកិច្ច

□ តាមរយៈអ្នករត់ការ

□ ផ្សេងៗ: ________________

០៧. តើសហគ្រាសអ្នក ជាទូទៅដឹងជាមុនទេពីចំនួនទឹកប្រាក់ដែលត្រូវបង់បន្ថែមឱ្យទៅមន្ត្រីរាជការ ដើម្បីធានាដល់ដំណើរការល្អនៃអាជីវកម្មដែរ ឬទេ?

| មិនដែលដឹងសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | ជានិច្ចកាលដឹងមុន |
|---|---|---|---|---|---|---|---|---|

០៨. តើអ្នកយល់ស្របទេថា បន្ទាប់ពីមានចំណាយបន្ថែមសេវាសាធារណៈ នឹងត្រូវបានផ្តល់អោយ អ្នកវិញគួរជាទីពេញចិត្ត ពីសំណាក់មន្ត្រីរាជការ?

| មិនយល់ស្របទាំងស្រុង | 1 | 2 | 3 | 4 | 5 | 6 | 7 | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|---|---|---|

០៩. តើមូលហេតុអ្វី បានជាសហគ្រាសអ្នកយល់ព្រមបង់ចំណាយក្រៅផ្លូវការ? (ចំលើយអាចលើសពី ១)

□ ដើម្បីទទួលបានសេវាសាធារណៈរហ័ស

□ ដើម្បីជៀសវាងការគំរាមកំហែងពីមន្ត្រីរាជការ

□ ដើម្បីការពារផលប្រយោជន៍អាជីវកម្ម

□ ដើម្បីប៉ះប៉ូវទៅនឹងម៉ោងមិនទទួលបានកម្រៃរបស់មន្ត្រីរាជការ

□ ដើម្បីជាសគុណសម្រាប់ការផ្តល់សេវាដោយមន្ត្រីរាជការ

□ ផ្សេងៗ: ____________________

១០. តាមយោបល់អ្នក តើមូលហេតុអ្វីបានជាមានចំណាយក្រៅផ្លូវការក្នុងវិស័យឯកជននៅប្រទេសកម្ពុជា? សូមអ្នកធ្វើការវាយតំលៃ លើមូលហេតុដូចខាងក្រោម ដោយជ្រើសរើសពីលេខ ១ (មិនជាមូល ហេតុទេ) ដល់លេខ ៧ (មូលហេតុចំបងបំផុត)

| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ |
|---|---|---|---|---|---|---|---|
| ប្រាក់ខែមន្ត្រីរាជការទាប | | | | | | | |
| វប្បធម៌នៃអំពើពុករលួយ-ទំលាប់ | | | | | | | |
| ការិយាធិបតេយ្យ-បែបបទរដ្ឋបាលច្រើន និង ស្មុគ្រស្មាញ | | | | | | | |
| ភាពធូរលុងនៃការអនុវត្តច្បាប់ | | | | | | | |
| តុលាការខ្វះភាពឯករាជ្យ និង គ្មានប្រសិទ្ធភាព | | | | | | | |
| ខ្វះការត្រួតពិនិត្យ- ខ្វះការទទួលខុសត្រូវរបស់មន្ត្រីរាជការ | | | | | | | |
| ខ្វះប្រព័ន្ធតាមដានអំពើពុករលួយប្រកបដោយប្រសិទ្ធភាព | | | | | | | |
| ខ្វះក្រមសីលធម៌ក្នុងសង្គម | | | | | | | |
| ខ្វះលទ្ធិប្រជាធិបតេយ្យ | | | | | | | |
| ប្រសិទ្ធភាពសង្គមស៊ីវិលនៅមានកំរិត | | | | | | | |
| ផ្សេងៗ: ________________________ | | | | | | | |

១១. ជាទូទៅ តើអ្នកណាជាអ្នកដោះស្រាយជាមួយមន្ត្រីមានសមត្ថកិច្ចដែលចុះមកពិនិត្យសហ គ្រាសអ្នក?

☐ ម្ចាស់សហគ្រាស (ប្រុស)  ☐ បុគ្គលិករដ្ឋបាល (ប្រុស)

☐ ម្ចាស់សហគ្រាស (ស្រី)  ☐ បុគ្គលិករដ្ឋបាល (ស្រី)

☐ ផ្សេងៗ: ___________

១២. តាមយោបល់អ្នក តើសកម្មភាពរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ទទួលបានជោគជ័យ កម្រិតណា?

មិនជោគជ័យទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | ជោគជ័យយ៉ាងខ្លាំង

១៣. តើអ្នកដែលឮ ពីច្បាប់ប្រឆាំងអំពើពុករលួយដែរឬទេ?

☐ បាទ/ចាស

☐ ទេ

១៤. តើអ្នកគិតថា ច្បាប់ប្រឆាំងអំពើពុករលួយដែលរដ្ឋសភាជាតិនឹងអនុម័តនាពេលឆាប់ៗខាងមុខនេះ មានប្រសិទ្ធភាពដែរឬទេ?

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| មិនមានប្រសិទ្ធភាពទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | មានប្រសិទ្ធភាពខ្លាំងបំផុត |

១៥. តើអ្នកមានជំនឿថា វិធានការណ៍ខាងក្រោមមានប្រសិទ្ធភាពក៏រិតណាក្នុងការលុបបំបាត់ អំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា?

១៥-០១. ការតំឡើងប្រាក់ខែសម្រាប់មន្ត្រីរាជការ

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| មិនមានប្រសិទ្ធភាពទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | មានប្រសិទ្ធភាពខ្លាំងបំផុត |

១៥-០២. ការលើកទឹកចិត្តទៅតាមការប្រតិបត្តិការងារជាក់ស្តែងរបស់មន្ត្រីរាជការ

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| មិនមានប្រសិទ្ធភាពទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | មានប្រសិទ្ធភាពខ្លាំងបំផុត |

១៥-០៣. ការបង្កើតអោយមានអាជ្ញាធរឯករាជ្យតាមដានអំពើរពុករលួយ

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| មិនមានប្រសិទ្ធភាពទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | មានប្រសិទ្ធភាពខ្លាំងបំផុត |

១៥-០៤. ការបង្កើតអោយមានប្រព័ន្ធ-បណ្តាញ រាយការណ៍អំពីអំពើពុករលួយ

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| មិនមានប្រសិទ្ធភាពទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | មានប្រសិទ្ធភាពខ្លាំងបំផុត |

១៥-០៥. ការប្រកាសជាសាធារណៈនៃទ្រព្យសម្បត្តិមន្ត្រីរាជការ

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| មិនមានប្រសិទ្ធភាពទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | មានប្រសិទ្ធភាពខ្លាំងបំផុត |

១៥-០៦. ការផ្សព្វផ្សាយជាសាធារណៈនូវតំលៃផ្លូវការនានា ដែលតម្រូវដោយរដ្ឋាភិបាល

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| មិនមានប្រសិទ្ធភាពទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | មានប្រសិទ្ធភាពខ្លាំងបំផុត |

១៥-០៧. សេវាបង់តែមួយ (សេវាច្រកទ្វារតែមួយរបស់រដ្ឋាភិបាល) សម្រាប់អាជីវកម្ម

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| មិនមានប្រសិទ្ធភាពទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | មានប្រសិទ្ធភាពខ្លាំងបំផុត |

១៥-០៨. ការជំរុញអោយមានសមាគមន៍អាជីវកម្មដែលអាចចរចារជាមួយរដ្ឋាភិបាល

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| មិនមានប្រសិទ្ធភាពទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | មានប្រសិទ្ធភាពខ្លាំងបំផុត |

១៦. តើអ្នកយល់ស្របទេថា ការធ្វើចំណាយក្រៅផ្លូវការអោយទៅជាចំណាយផ្លូវការ នឹងលុបបំបាត់អំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា?

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| មិនយល់ស្របទាំងស្រុង | 1 | 2 | 3 | 4 | 5 | 6 | 7 | យល់ស្របទាំងស្រុង |

## សំណួរអំពីសហគ្រាស

១៧. តើសហគ្រាសអ្នកចាប់ផ្តើមដំណើរការពីឆ្នាំណាមក? ឆ្នាំ: ____________________

១៨. តើសហគ្រាសអ្នកមានបុគ្គលិក/កម្មករប៉ុន្មានអ្នក:

សរុប: ______ ប្រុស: ______ ស្រី: ______

១៩. តើអ្នកអាចប្រាប់ពីចំណូលសរុបរបស់សហគ្រាសអ្នកបានដែរ ឬទេ?

| | ចំណូលសរុប (*) |
|---|---|
| ប្រចាំថ្ងៃ | |
| ប្រចាំខែ | |
| ប្រចាំវដ្តូវ (ឆមាស) | |
| ប្រចាំឆ្នាំ | |

(*) សូមបញ្ជាក់ឯកតារូបិយវត្ថុអោយច្បាស់ (ឧ. រៀល/R ដុល្លា/$ បាត/B)

ឈ្មោះសហគ្រាស:________________________ ប្រភេទអាជីវកម្ម:________________________________

ឈ្មោះអ្នកឆ្លើយតប:____________________________ ភេទ: ☐ ប្រុស ☐ ស្រី

មុខរបរ/តួនាទី:______________________________ អាយុ:__________________________________

អាសយដ្ឋាន:________ សង្កាត់/ភូមិ:_________ ខ័ណ្ឌ/ស្រុក:__________ ខេត្ត/ក្រុង:_________________

ទំនាក់ទំនង (ទូរស័ព្ទ-អ៊ីម៉ែល):__________________________________________________________

ស៊ីកទ័រ: ☐ កសិកម្ម ☐ សេវាកម្ម

☐ ឧស្សាហកម្ម/ផលិតកម្ម/សិប្បកម្ម ☐ ការសាងសង់

# ការសិក្សាស្តីពី ការអភិវឌ្ឍវិស័យឯកជននៅកម្ពុជា
# កម្រងសំណួរ
## (សម្រាប់សហគ្រាសធុន តូច មធ្យម និងធំ)

*វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា* កំពុងធ្វើការសិក្សាស្តីពីការអភិវឌ្ឍវិស័យឯកជននៅកម្ពុជា ដោយមានការគាំទ្រ និងឧបត្ថម្ភពី *ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់កិច្ចអភិវឌ្ឍន៍អន្តរជាតិ (USAID) និង អង្គការផេក-កម្ពុជា (Pact-Cambodia)* និង ***PADCO|AECOM*** ។ ការសិក្សានេះ គឺធ្វើឡើងសម្រាប់ប្រទេសកម្ពុជាទាំងមូលដែលក្នុងនោះ ក្រុមស្រាវជ្រាវនៃវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា នឹងចុះធ្វើការសម្ភាសន៍ជាមួយតំណាងសហគ្រាស ធុនតូច មធ្យម និងធំ សរុបទាំងអស់ចំនួន ១២០០ នៅតាមបណ្តាខេត្ត-ក្រុង ចំនួន ៩ រួមមានក្រុងភ្នំពេញ ខេត្តកណ្តាល កំពង់ចាម ព្រៃវែង កំពត ក្រុងព្រះសីហនុ បាត់ដំបង បន្ទាយមានជ័យ និង សៀមរាប ។

គោលបំណងចុងក្រោយតែមួយគត់នៃការសិក្សានេះ គឺស្វែងយល់អោយកាន់តែស៊ីជំរៅនូវ ឧបសគ្គនានាសម្រាប់អាជីវកម្ម ដើម្បីអាចផ្តល់ជាអនុសាសន៍ដល់រាជរដ្ឋាភិបាលក៏ដូចជាសហគមន៍អ្នកផ្តល់ជំនួយអន្តរជាតិសំដៅជំរុញ និង លើកស្ទួយវិស័យឯកជន ជាពិសេសអាជីវកម្មធុនតូច មធ្យម និងធំ នៅកម្ពុជា។

*យើងខ្ញុំសង្ឃឹមយ៉ាងជឿជាក់ថា លោក/លោកស្រីនឹងចំណាយពេលដ៏មានតំលៃប្រហែល ៣០នាទី ដើម្បី ចូលរួមក្នុងការស្ទាបស្ទង់មតិនេះ ។*

**ព័ត៌មាននៅក្នុងកម្រងសំណួរនេះនឹងត្រូវរក្សាជាការសំងាត់ ។**

០១. ជាទូទៅ តើចំណាយក្រៅផ្លូវការក្នុងវិស័យឯកជននៅប្រទេសកម្ពុជា មានភាពធ្ងន់ធ្ងរកម្រិតណា?

| មិនធ្ងន់ធ្ងរទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | ធ្ងន់ធ្ងរខ្លាំងបំផុត |
|---|---|---|---|---|---|---|---|---|

០២. ជាមធ្យម ក្នុងមួយឆ្នាំ តើសហគ្រាសអ្នកត្រូវចំណាយសរុបដល់មន្ត្រីរាជការប្រហែលប៉ុន្មានភាគរយ នៃចំណូលសរុបរបស់សហគ្រាសអ្នក?

ប្រហែលៈ ___________ភាគរយនៃចំណូលសរុបប្រចាំឆ្នាំ

០៣. ក្នុងរយៈពេល ១២ខែ កន្លងទៅ តើអាជ្ញាធរ/មន្ត្រីខាងក្រោម ធ្លាប់បានចុះត្រួតពិនិត្យសហគ្រាសអ្នកឬទេ? សម្រាប់ការចុះត្រួតពិនិត្យមួយលើកៗ តើអ្នកត្រូវចំណាយប្រហែលប៉ុន្មាន?

| | ចំណាយសរុប (*) | ភាពញឹកញាប់ (ចំនួនប៉ុន្មានដង ក្នុង១ឆ្នាំ?) | ចំណាយផ្លូវការ | ចំណាយក្រៅផ្លូវការ |
|---|---|---|---|---|
| ☐ ប៉ូលីស | | | | |
| ☐ ភ្នាក់ងារពន្ធដារ | | | | |
| ☐ អាជ្ញាធរមូលដ្ឋាន | | | | |
| ☐ ភ្នាក់ងារត្រួតពិនិត្យអគ្គីភ័យ/សុវត្ថិភាព | | | | |
| ☐ ការត្រួតពិនិត្យស្តង់ដារ | | | | |
| ☐ ភ្នាក់ងារបរិស្ថាន | | | | |
| ☐ ភ្នាក់ងារសង្គមកិច្ច និង ការងារ | | | | |
| ☐ ផ្សេងៗ: _______________ | | | | |
| ☐ ផ្សេងៗ: _______________ | | | | |
| **សរុប** | | | | |
| **ភាគរយ(%)** | | | | |

(*) ពតិមានទីនេះសំខាន់ណាស់: សូមបញ្ជាក់ឯកតារូបិយវត្ថុអោយច្បាស់ (ឧ. រៀល/R ដុល្លា/$ បាត/B)

០៤. តើសហគ្រាសរបស់អ្នកបានចុះបញ្ជី (ឬចុះបញ្ជីឡើងវិញ) ដែរ ឬទេ?

☐ បាទ/ចាស (ឆ្នាំចុះបញ្ជី/ចុះបញ្ជីឡើងវិញ: ____________)

☐ ទេ (រំលងទៅសំណួរទី ០៦)

០៥. តើប្រភេទនៃការចុះបញ្ជីសហគ្រាសណាមួយ ដែលអ្នកធ្លាប់ជួបប្រទះ? រាល់ការចុះបញ្ជីពីស្ថាប័ន/អាជ្ញាធរផ្សេងៗ ក្នុងមួយលើក អ្នកត្រូវចំណាយប្រហែលប៉ុន្មាន?

| | ចំណាយសរុប | ចំណាយផ្លូវការ | ចំណាយក្រៅផ្លូវការ |
|---|---|---|---|
| ☐ ការចុះបញ្ជីសហគ្រាស (MoC) | | | |
| ☐ ការចុះបញ្ជីដើម្បីបង់ពន្ធ (MEF) | | | |
| ☐ ការចុះបញ្ជីអាករលើតម្លៃបន្ថែម | | | |
| ☐ ការចុះបញ្ជីការងារ (MLVT) | | | |
| ☐ ការចុះបញ្ជីដីធ្លី (MLMUPC) | | | |
| ☐ ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា (CDC) | | | |
| ☐ ផ្សេងៗ: | | | |
| សរុប | | | |

០៦. តើសហគ្រាសអ្នកដំណើរការដោយមានអាជ្ញាប័ណ្ណ (អាជ្ញាប័ណ្ណប៉ាតង់ ឬ ទំរង់អាជ្ញាប័ណ្ណផ្សេងទៀត) ដែលចេញ ដោយស្ថាប័ន/អាជ្ញាធរផ្សេងៗដែរ ឬទេ?

☐ មាន

☐ អត់មានទេ (រំលងទៅសំណួរទី ០៨)

០៧. តើអ្នកត្រូវចំណាយប៉ុន្មានសម្រាប់ការចុះបញ្ជីសុំអាជ្ញាប័ណ្ណបើកអាជីវកម្ម?

| | ចំណាយសរុប | ចំណាយផ្លូវការ | ចំណាយក្រៅផ្លូវការ |
|---|---|---|---|
| ☐ ការចុះបញ្ជីសុំកន្លែងធ្វើអាជីវកម្ម (ពីអាជ្ញាធរមូលដ្ឋាន) | | | |
| ☐ អាជ្ញាប័ណ្ណបើកអាជីវកម្ម (ពីក្រសួង/មន្ទីផ្សេងៗ) | | | |
| ☐ ផ្សេងៗ: ____________________ | | | |
| សរុប | | | |

០៨. ក្នុងឆ្នាំកន្លងទៅ តើសហគ្រាសអ្នកមាននាំចេញ-នាំចូល (វត្ថុធាតុដើម ឬ ផលិតផលសំរេច) ដែរឬទេ?

☐ មាន

☐ អត់មានទេ (រំលងទៅសំណួរទី ១០)

០៩. ក្នុងឆ្នាំកន្លងទៅ តើការនាំចេញ-នាំចូល (វត្ថុធាតុដើម ឬ ផលិតផលសំរេច) ជាទូទៅធ្វើឡើងដោយមានទំនាក់ទំនង ជាមួយអាជ្ញាធរ/មន្ត្រី ណាខ្លះ? តើអ្នកត្រូវចំណាយប្រហែលប៉ុន្មានដើម្បីបំពេញបែបបទនៃការនាំចេញ-នាំចូល នាឆ្នាំកន្លងទៅ?

| | ចំណាយសរុប | ចំណាយផ្លូវការ | ចំណាយ ក្រៅផ្លូវការ |
|---|---|---|---|
| ☐ អ្នករត់ការនាំចេញ-នាំចូល | | | |
| ☐ ប៉ូលីសព្រំដែន | | | |
| ☐ ការត្រួតពិនិត្យរបស់គយ-រដ្ឋាករ | | | |
| ☐ កាំកុងត្រូល | | | |
| ☐ អាជ្ញាធរត្រួតពិនិត្យគុណភាពអនាម័យ | | | |
| ☐ ផ្សេងៗ: | | | |
| សរុប | | | |

១០. តើសហគ្រាសអ្នក មានធ្វើអាជីវកម្មជាមួយរដ្ឋាភិបាល ឬទេ?

☐ បាទ/ចាស

☐ ទេ (រំលងទៅសំណួរទី ១២)

១១. នៅពេលធ្វើអាជីវកម្មជាមួយរដ្ឋាភិបាល តើគេរំពឹងថានឹងត្រូវចំណាយបន្ថែមក្រៅផ្លូវការប៉ុន្មាន (%នៃតម្លៃកិច្ចសន្យាសរុប) ដើម្បីអោយការដេញថ្លៃទទួលបានជោគជ័យ?

ប្រហែល: ____________នៃតម្លៃកិច្ចសន្យាសរុប

១២. តើចំណាយបន្ថែម (ក្រៅផ្លូវការ) ទៅឱ្យមន្ត្រីរាជការត្រូវបានធ្វើតាមវិធីណា? (ចំលើយអាចលើសពី ១)

☐ មន្ត្រីមានសមត្ថកិច្ចមកកាន់សហគ្រាសអ្នកផ្ទាល់

☐ សហគ្រាសអ្នកទៅទាក់ទងផ្ទាល់ជាមួយមន្ត្រីមានសមត្ថកិច្ច

☐ តាមរយៈអ្នករត់ការ

☐ ផ្សេងៗ: __________________

១៣. តើសហគ្រាសអ្នក ជាទូទៅដឹងជាមុនទេពីចំនួនទឹកប្រាក់ដែលត្រូវបង់បន្ថែមឱ្យទៅមន្ត្រីរាជការ ដើម្បីធានាដល់ដំណើរការល្អនៃអាជីវកម្មដែរ ឬទេ?

| មិនដែលដឹងសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | ជានិច្ចកាលដឹងមុន |
|---|---|---|---|---|---|---|---|---|

១៤. តើអ្នកយល់ស្របទេថា បន្ទាប់ពីមានចំណាយបន្ថែម សេវាសាធារណៈនឹងត្រូវបានផ្តល់អោយអ្នកវិញគួរជាទីពេញចិត្ត ពីសំណាក់មន្ត្រីរាជការ?

| មិនយល់ស្របទាំងស្រុង | 1 | 2 | 3 | 4 | 5 | 6 | 7 | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|---|---|---|

១៥. តើមូលហេតុអ្វី បានជាសហគ្រាសអ្នកយល់ព្រមបង់ចំណាយក្រៅផ្លូវការ? (ចំលើយអាចលើសពី ១)

- ☐ ដើម្បីទទួលបានសេវាសាធារណៈរហ័ស
- ☐ ដើម្បីជៀសវាងការគំរាមកំហែងពីមន្ត្រីរាជការ
- ☐ ដើម្បីការពារផលប្រយោជន៍អាជីវកម្ម
- ☐ ដើម្បីប៉ះប៉ូវទៅនឹងម៉ោងមិនទទួលបានកម្រៃរបស់មន្ត្រីរាជការ
- ☐ ដើម្បីជាសគុណសម្រាប់ការផ្តល់សេវាដោយមន្ត្រីរាជការ
- ☐ ផ្សេងៗ: ______________________

១៦. តាមយោបល់អ្នក តើមូលហេតុអ្វី បានជាមានចំណាយក្រៅផ្លូវការក្នុងវិស័យឯកជននៅប្រទេសកម្ពុជា? សូមអ្នកធ្វើការវាយតំលៃលើមូលហេតុ ដូចខាងក្រោមដោយជ្រើសរើសពីលេខ ១ (មិនជាមូលហេតុទេ) ដល់លេខ ៧ (មូលហេតុចំបងបំផុត)

| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ |
|---|---|---|---|---|---|---|---|
| ប្រាក់ខែមន្ត្រីរាជការទាប | | | | | | | |
| វប្បធម៌នៃអំពើពុករលួយ-ទំលាប់ | | | | | | | |
| ការិយាធិបតេយ្យ-បែបបទរដ្ឋបាលច្រើន និង ស្មុគ្រស្មាញ | | | | | | | |
| ភាពធូរលុងនៃការអនុវត្តច្បាប់ | | | | | | | |
| តុលាការខ្វះភាពឯករាជ្យ និង គ្មានប្រសិទ្ធភាព | | | | | | | |
| ខ្វះការត្រួតពិនិត្យ- ខ្វះការទទួលខុសត្រូវរបស់មន្ត្រីរាជការ | | | | | | | |
| ខ្វះប្រព័ន្ធតាមដានអំពើពុករលួយប្រកបដោយប្រសិទ្ធភាព | | | | | | | |
| ខ្វះក្រមសីលធម៌ក្នុងសង្គម | | | | | | | |
| ខ្វះលទ្ធិប្រជាធិបតេយ្យ | | | | | | | |
| ប្រសិទ្ធភាពសង្គមស៊ីវិលនៅមានកំរិត | | | | | | | |
| ផ្សេងៗ: ______________________ | | | | | | | |

១៧. ជាទូទៅ តើអ្នកណាជាអ្នកដោះស្រាយជាមួយ មន្ត្រីមានសមត្ថកិច្ចដែលចុះមកពិនិត្យសហគ្រាសអ្នក?

☐ ម្ចាស់សហគ្រាស (ប្រុស) ☐ បុគ្គលិករដ្ឋបាល (ប្រុស)

☐ ម្ចាស់សហគ្រាស (ស្រី) ☐ បុគ្គលិករដ្ឋបាល (ស្រី)

☐ ផ្សេងៗ: ___________

១៨. តាមយោបល់អ្នក តើសកម្មភាពរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ទទួលបានជោគជ័យកម្រិតណា?

| មិនជោគជ័យទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | ជោគជ័យយ៉ាងខ្លាំង |
|---|---|---|---|---|---|---|---|---|

១៩. តើអ្នកដែលឮពីច្បាប់ប្រឆាំងអំពើពុករលួយដែរឬទេ?

☐ បាទ/ចាស

☐ ទេ

២០. តើអ្នកគិតថា ច្បាប់ប្រឆាំងអំពើពុករលួយដែលរដ្ឋសភាជាតិនឹងអនុម័តនាពេលឆាប់ៗខាងមុខនេះ មានប្រសិទ្ធភាពដែរឬទេ?

| មិនមានប្រសិទ្ធភាពទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | មានប្រសិទ្ធភាពខ្លាំងបំផុត |
|---|---|---|---|---|---|---|---|---|

២១. តើអ្នកមានជំនឿថា វិធានការណ៍ខាងក្រោមមានប្រសិទ្ធភាពកំរិតណាក្នុងការលុបបំបាត់អំពើរពុករលួយក្នុងវិស័យឯកជននៅកម្ពុជា?

២១-០១. ការតំឡើងប្រាក់ខែសម្រាប់មន្ត្រីរាជការ

| មិនមានប្រសិទ្ធភាពទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | មានប្រសិទ្ធភាពខ្លាំងបំផុត |
|---|---|---|---|---|---|---|---|---|

២១-០២. ការលើកទឹកចិត្តទៅតាមការប្រតិបត្តិការងារជាក់ស្តែងរបស់មន្ត្រីរាជការ

| មិនមានប្រសិទ្ធភាពទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | មានប្រសិទ្ធភាពខ្លាំងបំផុត |
|---|---|---|---|---|---|---|---|---|

២១-០៣. ការបង្កើតអោយមានអាជ្ញាធរឯករាជ្យតាមដានអំពើរពុកលួយ

| មិនមានប្រសិទ្ធភាពទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | មានប្រសិទ្ធភាពខ្លាំងបំផុត |
|---|---|---|---|---|---|---|---|---|

២១-០៤. ការបង្កើតអោយមានប្រព័ន្ធ-បណ្តាញ រាយការណ៍អំពីអំពើពុករលួយ

| មិនមានប្រសិទ្ធភាពទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | មានប្រសិទ្ធភាពខ្លាំងបំផុត |
|---|---|---|---|---|---|---|---|---|

២១-០៥. ការប្រកាសជាសាធារណៈនៃទ្រព្យសម្បត្តិមន្ត្រីរាជការ

| មិនមានប្រសិទ្ធភាពទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | មានប្រសិទ្ធភាពខ្លាំងបំផុត |
|---|---|---|---|---|---|---|---|---|

២១-០៦. ការផ្សព្វផ្សាយជាសាធារណៈនូវតំលៃផ្លូវការនានា ដែលតម្រូវដោយរដ្ឋាភិបាល

| មិនមានប្រសិទ្ធភាពទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | មានប្រសិទ្ធភាពខ្លាំងបំផុត |
|---|---|---|---|---|---|---|---|---|

២១-០៧. សេវាបង់តែមួយ (សេវាច្រកទ្វារតែមួយរបស់រដ្ឋាភិបាល) សម្រាប់អាជីវកម្ម

| មិនមានប្រសិទ្ធភាពទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | មានប្រសិទ្ធភាពខ្លាំងបំផុត |
|---|---|---|---|---|---|---|---|---|

២១-០៨. ការជំរុញអោយមានសមាគមន៍អាជីវកម្មដែលអាចចរចារជាមួយរដ្ឋាភិបាល

| មិនមានប្រសិទ្ធភាពទាល់តែសោះ | 1 | 2 | 3 | 4 | 5 | 6 | 7 | មានប្រសិទ្ធភាពខ្លាំងបំផុត |
|---|---|---|---|---|---|---|---|---|

២២. តើអ្នកយល់ស្របទេថា ការធ្វើចំណាយក្រៅផ្លូវការ អោយទៅជាចំណាយផ្លូវការ នឹងលុបបំបាត់អំពើពុករលួយក្នុងវិស័យឯកជននៅកម្ពុជា?

| មិនយល់ស្របទាំងស្រុង | 1 | 2 | 3 | 4 | 5 | 6 | 7 | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|---|---|---|

## សំណួរអំពីសហគ្រាស

២៣. តើសហគ្រាសអ្នកចាប់ផ្តើមដំណើរការពីឆ្នាំណាមក? ឆ្នាំ: ___________________

២៤. តើសហគ្រាសអ្នកមានបុគ្គលិក/កម្មករប៉ុន្មាននាក់:

សរុប: ______ ប្រុស: ______ ស្រី: ______

២៥. តើសហគ្រាសរបស់អ្នកមានកាន់កាប់ដោយភាគហ៊ុនបរទេសដែរ ឬទេ?

ភាគហ៊ុនក្នុងស្រុក: ___________%

ភាគហ៊ុនបរទេស: ____________%

២៦. តើអ្នកអាចប្រាប់ពីចំណូលសរុបរបស់សហគ្រាសអ្នកបានដែរ ឬទេ?

| | ចំណូលសរុប (*) |
|---|---|
| ប្រចាំថ្ងៃ | |
| ប្រចាំខែ | |
| ប្រចាំវគ្គ (ឆមាស) | |
| ប្រចាំឆ្នាំ | |

(*) សូមបញ្ជាក់ឯកតារូបិយវត្ថុអោយច្បាស់ (ឧ. រៀល/R ដុល្លា/$ បាត/B)

ឈ្មោះសហគ្រាស: ____________________________ ប្រភេទអាជីវកម្ម: ____________________________

ឈ្មោះអ្នកឆ្លើយតប: ____________________________ ភេទ: ☐ ប្រុស ☐ ស្រី

មុខរបរ/តួនាទី: ______________________________ អាយុ: ____________________________________

អាសយដ្ឋាន: _________ សង្កាត់/ភូមិ: _________ ខ័ណ្ឌ/ស្រុក: _____________ ខេត្ត/ក្រុង: _____________

ទំនាក់ទំនង (ទូរស័ព្ទ-អ៊ីម៉ែល): ____________________________________________________________

ស៊ីកទ័រ: ☐ កសិកម្ម ☐ វាំកម្ម

☐ ឧស្សាហកម្ម/ផលិតកម្ម/សិប្បកម្ម ☐ ការសាងសង់

# សំណួរ (ណែនាំ) សម្រាប់កិច្ចពិភាក្សាជាក្រុម

១. តើមានអាជ្ញាធរណាខ្លះ ដែលទាមទារឱ្យអ្នកបង់ចំណាយក្រៅផ្លូវការជាញឹកញាប់? ហេតុអ្វី?

២. តើសហគ្រាសរបស់អ្នកបានចុះបញ្ជី ឬទទួលអាជ្ញាប័ណ្ណ (ប៉ាតង់) ពីរដ្ឋាភិបាលឬទេ? ហេតុអ្វីមាន និង ហេតុអ្វីគ្មាន?

៣. ហេតុអ្វីបានជាសហគ្រាសចាំបាច់ត្រូវបង់ចំណាយក្រៅផ្លូវការទៅឱ្យមន្ត្រីសាធារណៈ?

៤. តើអ្នកគិតថាហេតុអ្វីបានជាមន្ត្រីសាធារណៈទារប្រាក់ក្រៅផ្លូវការពីវិស័យឯកជន?

៥. តើការបង់ចំណាយក្រៅផ្លូវការក្នុងវិស័យឯកជនមានកម្រិតធ្ងន់ធ្ងរចំពោះអាជីវកម្មរបស់អ្នកទេ? ហេតុអ្វីធ្ងន់ធ្ងរ? និង ហេតុអ្វីមិនធ្ងន់ធ្ងរ?

៦. តើការបង់ចំណាយក្រៅផ្លូវការ និងអំពើពុករលួយជះឥទ្ធិពលអ្វីខ្លះទៅលើអាជីវកម្មរបស់អ្នក?

៧. តើនរណាខ្លះដែលធ្វើការដោះស្រាយជាមួយមន្ត្រីសាធារណៈទាំងនោះ? តើស្ត្រី ឬបុរសដែលមានប្រសិទ្ធភាពជាងក្នុងការដោះស្រាយជាមួយមន្ត្រីទាំងនោះ? ហេតុអ្វីមានប្រសិទ្ធភាព? និងហេតុអ្វីមិនមានប្រសិទ្ធភាព?

៨. ដើម្បីកាត់បន្ថយអំពើពុករលួយក្នុងវិស័យឯកជន តើមានវិធីណាខ្លះដែលអ្នកគិតថាល្អបំផុតដើម្បីកាត់បន្ថយអំពើពុករលួយ?

៩. តើអ្នកអាចមានតួនាទីអ្វីខ្លះក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយក្នុងវិស័យឯកជន? តើធ្វើយ៉ាងណាដើម្បីឱ្យតួនាទីទាំងនេះអាចសម្រេចបានជោគជ័យ? នរណាខ្លះអាចជួយអ្នកបាន?

១០. ប្រសិនបើចម្លើយចំពោះសំណួរខាងលើឆ្លើយថាជាការបង្កើតសមាគម តើចាំបាច់មានគំនិតផ្តួចផ្តើមអ្វីខ្លះសម្រាប់សមាគមនោះ ដើម្បីធ្វើយ៉ាងណាឱ្យសមាគមនេះដំណើរការទៅយ៉ាងល្អ? ធ្វើយ៉ាងណា? នរណាអាចជួយបាន? តើសហគ្រាសមានឆន្ទៈនឹងចូលរួមក្នុងសមាគមនេះទេ? (តួនាទីរបស់ស្ត្រីក្នុងសមាគមមានអ្វីខ្លះ?)

១១. តើសកម្មភាពអាទិភាពអ្វីខ្លះដែលរដ្ឋាភិបាលគួរតែអនុវត្តដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ? តើរដ្ឋាភិបាលគួរដោះស្រាយបញ្ហាអំពើពុករលួយដែលមានកម្រិតតិចតួចមុន ឬអំពើពុករលួយដែលមានកម្រិតខ្លាំងមុន? ហេតុអ្វីត្រូវដោះស្រាយ និង ហេតុអ្វីមិនដោះស្រាយ?

## សំណួរសម្រាប់កិច្ចសម្ភាសន៍ជាមួយមន្ត្រីសាធារណៈ

១. ហេតុអ្វីមន្ត្រីសាធារណៈក្នុងប្រទេសកម្ពុជាយកប្រាក់ក្រៅផ្លូវការពីម្ចាស់អាជីវកម្ម?
២. តើមន្ត្រីសាធារណៈប្រើប្រាស់ប្រាក់ដែលពួកគេទទួលបានពីការបង់ក្រៅផ្លូវការទាំងនោះធ្វើអ្វីខ្លះ?
៣. ប្រសិនបើប្រាក់បៀវត្សរ៍គ្រប់គ្រាន់ តើអ្នកគិតថា មន្ត្រីសាធារណៈនឹងបញ្ឈប់ការយកប្រាក់ក្រៅផ្លូវ ការពីម្ចាស់អាជីវកម្មដែរឬទេ? បើមិន ហេតុអ្វី?
៤. ក្នុងប្រទេសផ្សេងៗ ប្រាក់បៀវត្សរ៍សម្រាប់មន្ត្រីសាធារណៈគ្រប់គ្រាន់។ បើតាមគំនិតរបស់អ្នក តើហេតុអ្វីបានជាមន្ត្រីសាធារណៈនៅតែយកប្រាក់ក្រៅផ្លូវការពីវិស័យឯកជន?
៥. តើប្រាក់បៀវត្សរ៍ប៉ុន្មាន ដែលគ្រប់គ្រាន់សម្រាប់មន្ត្រីម្នាក់?
៦. តើអ្នកមានអនុសាសន៍អ្វីខ្លះ ដែលអាចជួយកាត់បន្ថយការយកប្រាក់ក្រៅផ្លូវការពីវិស័យឯកជន?
៧. ច្បាប់ប្រឆាំងអំពើពុករលួយនឹងត្រូវអនុម័តក្នុងពេលឆាប់ៗខាងមុខ ដោយរដ្ឋសភាជាតិ។ តើអ្នកគិតថា ច្បាប់នេះនឹងមានប្រសិទ្ធភាពឬទេ?

ឧបត្ថម្ភដោយ:

ការបោះពុម្ពនេះ បានទទួលការឧបត្ថម្ភពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីកិច្ចអភិវឌ្ឍន៍អន្តរជាតិ (USAID)។ ទស្សនៈទាំងឡាយដែលបានបង្ហាញនៅក្នុងការបោះពុម្ពនេះជាគំនិតរបស់អ្នកនិពន្ធ និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកទេ។

ផលិតដោយ:

វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា

បន្ទប់លេខ ២៣៤ អាគារភ្នំពេញសិនធ័រ កែងផ្លូវលេខ ២៧៤ និង ៣ ប្រអប់សំបុត្រលេខ ១០០៨ ភ្នំពេញ កម្ពុជា

ទូរស័ព្ទ: (+៨៥៥) ២៣ ៩៨៧ ៩៤១ ទូរសារ: (+៨៥៥) ២៣ ២២៤ ៦២៦

អ៊ីម៉ែល: eic@eicambodia.org វិបសាយ: http://www.eicambodia.org

ខែ កក្កដា ឆ្នាំ ២០០៦